១០

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៨ ខែ តុលា

ព.ស. ២៥០៩ គ.ស. ១៩៦៦

– ភ្នំពេញ –

NATIONALE
U CAMBODGE
P.K-1
1966-10

C.205/82/597/51/ក

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

១– សាភណីយធម្មកថា ព្រះមហាឧត្ដមវិជ្ជា អេង-ទេមី រៀបរៀង . . . ១០០១
២– សុខគវេសកកថា ភិក្ខុ សួស-ជ្រិន រៀបរៀង . . . . . ១០១១

*ផ្នែកអក្សរសាស្ត្រ*

៣– ប្រវត្តិព្រះឧត្តមមុនី អ៊ុម-ស៊ូ លោក ជាប-ពិន រៀបរៀង . . . ១០២៤
៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . ១០៣៧
៥– ព្រះរាជនិពន្ធកមកេរ្តិ៍ លោក ឧ. ធាម ស្រាវជ្រាវ (ត) . . . . . ១០៤១
៦– ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . ១០៥០
៧– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . ១០៥៣
៨– ឯកសារកម្ពុជសុរិយា លោក ឧ.ធាម ប្រមូលរៀបរៀង (ត) . . . ១០៦១
៩– អត្ថបទផ្នែកទំនៀមទម្លាប់ រឿងភ្នំក្រោម . . . . . . ១០៦៩
១០– ប្រវត្តិស្រុកត្បូងឃ្មុំ និង អ្នកតាបេង . . . . . . . ១០៧២
១១– ជីវប្រវត្តិរបស់ខ្ញុំឈ្មោះ អៀង-សាយ (ត) . . . . . . ១០៧៥

*ផ្នែកកំណត់និងប្រវត្តិការណ៍*

១២– ភ្នំពេញ ថ្ងៃទី ៥ កញ្ញា ១៩៦៦ នាយកនៃពុទ្ធសាសនបណ្ឌិត្យ . . . ១០៨៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៖០០ ។

# ផ្នែកសាសនា

> ពាក្យយាត់មិនឲ្យ ធ្វើការអាក្រក់
> ជាការលាមក, ឲ្យធ្វើល្អពៅ,
> ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
> បីនេះលោកហៅ ពុទ្ធសាសនា ។
>
> ក.ត.

## សារាណីយធម្មកថា

វិទ្យុធម្មទេសនា ពីថ្ងៃទី ២២-៩-៦៦

របស់ព្រះមហាឧត្តមវិជ្ជា អេង-ទេមី វត្តស្វាយពពៃ

សង្កាត់លេខ ៦ ក្រុងភ្នំពេញ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃ ដោយគោរព ។

បន្ទាប់អំពីនេះ នឹងបានសំដែងនូវព្រះធម្មទេសនា ជាគ្រឿងប្រដាប់ប្រាជ្ញាបារមី និង ជាផ្លូវវត្តប្រតិបត្តិ នៃអស់លោកពុទ្ធបរិស័ទទាំងឡាយ ដើម្បីនឹងបានសំរេចប្រយោជន៍ក្នុងការស្តាប់តាមសមគួរ ។ អាត្មាភាពដែលបានឱកាសមកសំដែងព្រះធម៌ទេសនា ផ្សាយតាមវិទ្យុជាតិក្នុងពេលនេះ នឹងលើកយកសារាណីយធម៌ ដែលមានមកក្នុងគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាត មកធ្វើអត្ថាធិប្បាយ ដោយសង្ខេប ។ ឲ្យ

សមល្មមទៅតាមកាលវេលា ដែលលោកអ្នកចាត់ការបានកំណត់ទុកឲ្យ ។

ពាក្យថា សាពណីយធម៌ ប្រែថាធម៌ជាទីតាំងនៃសេចក្តីរឭក ឬធម៌ជាគ្រឿងធ្វើឲ្យរឭកដល់គ្នានិងគ្នា, បានសេចក្តីថា ធម៌សំរាប់ធ្វើមនុស្ស ដែលមានជីវិតការរស់នៅប្រព្រឹត្តទៅដូចគ្នា មិនឲ្យមានសេចក្តីប្រទូស-រ៉ាយគ្នា មិនឲ្យបៀតបៀនគ្នា ឲ្យមានតែសេចក្តីស្រឡាញ់រាប់អានគ្នា មានសេចក្តីព្រមព្រៀងគ្នា យល់គ្នាទៅវិញទៅមក ដែលជាហេតុឲ្យកើតសេចក្តីសុខសេចក្តីចម្រើន ៗ នៅទីណាក៏ដោយ កាលបើខ្វះសេចក្តីសាមគ្គីព្រមព្រៀងគ្នា គ្មានសេចក្តីយោគយល់គ្នាទៅវិញទៅមកទេ មានតែការប្រកួតប្រណាំងគ្នា ទាស់ទែងខ្វែងគំនិតគ្នាហើយ ទីនោះនឹងរកសេចក្តីសុខសេចក្តីចម្រើនមិនបានជាដាច់ខាត, ផ្ទុយទៅវិញ កន្លែងណាដែលមនុស្សអាស្រ័យនៅមានសេចក្តីយោគយល់គ្នា មានសេចក្តីសាមគ្គីព្រមព្រៀងគ្នាហើយ កន្លែងនោះរមែងមានតែសេចក្តីស្ងប់ស្ងៀម មនុស្សអ្នកនៅទីកន្លែងនោះ រមែងមានតែសេចក្តីសុខសេចក្តីចំរើនរុងរឿង ៗ

មនុស្សគ្រប់រូបដែលកើតមកក្នុងលោកនេះ មិនថាជាតិណា ថ្នាក់ណា ភេទប្រុស ឬស្រីទេ សុទ្ធតែជាអ្នកស្អប់ខ្លាចទុក្ខ ស្រឡាញ់សុខ ប្រាថ្នាចង់បានសុខដូចគ្នាទាំងអស់ រហូតដល់សត្វតិរច្ឆានជាទីបំផុត ក៏ចេះស្អប់ខ្លាចទុក្ខ ស្រឡាញ់សុខដែរ ។ តែមានមនុស្សពួកខ្លះ ស្អប់ទុក្ខ ស្រឡាញ់សុខ ហើយត្រឡប់ជាធ្វើអំពើអាក្រក់ទុច្ចរិត ដែលជាហេតុ

ឲ្យខ្លួនបានទទួលសេចក្ដីក្ដៅក្រហាយវិញ, ទាំងនេះ ក៏ព្រោះសេចក្ដីប្រមាទខ្វះ ព្រោះសេចក្ដីលង់ទៅវង្វេងកាន់ច្រឡំខុស ។ ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ដែលព្រះអង្គមានទឹកព្រះទ័យ ពេញទៅដោយព្រះមហាករុណាទិគុណ ទ្រង់អាសូរដល់ប្រជាសត្វទៅឥតសេមុខ កាលបើទ្រង់ជ្រាបច្បាស់ នូវគោលបំណងរបស់សត្វលោក ដូច្នេះហើយ ទើបព្រះអង្គទ្រង់សំដែង នូវវិធីសំរាប់ស្វែងរកសេចក្ដីសុខ ទុកឲ្យពួកពុទ្ធបរិស័ទបដិបត្តិតាម ដើម្បីនឹងបានទទួលផល គឺសេចក្ដីសុខសេចក្ដីចម្រើន តាមសមគួរដល់ការបដិបត្តិ ។ ពុទ្ធវិធីសម្រាប់បដិបត្តិ ដើម្បីស្វែងរកសេចក្ដីសុខ ដែលមានមកក្នុងព្រះសុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាតនោះ មានឈ្មោះថា សារាណីយធម៌ គឺធម៌ជាគ្រឿងធ្វើមនុស្សឲ្យរឭកដល់គ្នានិងគ្នា ឲ្យមានការរួបរួមសាមគ្គីព្រមព្រៀងគ្នា ឲ្យមានមេត្តាចិត្តជួយសង្គ្រោះគ្នា មិនឈ្លោះវិវាទបៀតបៀនគ្នា កាលបើធម៌សាមគ្គីមានឡើងហើយ សេចក្ដីសុខសេចក្ដីចម្រើន ក៏នឹងកើតមានដែរ ។

## សារាណីយធម៌នោះ មាន ៦ ប្រការគឺ

១– ការតាំងកាយកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ គឺការបង្អោនកាយប្រកបដោយមេត្តាជួយធ្វើកិច្ចការងារផ្សេង ៗ ដែលសហធម្មិកអ្នករួមរស់នៅជាមួយគ្នាត្រូវធ្វើ ជួយប្រកបកិច្ចការដែលជាប្រយោជន៍សាធារណៈ

ដោយសេចក្តីអនុគ្រោះពិត ៗ ជួយព្យាបាលថែរក្សាគ្នា ក្នុងពេលដែលអ្នកនៅជាមួយគ្នាមានកើតព្យាធិបៀតបៀន ត្រូវមានការសាមគ្គីព្រមព្រៀងគ្នាប្រកបដោយមេត្តា ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ។

២- ការតាំងវចីកម្មប្រកបដោយមេត្តា ជួយរំឭកដាស់តឿន ជួយបង្ហាត់បង្រៀនមនុស្ស ដែលរស់នៅក្នុងគ្រួសារ ភូមិស្រុកជាមួយគ្នា ឲ្យចេះដឹងធម៌អាថ៌សិក្ខាវិន័យ ឲ្យដឹង បាប បុណ្យ គុណ ទោស ព្យាយាមពន្យល់ឲ្យស្គាល់ច្បាស់ថា នេះ ជាអំពើអាក្រក់ ដែលនឹងឲ្យផលអាក្រក់ គឺនឹងនាំមកនូវសេចក្តីទុក្ខ សេចក្តីក្តៅក្រហាយវិនាសអន្តរាយ ទាំងក្នុងលោកនេះ និងលោកខាងមុខ, អំពើនេះ ជាអំពើល្អ ជាអំពើដែលនឹងឲ្យផលល្អ គឺសេចក្តីសុខសេចក្តីចម្រើនដល់អ្នកធ្វើ ។ ជួយទូន្មានប្រៀនប្រដៅ ឲ្យចេះចៀសវាងការធ្វើអំពើទុច្ចរិតផ្សេង ៗ ឲ្យធ្វើតែអំពើល្អដែលជាបុណ្យជាកុសល ជាហេតុឲ្យកើតសេចក្តីសុខសេចក្តីចម្រើន ។

៣- ការតាំងមនោកម្មប្រកបដោយមេត្តា ផ្សាយមេត្តាចិត្តទៅកាន់មនុស្ស ដែលរស់នៅក្នុងគ្រួសារ ឬភូមិស្រុកជាមួយគ្នា ដោយផ្តងមេត្តាចិត្ត គិតតែពីឲ្យមនុស្សទាំងនោះ ទោះជាមិត្តក្តី ជាសត្រូវក្តី បានជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចម្រើន មានកេរ្តិ៍ឈ្មោះពីរោះល្អ កុំបីជាអ្នកមានពៀរវេរានឹងគ្នា កុំបៀតបៀនគ្នា កុំបីជាអ្នកមានទុក្ខភ័យបៀត

បៀនឲ្យលំបាកកាយលំបាកចិត្តឡើយ ។ គាំទ្រមេត្តាចិត្ត គិតឲ្យគេបាន សេចក្តីសុខៈសេចក្តីចម្រើនគ្រប់ៗគ្នា ចូរទៅឥតភេសមុខ ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី ។

៦– ការចែករំលែកលាភសក្ការៈ ដែលគេបានដោយធម៌ ឲ្យដល់គ្នានិងគ្នា គឺបើខ្លួនមានសំលៀកបំពាក់ អាហារភោជន សេនាសនៈ ទីស្នាក់អាស្រ័យ ថ្នាំសម្រាប់ព្យាបាលការពាររោគ ដែលគេបានដោយសុចរិតធម៌ មិនមែនបានមកដោយការលួចប្លន់បោកគេទេ ហើយមានល្មមនឹងចែករំលែកឲ្យបាន គួរបែងចែកដល់មនុស្សដែលអាស្រ័យនៅជាមួយគ្នា ឲ្យបានប្រើប្រាស់បរិភោគ ដើម្បីបានទទួលនូវសេចក្តីសុខ ប្រាសចាកទុក្ខ ព្រោះសេចក្តីខះខាតផ្សេង ៗ ផ្តល់ឲ្យដោយការគាំទ្រចិត្ត ជួយសង្គ្រោះគ្នា ឲ្យបានសេចក្តីសុខផុតចាកទុក្ខពិត ៗ ។

៧– ការរក្សាសីលឲ្យបរិសុទ្ធហ្មត់ចត់ស្មើគ្នា រក្សាចរិយាការប្រព្រឹត្ត ដោយកាយវាចាឲ្យស្អាតបរិសុទ្ធ ផុតចាកមន្ទិលទោសផ្សេង ៗ គឺ គាំទ្រវិរតិចេតនា ចៀសវាងការសម្លាប់សត្វបំបាត់ជីវិតគេ វាយដំប្រចាក់ ប្រទូសរ៉ាយរាងកាយអ្នកដទៃ ពប់គាំទ្រពីសត្វជាទាបហេតុដល់មនុស្ស, ចៀសវាងការប្រព្រឹត្តិរំលោភ លើបុត្រធីតា ភរិយា ស្វាមីអ្នកដទៃ ដែលជាហេតុឲ្យគេកើតសេចក្តីទុក្ខក្តៅក្រហាយ មិនសប្បាយចិត្ត, ចៀសវាងការនិយាយកុហកបញ្ឆោតអ្នកដទៃ, ចៀសវាងការផឹកទឹកស្រវឹង គឺស្រា

និង មេរ័យ ដែលជាហេតុឲ្យកើតសេចក្តីវង្វេងភ្លេចស្មារតី ហើយធ្វើអំពើអាក្រក់ផ្សេង ៗ មានការកាប់សម្លាប់ជាដើម ជាហេតុឲ្យមានអន្តរាយដល់សិក្ខាបទដទៃទៀត ៗ ជាពិសេសជាងនេះទៅទៀត ត្រូវរក្សាសីល ៨ សីល ១០ ឲ្យបរិសុទ្ធហ្មត់ចត់ស្មើគ្នា កុំបណ្តោយឲ្យធ្លាយធ្លុះពព្រុះពពាល តាំងចិត្តសង្រួមរាំងយ៉ាងតឹងរឹង តាំងក្នុងវិចំពោះមុខ តាំងក្នុងទីកំបាំងមុខ ដែលជាគ្រឿងបំបាត់នូវសេចក្តីក្តៅក្រហាយ ម៉ិនឲ្យកើតមានឡើង ក្នុងចំណោមមនុស្សដែលរស់នៅជាមួយគ្នា ៗ

៦- ការមានទិដ្ឋិសេចក្តីយល់ឃើញស្របគ្នា មិនមានមតិយល់ខ្វែងគ្នាឡើយ, មានសេចក្តីយល់ត្រូវ យល់ល្អប្រពៃ ស្របទៅតាមគន្លងធម៌ ដែលហៅថា សម្មាទិដ្ឋិ បានដល់សេចក្តីយល់ថា សង្ខារទាំងឡាយ គឺឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណគ្រប់គ្រងក្តី អនុបាទិន្នកសង្ខារ គឺសង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រងក្តី សូម្បីមានប្រភេទផ្សេង ៗ គ្នាយ៉ាងណាក៏ដោយ ក៏គង់មានការប្រព្រឹត្តទៅដូចគ្នា មានសភាពស្មើគ្នា ដោយមានលក្ខណៈទាំង ៣ ប្រចាំដូចគ្នាទាំងអស់ គឺអនិច្ចតា សភាពជារបស់មិនទៀង ទុក្ខតា សភាពជារបស់ទុក្ខ អនត្តតា សភាពជារបស់មិនមែនជាខ្លួនជាប្រាណ ទាំងមានសេចក្តីយល់ឃើញយ៉ាងជ្រាលជ្រៅ ឬ យ៉ាងជាន់ខ្ពស់តទៅទៀត គឺយល់ច្បាស់ថា នេះជាទុក្ខ នេះជាហេតុឲ្យទុក្ខកើត នេះជាសេចក្តីរលត់ទុក្ខ នេះជាផ្លូវសម្រាប់

បដិបត្តិដើម្បីដល់នូវសេចក្តីរលត់ទុក្ខ ។ ការមានទិដ្ឋិសេចក្តីយល់ត្រូវស្មើគ្នានេះ រមែងធ្វើមនុស្សអ្នកនៅជាមួយគ្នា ឲ្យមានសេចក្តីស្រឡាញ់ទុកចិត្តស្និទ្ធស្នាលនឹងគ្នា មិនវៀសគ្នា មានតែសេចក្តីព្រមព្រៀងគ្នាយ៉ាងជិតស្និទ្ធ ។

ធម៌ទាំង ៦ ប្រការ ដូចបានរៀបរាប់មកនេះ ជាធម៌មានប្រសិទ្ធិ-ភាព អាចដឹកនាំមនុស្សឲ្យចេះស្រឡាញ់រាប់អានគ្នា ឲ្យចេះគោរពកោតក្រែងគ្នាទៅវិញទៅមក មិនមើលងាយបៀតបៀនគ្នា ។ សារាណីយ-ធម៌នេះ មាននៅមនុស្សពួកណា រមែងនាំឲ្យមនុស្សពួកនោះ មានសេចក្តីសាមគ្គីព្រមព្រៀងគ្នា មិនប្រកែងប្រណាំងគ្នា ចេះអត់ឱនយោគយល់អធ្យាស្រ័យគ្នា ជួយសង្គ្រោះគ្នាទៅវិញទៅមក ។ បុគ្គលពួកណាដែលមានសេចក្តីព្រមព្រៀងយល់ស្របគ្នា មិនទាស់ទែងខ្វែងគំនិតគ្នាហើយបុគ្គលពួកនោះ រមែងជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចម្រើន ប្រាសចាកឧបសគ្គផ្សេងៗទៅបាន ។ តាមធម្មតា គ្រួសារនីមួយៗតែងមានការរស់នៅដោយសេចក្តីសុខស្ងប់ស្ងៀម មានរបៀបរៀបរយល្អណាស់ទាំងនេះ ក៏ព្រោះសមាជិកនៃគ្រួសារនោះ មានធម៌សាមគ្គីព្រមព្រៀងគ្នាមានការយោគយល់ស្គាល់អធ្យាស្រ័យគ្នាទៅវិញទៅមក, ស្វាមី មានមេត្តាចិត្ត អាណិតអាសូរ ជួយសង្គ្រោះភរិយាតាមឋានៈ, ភរិយា ក៏ចេះគោរពកោតក្រែងស្វាមី បដិបត្តិទំនុកបម្រុងស្វាមី មិនពោលពាក្យគ្រោតគ្រាត

ប្រើតែពាក្យដែលសុភាពរាបសា ផ្អែមល្ហែមទៅកាន់ស្វាមី, បិតាមាតា ជួយទំនុកបម្រុងបុត្រធីតា ថែរក្សាបុត្រធីតា រហូតដល់មនុស្សដែលអាស្រ័យនៅជាមួយផង ឲ្យបានសេចក្តីសុខសួស្តីផុតចាកទុក្ខភ័យវិបត្តិផ្សេង ៗ, បុត្រធីតា ក៏ចេះគោរពក្រាបសំពះមាតាបិតា បដិបត្តិតាមពាក្យទូន្មានប្រៀនប្រដៅរបស់មាតាបិតា, បង មានធម៌មេត្តាចេះអត់ឱនឲ្យប្អូន ចែករំលែកវត្ថុផ្ទាល់ខ្លួនឲ្យដល់ប្អូន ផ្តល់សុខឲ្យដល់គ្នានិងគ្នា, ប្អូន ក៏ចេះគោរពបងតាមឋានៈ ៗ ដោយអាស្រ័យការយោគយល់ផ្តល់អធ្យាស្រ័យគ្នានេះហើយ ទើបគ្រួសារនីមួយ ៗ តែងមានសេចក្តីស្ងប់ស្ងៀម គ្មានការវិវាទទាស់ទែងកាប់សម្លាប់ដណ្តើមអំណាចគ្នាឡើយ ដែលជាហេតុឲ្យមានតែសេចក្តីសុខសេចក្តីចម្រើនតែម្យ៉ាង ៗ ដូច្នេះ ប្រសិនបើមនុស្សដែលនៅរួមគ្នាជាពួកជាក្រុមច្រើន ៗ មានធម៌សាមគ្គីយោគយល់គ្នានិងគ្នាហើយ រមែងមានតែសេចក្តីសុខសេចក្តីចម្រើន ៗ ក្នុងភូមិ ស្រុកប្រទេសណា ដែលប្រជាពលរដ្ឋ មានសេចក្តីព្រមព្រៀងគ្នាជាធ្លុងមួយ មានការយោគយល់គ្នា មិនប្រជែងប្រណាំងគ្នាហើយ, ភូមិ ស្រុកប្រទេសនោះ នឹងមានសេចក្តីរឹងប៉ឹង មានកម្លាំងមាំមួន អាចតទប់នឹងសត្រូវរក្សាការពារសេចក្តីស្ងប់សុខ កំចាត់ភយន្តរាយគ្រប់យ៉ាងបាន, ពលរដ្ឋក្នុងភូមិ ស្រុក ប្រទេសនោះ ក៏នឹងបានផុតអំពីសេចក្តីទុក្ខលំបាកផ្សេង ៗ មានតែសេចក្តីសុខសេចក្តីចម្រើនលូតលាស់ជាពិតប្រាកដ ៗ បើពលរដ្ឋ

ក្នុងពិភពលោកទាំងមូលនេះ ព្រោះអប់រំបណ្តុះសារាណីយធម៌ ឲ្យកើតមាន ក្នុងសន្តានចិត្តគ្រប់ ៗ គ្នា មានសេចក្តីព្រមព្រៀងគ្នា យល់អធ្យា-ស្រ័យគ្នាទៅវិញទៅមក មានមេត្តាចិត្ត គិតឲ្យមនុស្សផងគ្នាបានសេចក្តីសុខ ផុតចាកទុក្ខសោក ៗ គ្នា មិនបង់ចិត្តបៀតបៀនគ្នាហើយ សាកលលោក ក៏នឹងមិនមានការចលាចល ជ្រួលច្របល់ កាប់សម្លាប់គ្នាឡើយ, នឹងមានតែសេចក្តីសុខសន្តិភាព, ប្រជាពលរដ្ឋក្នុងលោកទាំងអស់ ក៏នឹងផុតចាកសេចក្តីទុក្ខក្តៅក្រហាយ មានតែសេចក្តីសុខកាយសប្បាយចិត្ត ដូចសេចក្តីសុខសម្រាន្ត ដែលកើតមានដល់គ្រួសារនីមួយ ៗ ដូច្នោះឯង ៗ

សាធុសប្បុរសទាំងឡាយ អ្នកប្រាថ្នានូវសេចក្តីសុខសេចក្តីចម្រើន គប្បីព្យាយាមអប់រំបណ្តុះសារាណីយធម៌ ឲ្យដុះលូតលាស់នៅក្នុងសន្តានចិត្តជាប់ជានិច្ច, កាលបើមានសារាណីយធម៌ហើយ សេចក្តីសាមគ្គីព្រមព្រៀងគ្នា សេចក្តីស្រឡាញ់រាប់អានគ្នា ការយោគយល់អធ្យាស្រ័យគ្នា ក៏កើតមានឡើងដែរ, អស់លោក ក៏បានជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចម្រើន តាមសមគួរដល់ការប្រតិបត្តិតាមគោលធម៌ទាំង ៦ ប្រការ មានន័យដូចអាត្មាភាព បានពណ៌នាមក ដោយប្រការដូច្នេះឯង ៗ

សម្តែងមកក្នុងសារាណីយធម្មកថា ក៏ល្មមបញ្ចប់ត្រឹមប៉ុណ្ណេះ តែមុននឹងបញ្ចប់ អាត្មាភាព សូមថ្វាយនូវព្រះពរកុសល ដល់អគ្គសម្តេចព្រះ

មហាក្សត្រិយានី ព្រះអគ្គសាសនូបត្ថម្ភិកា និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គទ្រង់គង់នៅ ប្រកបដោយព្រះបរមសុខ ក្នុងសិរីរាជសម្បត្តិ អស់កាលយូរ ដើម្បីបានជាម្លប់ជាទីជ្រករគាំទ នៃប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ក្នុងព្រះរាជាណាចក្រតាំងមូល និងសូមឲ្យអស់លោកសាធុសប្បុរសទាំង-ឡាយ បានជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន គ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

ព្រះធម៌ទេសនា ក៏សន្មតថាចប់ត្រឹមប៉ុណ្ណោះឯង ។

(ឯវំ)

# សុខគវេសកកថា

វិទ្យុធម្មទេសនា ពីថ្ងៃទី ១៣ — ១០—៦៦

របស់ភិក្ខុ សួស.ជ្រិន សិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ ព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ អង្គនោះ (ព្រមទាំងព្រះធម៌ និង ព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ អាត្មាភាពសូមដកយកពុទ្ធភាសិត នៅក្នុងគម្ពីរធម្មបទ ត្រង់ទណ្ឌវគ្គ ដែលព្រះជិនស្រីទ្រង់ត្រាស់សំដែងអំពី " គោលបំណង របស់សត្វលោក ប្រាថ្នាចង់ឲ្យបានសុខដល់ខ្លួន ហើយក៏ប្រព្រឹត្តធ្វើនូវកម្មផ្សេងៗគ្នា " មកសំដែងដូចតទៅនេះ ៖

ព្រះពុទ្ធភាសិតនោះឯងសំដែងថា ៖

សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។
សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។

ប្រែថា : សត្វទាំងឡាយ សុទ្ធតែប្រាថ្នាសេចក្តីសុខ អ្នកណា ស្វែងរកសុខដើម្បីខ្លួន ហើយបៀតបៀនគេដោយអាជ្ញា អ្នកនោះ រមែងមិនបានសុខទេ ។

សត្វទាំងឡាយ សុទ្ធតែប្រាថ្នាសេចក្ដីសុខ អ្នកណា ស្វែងរក សុខ ដើម្បីខ្លួន ហើយមិនបៀតបៀនគេដោយអាជ្ញាទេ អ្នកនោះ តែងបានសុខទៅមុខ ។

អធិប្បាយថា : ព្រះលោកុត្តមាចារ្យ ទ្រង់មានព្រះប្រាជ្ញាបេស ឃើញការវែងឆ្ងាយ គ្រប់ឧបាយដែលជាហេតុនាំឲ្យបានសុខ ហើយ ទ្រង់បានប្រទានព្រះឱវាទដ៏មានសារៈនេះ ហាក់ដូចជាកញ្ចក់ដ៏ស័ក្ដិសិទ្ធិ មួយទុកឲ្យសត្វលោកឆ្លុះយល់ថា: ការបៀតបៀនអ្នកដទៃ ដើម្បីយក សុខមកដល់ខ្លួននោះ មុខជានឹងមិនបានសុខរហូតទៅទេ ។ អ្នកណា យកអាជ្ញាទៅបៀតបៀនអ្នកដទៃ គឺយកកម្លាំងច្រើន ទៅផ្ដាញអ្នកកម្លាំង តិចក្ដី យកយសសក្ដិសម្បត្តិ ឬ ដំបងទៅបៀតបៀនអ្នកដទៃក្ដី ដោយ សេចក្ដីយល់ថា ខ្លួនបានសុខនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងថា មិន មែនបានសុខរហូតជាដាច់ខាត, ដោយពិតនោះ ខ្លួនឯង នឹងត្រូវទទួល ទុក្ខវិញមិនខាន គឺអ្នកណា ធ្វើទុក្ខដល់គេ អ្នកនោះ នឹងត្រូវទទួលទុក្ខវិញ ព្រោះអំពើទាំងអស់ ឲ្យផលមិនហួសហេតុដើម ដូចការសាបព្រោះបណ្ដុះ ពូជ មានធញ្ញជាតិ និង រុក្ខជាតិជាដើម ទៅក្នុងផែនដី ត្រូវបានផល-ផលតាមពូជដើមនោះវិញ ។ ព្រះបរមសាស្ដាទ្រង់សម្ដែងថា :

យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ

កល្យាណការី កល្យាណំ បាបការី ច បាបកំ ។

បុគ្គលសាបព្រោះពូជបែបណា រមែងបានផលបែបនោះវិញ, អ្នកធ្វើល្អ រមែងបានល្អ, អ្នកធ្វើអាក្រក់ រមែងបានអាក្រក់ ។

ពុទ្ធភាសិតនេះបំភ្លឺថា : បុគ្គលអ្នកសាបព្រោះពូជដូចជាស្រូវ ឬដំណាំអ្វីមួយទៅក្នុងផែនដី បើស្រូវខ្សាយ ដល់បានផលមកបានជាខ្សាយ, បើដំណើប បានជាដំណើប, ដូង បានជាដូង, ស្វាយ បានជាស្វាយ យ៉ាងណាមិញ, ចំណែកអ្នកឲ្យទុក្ខដល់គេ មានបៀតបៀនដោយកាយជាដើម រមែងបានទទួលនូវទុក្ខដល់ខ្លួនវិញ; រីឯអ្នកឲ្យនូវសុខដល់គេទៀតសោត មានការផ្តល់អាហារនំចំណី ដល់មនុស្សសត្វដទៃ ឬជួយធ្វើការងារដោយកម្លាំងកាយ - វាចា ពុំនោះទេ ជួយដាស់តឿនឲ្យធ្វើការងារត្រូវ ដែលជាប្រភពនាំមកនូវសេចក្តីសុខ - ចម្រើន ដល់អ្នកធ្វើតាម, អ្នកនោះឯង រមែងបានទទួលនូវសេចក្តីសុខកាយ សប្បាយចិត្តពុំខានឡើយ ក៏ដូច្នោះដែរ ។

ហេតុដូច្នេះ ការឲ្យសុខឬទុក្ខដល់គេ រមែងបានផលតាមអំពើដើមនោះវិញ ដូចជាព្រះពុទ្ធដីកាដែលលើកអាងមកហើយនេះ, តែគួរជ្រាបថា ការដែលទទួលសុខឬទុក្ខ តបស្នងវិញនោះ ជួនកាលក៏បានផលដោយរូបដដែលវិញ ដូចវាយគេ ត្រូវគេវាយវិញ សម្លាប់គេ ត្រូវគេសម្លាប់វិញ យ៉ាងនេះជាដើមក៏មាន, ជួនកាល បានផលដោយប្រែរូបផ្សេងវិញ ដូចវាយគេ ឬ លួចគេ មិនត្រូវគេវាយ គេលួចវិញទេ

ត្រឡប់ត្រូវគេពិន័យជាប្រាក់កាស ឬដាក់គុក, តំនោះ កម្មនោះឯង ឲ្យផលក្លាយទៅជា ត្រូវទទួលឈឺថ្កាត់ វិនាសទ្រព្យសម្បត្តិ ដោយកណ្ដៀរគោរ កណ្ដុរកាត់ លង់ទូក ភ្លើងឆេះផ្ទះជាដើម ក៏មាន ។ នេះហើយជាផលប្រែរូប ប្លែកពីអំពើដើម ដែលគេច្រើនធ្វេសគំនិត មិនសូវនឹកដល់ ដោយចូលចិត្តថា ផលដែលបានមកខាងក្រោយនេះ មិនមែនជាប់ទាក់ទង ពីអំពើដែលបានធ្វើមុននោះទេ; តែដោយពិតនោះគឺ ជាបដជាប់តពីអំពើដែលខ្លួនធ្វើមុននោះជាហេតុ គ្រាន់តែប្រែរូបដើម ដូចទឹកដោះដែលរូតហើយ ផ្សរទៅក្នុងកាលធនៈច្រើនដង ទាំងកន្លងវេលាថែមទៀត ក៏ប្រែអំពីខីរៈ ទៅជាទធិ ជាសប្បិជាដើមពុំខានឡើយ ។

ធម្មតាបុថុជ្ជន ច្រើនមិនផុតពីគំនុំ ការដែលឲ្យទុក្ខគេហើយគេមិនតបវិញនោះ ក៏ព្រោះតែគេរកឱកាសមិនទាន់បាន បើតបវិញបានមុខជានឹងតបវិញពុំខាន; គួរគិតថា : មនុស្សម្នាក់ ៗ មិនសុទ្ធតែមានវាសនារហូត, មិនសុទ្ធតែឥតវាសនារហូតទេ, ពេលខ្លះ ក៏សុខសម្បូណ៌សប្បាយ, ពេលខ្លះ ក៏ខ្សត់ក្រក្តៅក្រហាយ, ព្រោះហេតុនោះបើប្រាថ្នាសុខដល់ខ្លួន គួរតែកុំឲ្យទុក្ខដល់គេ ខ្លាចក្រែងខ្លួនអស់វាសនាហើយអ្នកដែលខ្លួនឲ្យទុក្ខគេ ។ ត្រឡប់ជាមានវាសនាឡើងវិញនោះ គេដេញតាមគេជាន់កែង ព្រោះតែសុខទុក្ខក្នុងលោក ជាវិបរិណាមធម៌ ដូច្នេះ

បានជាមានភាសិតបុរាណថា “ អ្នកមានមិនដល់បីត អ្នកក្រមិនដល់បីជាន់ ” យ៉ាងនេះខ្លះ, “ វិលលើជាក្រោម ក្រោមជាលើ ដូចកង់គ្រាចកង់ផ្ចង់ ” យ៉ាងនេះខ្លះ, “ ទឹកឡើងត្រីស៊ីស្រមោច តែទឹកហោចស្រមោចស៊ីត្រី ” យ៉ាងនេះខ្លះ; ភាសិតទាំងនេះ ក៏ជាឧបាយទប់នូវអំពើ ដែលធ្វើអាក្រក់ដល់អ្នកដទៃ ព្រោះហេតុតែចង់បានសុខដល់ខ្លួន, ក៏ទុកជាភាសិតប្រាប់សេចក្ដីពិតមួយផ្លូវដែរ ។

ន័យមួយទៀត : អ្នកឲ្យទុក្ខគេ ព្រោះតែចង់បានសុខដល់ខ្លួននោះ វេលាដែលខ្លួនថយកំសទា នោះណាជាអ្នកដែលខ្លួនឲ្យទុក្ខនោះ មិនអាចតបវិញបានទេ ក៏គង់ខ្លួនត្រូវគេផ្ដន្ទា, ការដែលគេត្រូវជួយសង្គ្រោះបាន គេក៏មិនជួយ, ឧទាហរណ៍ ដូចជាខ្លួនត្រូវលង់ទឹក គេក៏មិនជួយស្រង់ ភ្លើងឆេះផ្ទះ គេក៏មិនជួយលត់ គឺខ្លួនអ្នកនោះ ក្លាយទៅជាមនុស្សឥតទីពឹង ទីងពឹងពាក់អ្នកដទៃមិនបាន ព្រោះខ្លួនជាមនុស្សជំពាក់ដោយពៀរជុំវិញខ្លួន; ហេតុនោះបានជាព្រះសម្ពុទ្ធទ្រង់សំដែងថា : “ អ្នកនោះឈ្មោះថាជាប់ពាក់ព័ន្ធដោយធម៌ជំពាក់គឺពៀរ រមែងមិនរួចពីពៀរ ” ។ អ្នកដែលឃើញភ័យក្នុងអនាគត ខ្លាចក្រែងគ្រោះនាមក្ដាមខ្យងទីងធ្ងង់មកដល់ខ្លួន ដូចជាព្រះពុទ្ធដីកា ដែលលើកអាងមកនេះ ហើយចៀសវាង មិនធ្វើទុក្ខដល់គេ រមែងបានទទួលនូវសេចក្ដីចំរើនដល់ខ្លួនពុំខានឡើយ ។

មនុស្សសត្វ ដែលត្រាច់រង្គាត់ក្នុងវដ្ដសង្សារ សុទ្ធសឹងតែប្រាថ្នារក

សេចក្ដីសុខគ្រប់ ៗ ប្រាណ, តែជួនណា ក៏រកបាន ជួនក៏ទេ ដោយហេតុគំនិតដែលគិតយល់ត្រូវ ក៏បានត្រូវ គឺបានសេចក្ដីសុខ, បើគិតខុសយល់ខុស ធ្វើការងារ ក៏បានខុស គឺបានសេចក្ដីទុក្ខ, គឺថា ការបានសេចក្ដីចម្រើននិងវិនាសនេះ មកពីមានប្រាជ្ញាល្អ និង ឥតប្រាជ្ញា ៗ ឯសេចក្ដីសុខ ដែលសព្វសត្វតែងត្រូវការនោះសោត ចែកចេញជាពីរប្រការ គឺកាយិកសុខ និង ចេតសិកសុខ បានដល់សេចក្ដីស្រួលរបស់កាយ និងសេចក្ដីសប្បាយរបស់ចិត្ត, តែថា សេចក្ដីសុខខ្លះ ប្រឡំដោយទុក្ខ ហៅថាសាមិសសុខ ៗ ធម្មតាសេចក្ដីសុខក្នុងលោកទាំងអស់ សុទ្ធសឹងប្រឡំដោយសេចក្ដីទុក្ខ បើមិនទទួលទុក្ខសិន មុខជានឹងមិនបានសេចក្ដីសុខទេ, ដូចជា ការធ្វើស្រូវ បើមិនប្រថុយឲ្យនឿយខ្លះ ដោយការភ្ជួររាស់ ឬនឿយគំនិតទេ ក៏រកស្រូវមិនបានឡើយ, បរិភោគផ្លែឈើ បើមិនបកសំបកចេញសិន ក៏អាស្រ័យសាច់មិនបាន ៗ គំនិតដែលយល់ថាឲ្យនឿយសិន ទើបបានសុខនេះ ជាគំនិតយល់ត្រូវគ្នាគ្រប់ជាតិ, ភាសិតខ្មែរយើងថា " ចង់ឆ្ងាញ់ឲ្យរកអន្ទូក ចង់ស្រណុកឲ្យនឿយ " ៗ ពុទ្ធភាសិតថា " វីរិយេន ទុក្ខមច្ចេតិ មកពីខំប្រឹង ទើបផុតសេចក្ដីទុក្ខបាន " យ៉ាងនេះខ្លះ, " ឧដ្ឋាតា វិន្ទតេ ធនំ មនុស្សខំស្វាហ៍ តែងរកទ្រព្យបាន " យ៉ាងនេះខ្លះ, " វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា ជាតិប្រុសត្រូវតែខំប្រឹង ឲ្យទាល់តែសម្រេច

ប្រយោជន៍បាន ” យ៉ាងនេះខ្លះ, កន្លែងខ្លះ ទ្រង់សម្តែងថា “ បើចង់បានសុខច្រើន ត្រូវតែលះសុខតិច ” ដោយគាថា ថា :

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ

ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។

បើឃើញថា សុខដ៏ទូលាយ ( បានមក ) ពីលះសុខតិចតួច អ្នកប្រាជ្ញកាលសម្លឹងរកសុខដ៏ទូលាយ ត្រូវតែលះសុខតិចតួចចេញ ។

អធិប្បាយថា : ដូចជាបាយមួយចំអែតដែលបុគ្គលបរិភោគហើយ អាចបំបាត់សេចក្តីក្រវល់ក្រវាយដោយសេចក្តីស្រេកឃ្លានបាន ឈ្មោះថា បានសេចក្តីសុខហើយ តែជាសុខយ៉ាងតិចទេ ព្រោះឲ្យសុខយ៉ាងយូរត្រឹម ១ ថ្ងៃ ១ យប់ប៉ុណ្ណោះ, បើលះភត្តនោះ ឲ្យទៅជាទាន ផលទាននោះ នឹងជូនឲ្យបានសោយសុខច្រើនជាតិ ។

ការដែលបណ្តែតបណ្តោយចិត្តឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ មានធ្វើបញ្ចោកជាដើម ក៏ឈ្មោះថាបានសេចក្តីសុខដែរ ព្រោះមិនទទឹងទាស់ទឹងបំណងរបស់ចិត្ត, តែជាសុខយ៉ាងតិច ព្រោះឲ្យសុខតែក្នុងមួយសន្ទុះរបស់ចិត្តប៉ុណ្ណោះ, តទៅ ត្រូវតែទទួលទុក្ខ, ដូចជាចោរដែលលួចទ្រព្យគេបានមួយរៀល ឬ ពីររៀលមក ចោរនោះឯង យល់ថាស្រួល ព្រោះគ្រាន់បើជាជាងធ្វើការឲ្យគេ ដែលបានថ្ងៃឈ្នួលមួយថ្ងៃត្រឹម ១០-២០ រៀល, តែបើពួកអ្នករាជការរដ្ឋបាល ចាប់ខ្លួនបានយកទៅដាក់គុក

ទឹនត្រូវទទួលទុក្ខយ៉ាងខ្លាំង ទៅលើសអំពីការដែលត្រាំធ្វើការស៊ីឈ្នួល តាមសម្មាអាជីវៈ ១០០ ឬ ១០០០ ភាគទៅទៀត, បានជាមានភាសិតថា " លួចគេបានរាគ្រាន់ តែគេទាន់រាក្រែល " ។ ការត្រាំអង្គុយធ្វើបរិកម្មភាវនាក្តី អង្គុយស្តាប់ធម៌ទេសនាក្តី ក៏ឈ្មោះថា បានសេចក្តីទុក្ខខ្លះដែរ ព្រោះពេយខ្លួន ឈឺចង្កេះ ស្រពន់ជើង មិនស្រួលដូចគេដេក ឬ ដើរលេងតាមទំនើងចិត្តនោះទេ តែនាំឲ្យកើតសេចក្តីសុខ ព្រោះបានចម្រើនសេចក្តីចេះដឹង យល់ការខុសត្រូវជ្រៅពក ។ ម្យ៉ាងទៀត សេចក្តីសុខចំពោះខ្លួនមួយ ឈ្មោះថា សុខតិច, សេចក្តីសុខដែលផ្សាយដល់ពួកវង្សញាតិត្រកូលផង ឈ្មោះថា សុខច្រើនជាង, សេចក្តីសុខកើតអំពីសុចរិត ដែលផ្សាយដល់ញាតិអ្នកនគរជាមួយគ្នា ឈ្មោះថា សុខធំទូលាយទៅទៀត, សេចក្តីសុខដែលផ្សាយជាសាធារណៈដល់មនុស្សជាតិដូចគ្នាលើផែនដីទាំងអស់ ឈ្មោះថា សុខធំជាទីបំផុត, ព្រោះហេតុនោះបានជា អ្នកមានប្រាជ្ញា កាលដែលគេសម្លឹងយកសុខធំទូលាយហើយ គេត្រូវតែលះសេចក្តីសុខតិចចេញ គេមិនគិតឲ្យបានសុខតែមួយខ្លួន – មួយត្រកូល – ឬមួយពួកប៉ុណ្ណោះទេ គេត្រូវតែផ្សាយសេចក្តីសុខដល់មនុស្សជាតិស្មើភាគគ្នាទាំងអស់ ។ មានពាក្យលោកប្រដៅទុកថា " កុំរែកប្រឡង់ចុះតែខ្លួនមួយ " ពុទ្ធភាសិតថា " ឯកាសី លកោត សុខំ ស៊ីតែម្នាក់ឯង រមែងមិនបានសេចក្តីសុខៈទ " ។

ហេតុអ្វីក៏លោកប្រដៅមិនឲ្យប្រើគំនិតបែបនេះ ? ព្រោះថា គំនិតបែបនេះ ជាគំនិតថោកថយ ជាគំនិតខ្ចី មិនមែនធ្វើសុខរបស់ខ្លួនឲ្យបានច្រើនឲ្យធំធ្លាយទូលាយទេ ដោយពិតនោះ គំនិតមិនទូលាយនេះឯង រមែងប្រមូលទុក្ខដាក់ខ្លួនវិញទេតើ ។

មនុស្សដែលយកសុខតែឯង ដល់វេលាបានទុក្ខ ក៏រងទុក្ខតែម្នាក់ឯង គ្មានអ្នកឯណាជួយទុក្ខឡើយ, មនុស្សដែលចែកសុខដល់គេផង គេគង់នឹងចែកសុខមកវិញ ។

ត្រកូលដែលមានបុព្វបុរសជាមួយគ្នា ហេតុអ្វីក៏គ្មានសេចក្ដីព្រមព្រៀងគ្នា, កូនចៅខ្លះ ក៏ដឹងគុណមាតាបិតាជីដូនជីតា ខ្លះក៏ត្រឡប់ជាអកតញ្ញូវិញ ? ការនេះក៏មកពីមាតាបិតា ជីដូនជីតាផ្សាយសេចក្ដីសុខដល់កូនចៅ មិនស្មើភាគគ្នាដែរ បានជាធ្វើចិត្តកូនចៅដែលជាប់មានសន្ដានល្អ ឲ្យត្រឡប់ជាមិនល្អទៅវិញ ។ គ្រូអាចារ្យ និងសិស្សានុសិស្សក៏ដូចគ្នា ដែលនាំឲ្យសិស្សខូចចិត្ត គិតខុសទៅវិញ ក៏មកពីគ្រូមានបក្ខភាគធម៌ខានបុព្វការីខ្លះដែរ, បុគ្គលដែលប្រព្រឹត្តមេត្តាជាគូ ៗ ទាំងអស់ ត្រូវឲ្យមានគុណធម៌ស្មើគ្នាទៅវិញទៅមក តាមមុខងាររៀងខ្លួន ទើបបានសេចក្ដីសុខ បើខ្វះគុណធម៌ម្ខាង ៗ ធម៌គូនោះឯង នឹងត្រឡប់ក្លាយទៅជាធម៌ពោលវិញ, គុណធម៌សម្រាប់ឲ្យបុគ្គលដែលប្រព្រឹត្តជាគូ ៗ ប្រតិបត្តិនោះ ដូចន័យដែលព្រះដ៏មានព្រះភាគជាម្ចាស់

ទ្រង់ត្រាស់សម្តែង ធម៌សម្រាប់មាតាបិតា និង បុត្តធីតា, អាចារ្យ និងសិស្ស, ស្វាមី និង ភរិយា, មិត្រ និង មិត្រ, ខាងចៅហ្វាយ និង ខ្ញុំកំដរ, សមណព្រាហ្មណ៍ និង គ្រហស្ថ ថាត្រូវឲ្យប្រព្រឹត្តធម៌យ៉ាងនោះ ៗ ដល់គ្នាទៅវិញទៅមក ។

អ្នកដែលប្រព្រឹត្តធម៌ពាសក្នុងមុខងាររបស់ខ្លួននោះ គួរជ្រាបរឿងក្នុងគតិលោក ដែលដំណាលអំពីលោកគ្រូ ឆាន់ត្រីកន្ទ្រប់ ងាប់ទឹងក្របីវ័ធ ព្រោះផែនដីក្រឡាប់, រឿងនោះឯង ជាភស្តុតាងមួយបំភ្លឺគំនិតកុំឲ្យអាចារ្យ និង សិស្សយកតម្រាប់តាម ។ លោកអ្នកដែលធ្វើជាមេបាលើគេ គួរប្រព្រឹត្តខ្លួនកុំឲ្យធ្លាក់ក្នុងក្បួនលោកនីតិ៍ដៀលថា :

ន សេវេ ផរុសំ សាមិំ ន ច សេវេយ្យ មច្ឆរឹ

តតោ អប្បគណ្ហំ សាមិំ នេវ និគ្គហិតំ តតោ ។

កុំសេពម្ចាស់គ្រោតគ្រាតជាតិប្រវ័ញ្ច, កុំសេពម្ចាស់កំណាញ់កកាញ់ខុន, កុំសេពម្ចាស់មិនលើកតម្កល់គុណ, កុំសេពម្ចាស់យកបុណ្យមកសង្កត់ ។

សេចក្តីប្រព្រឹត្តិល្អដល់គ្នាទៅវិញទៅមក ដូចពណ៌នាមកនេះ ជាឧបាយឲ្យកើតសេចក្តីសុខមួយផ្លូវដែរ, លោកអ្នកប្រាថ្នាសុខទូលាយគួរប្រព្រឹត្ត ។

អ្នកដែលមានចំណេះវិជ្ជាឈ្មោះថា បានសេចក្តីសុខយ៉ាងប្រសើរ

ព្រោះវិជ្ជាអាចឲ្យសម្រេចប្រយោជន៍ច្រើនយ៉ាង យោងខ្លួនប្រាណ ឲ្យបានឃ្លាតពីកសត់ទុគ៌ត បំភ្លឺគំនិតឲ្យយល់ត្រូវ យល់ល្អ ជាសម្បត្តិយ៉ាងស្រាលអាស្រ័យនៅនឹងខ្លួន ទៅទីណា ៗ មិនបាច់រែកសែងវេចខ្ចប់ ឬ ព្រួយដោយការទុកដាក់ឡើយ ចោរលួចយកក៏មិនបាន ជាវិជ្ជាឲ្យសុខទាំងឥធលោក និងបរលោក, សមដូចជាកាសិតក្នុងលោកនីតិថា:

សិប្បសមំ ធនំ នត្ថិ សិប្បំ ចោរា ន គយ្ហរេ
ឥធ លោកេ សិប្បំ មិត្តំ បរលោកេ សុខាវហំ ។

មានទ្រព្យមិនស្មើនឹងមានវិជ្ជា វិជ្ជាចោរប៉ងលួចយកពុំបាន
វិជ្ជាទុកជាមិត្រសន្តាន ក្សាន្តក្នុងឥធលោក យោគដល់បរលោក ។

វិជ្ជាជារបស់មានប្រយោជន៍ ឲ្យសេចក្ដីសុខដល់ខ្លួនប្រាណយ៉ាងនេះ បានជាត្រូវខំប្រឹងរៀនសិក្សា មិនត្រូវខ្ជិលទំលាក់ក្រាញថា ខ្លួនចាស់ ខ្លួនរៀនមិនចេះ ព្រោះប្រាជ្ញាអាប់នោះទេ រៀនមួយថ្ងៃ ឬ ពីរថ្ងៃបានត្រឹមតែមួយម៉ាត់ យូរ ៗ ទៅគង់បានច្រើនម៉ាត់ កើនចំណេះវិជ្ជានោះច្រើនឡើង ៗ ជាលំដាប់ ហើយអាចស្វែងរកនូវសេចក្ដីសុខបានដោយងាយ ៗ ដូច្នេះ សេចក្ដីសុខទាំងអស់ នោះក្នុងលោកនេះ ឬ លោកខាងមុខក៏ដោយ មនុស្សគ្រប់ប្រភេទ ដែលចង់បានពល់ ៗ គ្នានោះ ត្រូវតែរកវិជ្ជា, រកទ្រព្យសម្បត្តិ ប្រកបដោយសម្មាអាជីវៈ, មានវិរិយៈ មិនដាច់, សមាគមជាមួយលោកអ្នកសប្បុរស, កាន់ខន្តិធម៌,

បណ្តេញសេចក្តីក្រោធឲ្យចេញពីខន្ធសន្តាន, សន្សំយកបុណ្យកុសល, ញ៉ាំងចិត្តកុំឲ្យធ្វើខ្ញុំតណ្ហា, មានហិរិ ឱត្តប្បៈ សតិសម្បជញ្ញៈ, កុំសេពគប់ជនពាល, ត្រូវប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ជឿកម្មផល និងជាពិសេសទៅទៀត កុំបៀតបៀនដល់គ្នីគ្នា ចេះគោរពច្បាប់សម្រាប់មនុស្សសត្វ ដោយមិនយកអាជ្ញាមកគម្រាម កំហែងអ្នកដទៃ ហើយត្រូវពិចារណា រួចអនុវត្តទៅតាមអត្ថន័យ នៃពុទ្ធភាសិត ដែលអាត្មាភាពលើកយកមកសំដែងក្នុងពេលនេះឯង ថា :

សុខកាមានិ ភូតានិ សត្វទាំងឡាយសុទ្ធតែប្រាថ្នាសេចក្តីសុខ
យោ ទណ្ឌេន វិហឹសតិ អ្នកណាបៀតបៀនគេដោយអាជ្ញា
អត្តនោ សុខមេសានោ (ព្រោះតែ) ស្វែងរកសុខដើម្បីខ្លួន
បេច្ច សោ ន លភតេ សុខំ អ្នកនោះមិនបានសុខទៅមុខទេ ៗ
សុខកាមានិ ភូតានិ សត្វទាំងឡាយសុទ្ធតែចង់បានសុខ
យោ ទណ្ឌេន ន ហឹសតិ អ្នកណាមិនបៀតបៀនគេដោយអាជ្ញា
អត្តនោ សុខមេសានោ (ព្រោះតែ) ស្វែងរកសុខដើម្បីខ្លួន
បេច្ច សោ លភតេ សុខំ អ្នកនោះរមែងបានសុខទៅមុខ ៗ

ការសំដែងធម៌ទេសនា ផ្សាយតាមវិទ្យុជាតិ ក្នុងឱកាសនេះ មិនទាន់ចប់សព្វគ្រប់ទេ តែសូមបញ្ចប់ដោយសេចក្តីសង្ខេប តាមកាលវេលាតែប៉ុណ្ណេះចុះ ។ មុននឹងបញ្ចប់នូវធម្មទេសនានេះ អាត្មាភាពសូម

លើកយកអានិសង្សនៃធម្មទេសនានេះទាំងស្រុង ថ្វាយចំពោះសម្តេចព្រះសង្ឃរាជ សូមព្រះអង្គទ្រង់គង់ជាសុខ មានព្រះជន្មវស្សាជាងរយឆ្នាំ ដើម្បីជាម្លប់នៃព្រះសង្ឃ ឧបាសក - សិកា ទាំងអស់ នាំគ្នាកាន់ព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿង គ្រប់ទេសៈ កាលៈ ដរាបដល់គ្រប់ប្រាំពាន់ព្រះវស្សា ។ ម្យ៉ាងទៀត សូមលើកយកអានិសង្សនេះ ថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋ ដែលជាព្រះអគ្គមគ្គុទ្ទេសក៍ដំបូង ទ្រង់កាន់ចង្កូតនាវាកម្ពុជា បើកបរឆ្ពោះទៅរកសុខសន្តិភាព, សូមព្រះអង្គទ្រង់គង់ប្រថាប់ជាសុខ មានព្រះជន្មាយុយឺនយូរ ជាងរយឆ្នាំ បើសត្រូវជិតឆ្ងាយប៉ងពិឃាតព្យាបាទ ដោយរបៀបជាហេតុបច្ច័យណាមួយក្តី សូមឲ្យលាយក្លាយមកជាមិត្រ ដើម្បីនឹងបានព្រះអង្គ គង់ជាម្លប់នៃប្រជាពលរដ្ឋខ្មែរទាំងកម្ពុជាសកល, ព្រមទាំងព្រះរាជវង្សានុវង្ស នាហ្មឺនសព្វមុខមន្ត្រីគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋទាំងមូល ទាំងព្រះសង្ឃទាំងគ្រហស្ថ សូមបានប្រកបដោយវិបុលសុខសិរីសួស្តីជយមង្គលគ្រប់ប្រការ កុំបីក្លាយទៅជាបការៈដទៃឡើយ ។

ធម៌ទេសនា ដែលអាត្មាភាព បានសម្តែងអំពី " សុខគវេសកកថា " គង់វេលានេះ សូមបញ្ចប់ដោយសង្ខេប តាមសមគួរដល់កាលវេលា តែប៉ុណ្ណោះឯង ដំ ។

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ព.ប.

## ប្រវត្តិ

### ព្រះឧត្តមមុនី អ៊ុម-ស៊ូរ

(ដកយកប្រវត្តិដែលលោក ចាប-ពិន បានរៀបរៀង ចុះក្នុងខាងដើមសៀវភៅ អវសានកិច្ច របស់ព្រះឧត្តមមុនី អ៊ុម-ស៊ូរ)

ព្រះតេជព្រះគុណព្រះឧត្តមមុនី អ៊ុម-ស៊ូរ មាតា នាម ទេស បិតា នាម អ៊ុម លោកកើតនៅភូមិកន្ទ្រាមអក ឃុំកន្ទ្រាមអក ខេត្តព្រៃវែង ក្នុងពុទ្ធសករាជ ២៤២៤ ឆ្នាំម្សាញ់ត្រីស័ក ខែផល្គុន ១៤ រោច ថ្ងៃពុធ វេលាម៉ោង ៦ ព្រឹក ។

កាលលោកជាកុមារ បានសិក្សាអក្សរនិងលេខក្នុងសំណាក់បិតា ដរាបដល់ចេះមើល ចេះសរសេរបាន ។ លុះអាយុ ១៦ ឆ្នាំ ចូលទៅនៅក្នុងសំណាក់លោកគ្រូព្រះធម្មតេនវង្ស ទៀង ចៅអធិការវត្តសិរីសាគរ ស្រុកត្របែក ជាមេគណខេត្តបាភ្នំ សិក្សាធម៌វិន័យអស់ ១ ឆ្នាំ បម្រុងនឹងបួស, ដល់អាយុ ១៧ ឆ្នាំ បព្វជ្ជាជាសាមណេរ ។



ព្រះឧត្តមមុនី អ៊ុម.ស៊ូរ

លុះបព្វជ្ជាហើយ ក្នុងវស្សាទី ១ បានមើលគម្ពីរដីកាក្បួនច្បាប់ជាច្រើន គឺ បានមើលគម្ពីរទេសជាតក ព្រះអភិធម្ម ៧ គម្ពីរ បានចាសោត្រ ត្រៃ ៣ ដីកាពាហុំ កាណក់ះបាលី និងទន្ទេញបាលីបាតិមោក្ខចាំស្ទាត់ រត់មាត់ដល់ចប់ ។

វស្សាទី ២ លោកគ្រូព្រះធម្មគេនវង្សអធិបូធម្មទៅ , សាមណេរស៊ីរ បានទៅចម្លងសាមណេរវិន័យ និងបព្វសិក្ខាពីលោកគ្រូសូត្រ យឹម វត្តពោធិ៍លាស់ ក្នុងខេត្តជាមួយគ្នា យកមកបបួលភិក្ខុសាមណេរឲ្យរៀនសូត្រ ។

វស្សាទី ៣ រៀនធម៌សមណៈពីលោកគ្រូអាចារ្យ ប៉ែន ជាឧបាសក នៅភូមិកំពង់ស្វាយ ឃុំខេត្តជាមួយគ្នា ។

អាយុ ១៩ ឆ្នាំ សឹកទៅជាឧបាសក រក្សាឧបោសថសីលអស់១ឆ្នាំ ។

អាយុ ២១ ក្នុងឆ្នាំឆ្លូវត្រីស័ក ពុទ្ធសករាជ ២៤៤៤ បួលមកឧបសម្បទាជាភិក្ខុ ក្នុងវត្តសិរីសាគរវិញ មានលោកគ្រូព្រហ្មសរោ ឃួន ចៅអធិការវត្តពោធិលាស់ ជាឧបជ្ឈាយ៍ លោកគ្រូបញ្ញាសទ្ធម្មោ មាស ចៅអធិការវត្តសិរីសាគរ និងលោកគ្រូសូត្រ យឹម ចន្ទកេសរោ វត្តពោធិ៍លាស់ ជាកម្មវាចាគុស្សាវនាចារ្យ បាននាមឆាយាជា ធម្មវិនយ-រក្ខិតោ ។

លុះឧបសម្បទាហើយ ក្នុងវស្សាទី ១ បានរៀនបាតិមោក្ខប្រែ បត្ថ-

បរិសុទ្ធិសីល និងធម៌ភាណវារៈ ចេះចាំស្ទាត់ ហើយបបួលភិក្ខុចាស់ៗ ក្នុងវត្ត ហាត់សូត្រធម៌ឲ្យត្រឹមត្រូវ លុះហាត់ធម៌ហើយ រៀនសមថកម្មដ្ឋានថែមទៀត ។

វស្សាទី ២ លាលោកគ្រូចៅអធិការចេញទៅរៀនព្រះត្រៃបិដកឯវត្តព្រែកបាំង ភូមិកំពង់ហ្លួង ស្រុកពញាឮ ខេត្តកំពង់ស្ពឺ នៅក្នុងសំណាក់លោកគ្រូព្រះវិនរ័ត ឃុប កាលជាអាចារ្យនៅឡើយ បានរៀនមូលកច្ចាយនៈ ពីលោកគ្រូអាចារ្យ សម ជាឧបាសក នៅភូមិកំពង់ហ្លួង ។

វស្សាទី ៣ ត្រឡប់មកភ្នំពេញ នៅក្នុងសំណាក់លោកគ្រូអាចារ្យអ៊ួង វត្តឧណ្ណាលោម បានរៀនមូលកច្ចាយនៈ ពីលោកគ្រូអាចារ្យសយ ជាតិសៀម រៀនធម្មបទពីលោកគ្រូអាចារ្យអ៊ួង ។

វស្សាទី ៤ ត្រឡប់ទៅនៅរៀនឯវត្តសិរីសាគរវិញ. អស់ ៣ វស្សា ដោយជំនាន់នោះមានលោកគ្រូអាចារ្យ ឌុយ កាលនៅជាឧបាសកមកបង្ហាញក្នុងវត្តនោះ ។ គ្រានោះ លោកមានបំណងល្មមបង្ហាញគេបាន ក៏បានជួយបង្ហាត់មូលកច្ចាយនៈ និងធម្មបទគេទៅ ។

វស្សាទី ៧ ទី ៨ ទី ៩ ត្រឡប់មកនៅភ្នំពេញ បានរៀនមង្គលត្ថទីបនី និងវិសុទ្ធិមគ្គ ពីលោកគ្រូអាចារ្យ អ៊ួន បានរៀនបញ្ចប់មង្គលត្ថទីបនី និងគម្ពីរឯទៀតខ្លះ មានបឋមសមន្តបាសាទិកាជាដើម ពីព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោង ។

វស្សាទី ១០ ដល់ទី ១៦ លោកនៅធ្វើជាអាចារ្យបង្រៀននៅវត្តសិរីសាគរ ។ លុះទៅនៅវត្តនោះ សម្តេចព្រះមហាសង្ឃរាជ ( ទៀង ) ទ្រង់បង្គាប់ឲ្យបង្ហាត់ធម៌គាណការៈ ដល់ភិក្ខុសាមណេរក្នុងខេត្តបាភ្នំ ចំនួន ២៨ វត្ត មានវត្តពោធិ៍លាស់ជាដើម ។

វស្សាទី ១៧ ព្រះមហាវិមលធម្ម ថោង ឲ្យមកនៅភ្នំពេញ ក៏បានតាំងលោកជាព្រះគ្រូវិមលបញ្ញា ក្នុងឆ្នាំដែលព្រះរាជការតាំងសាលាបាលីជាន់ខ្ពស់ នៅវិហារព្រះកែវ ។ កាលនោះ បានជួបជុំជាមួយនឹងព្រះសិរីសម្មតិវង្ស អ៊ែម ចាងហ្វាងសាលាបាលីជាន់ខ្ពស់ កាលនៅជាព្រះញាណបវរវិជ្ជា ព្រះសាសនសោភ័ណ ណាត ជាព្រះគ្រូសំសត្ថា ព្រះវិសុទ្ធិវង្ស គាត ជាព្រះគ្រូសំវិជ្ជានៅឡើយ ព្រមទាំងលោកអាចារ្យឯទៀត ៗ ជាច្រើន ពិនិត្យមើលគម្ពីរ បាលី អដ្ឋកថា យោជនា ជាច្រើន សង្កេតកែផ្លូវប្រតិបត្តិរបស់ភិក្ខុសាមណេរឲ្យត្រឹមត្រូវ តាមពុទ្ធបញ្ញត្តិនិងពុទ្ធានុញ្ញាត ; រួចហើយក៏ព្រានសេចក្តីរៀបរៀងជាសៀវភៅទាំងឡាយ មានសាមណេរវិន័យ បព្វជ្ជាខន្ធកៈ និងគិហិប្បដិបត្តិជាដើម ចែកសិស្សានុសិស្សរៀនសូត្រ ។

វស្សាទី ១៨ លោកមហាឥស្សរ កេត អធិបតីសាលាសានទិទ្ធិជ័យ បាននិមន្តទៅសម្តែងធម៌ឯផ្ទះលោក ។ កើតសេចក្តីជ្រះថ្លា គាពជនាឲ្យទៅពន្យល់ធម៌វិន័យដល់ពុទ្ធបរិស័ទ ឯវត្តជយនារី ( ចុងកោះសំពេង ) ខេត្ត

កំពង់ចាម ដែលជាស្រុកកំណើតរបស់លោកមហាឥស្សរៈនោះ; ព្រះអាចារ្យ ស៊ូរ លោកនៅនៅវត្តនោះអស់ ២ ខែកន្លះ ត្រឡប់មកនៅភ្នំពេញវិញ; ក្នុងឆ្នាំនោះ ព្រះករុណាម្ចាស់ជីវិត និងរាជការប្រូតិកតូពក៍ បង្កើតព្រះរាជបណ្ណាល័យ ជាទីតំកល់ក្បួនច្បាប់ ដើម្បីបោះពុម្ពសៀវភៅធម៌វិន័យពុទ្ធសាសនា គឺតាំងលោកជាអាចារ្យផ្ទៀងធម៌វិន័យក្នុងវ៉ានោះ ។ លំដាប់នោះ រាជការត្រូវការឲ្យមានធម៌វិន័យជាច្បាប់សម្រាប់ពុទ្ធបរិស័ទរៀនសូត្រដើម្បីប្រតិបត្តិត្រឹមត្រូវតាមពុទ្ធសាសនា គឺយកសៀវភៅធម៌អាចារ្យដែលលោកព្រាងទាំងនោះ មានគិហិប្បដិបត្តិជាដើម មកបោះពុម្ពផ្សាយតាមលំដាប់ ។

តាំងពីវស្សាទី ១៩ រៀងទៅដល់ទី ៣៥ លោកបានរៀបរៀងសៀវភៅជាច្រើនគឺ គិហិប្បដិបត្តិ, អភិធម្មត្ថសង្គហៈ, មិលិន្ទប្បញ្ហាទីមួយ, មិលិន្ទប្បញ្ហាទីពីរ, ទសបារមីកថា, មាតាបិតុបដ្ឋានកថា, សំវេជនីយធម៌, ១០០ គាថា, មរណានុស្សតិកម្មដ្ឋាន, រតនប្បភា ( ពន្លឺកែវ ), បានជួយបង្ហើយអរិយសច្ចកថា របស់ព្រះមហាវិមលធម្ម ថោង ចាងហ្វាងសាលាបាលីជាន់ខ្ពស់, បានយកធម៌ៈផ្សេង ៗ ដែលលោកអាចារ្យ ចាប-ពិន និង អាចារ្យ គឹម-អាន រៀបរៀង មកប្រមូលជាសៀវភៅមួយឡើងឈ្មោះថា សុភាសិតប្បកាសិនី, បានប្រជុំអស់លោកអ្នកចេះបាលីស្ទាត់ៗ ផ្ទៀងផ្ទាត់ធម៌ភាណវារៈបាលី រហូតដល់បានបោះពុម្ព

សម្រេច, បានប្រជុំលោកអាចារ្យ ប្រែបាលីគម្ពីរវិសុទ្ធិមគ្គជាសម្រាយ បានចប់ពីរនិទ្ទេស គឺសីលនិទ្ទេស និងសមាធិនិទ្ទេស បានចាត់ការឲ្យចម្លងបាលីធម្មបទដ្ឋកថាបុព្វភាគ បម្រុងនឹងបោះពុម្ព, បានចាត់ការឲ្យចម្លងបាលីវិសុទ្ធិមគ្គមួយចប់បម្រុងនឹងបោះពុម្ព ។ ល ។

ក្នុងពុទ្ធសករាជ ២៤៧២ រាជការបានបង្កើតពុទ្ធសាសនបណ្ឌិត្យ ឲ្យមានក្រុមជំនុំច្រើនរូប ប្រែព្រះត្រៃបិដកពីបាលីមកជាសម្រាយ បានតាំងលោកជាអធិបតីនៃ អ្នកចាត់ការឲ្យក្រុមជំនុំប្រែព្រះត្រៃបិដក និងត្រួតត្រាកិច្ចការគ្រប់យ៉ាង ។ ក្នុងឱកាសនោះ រាជការបង្កើតឲ្យមានធម្មទេសនាប្រដៅពួកទាហានទាំងក្រុមក្សេត្រស្រុក និងក្រុមពិជ័យសង្គ្រាម, បានចាត់និមន្តលោកអាចារ្យទាំងឡាយក្នុងសាលាបាលី និងក្រុមជំនុំព្រះត្រៃបិដកឲ្យទៅសម្តែងធម៌គ្រប់ខេត្ត. ចំណែកអង្គលោកត្រូវទៅសម្តែងជាដំបូងក្នុងតំបន់នានា ដូចខាងក្រោយនេះ គឺ ទីក្រុងភ្នំពេញ, ព្រៃនគរ, វត្តព្រៃឆ្លាក់ ( ស្វាយរៀង ), វត្តសិរីសាគរ ( កំពង់ត្របែក ព្រៃវែង ) វត្តដំណាក់ ( សៀមរាប ), វត្តកំពង់ធំ ( កំពង់ធំ ), បន្ទាយទាហាន ( កំពង់ចាម ), វត្តកំពង់បាយ ( កំពត ), វត្តម្រំ ( កំពង់ស្ពឺ ), បន្ទាយទាហាន ( បាត់ដំបង ), បន្ទាយទាហាន ( ពោធិ៍សាត់ ), បន្ទាយទាហាន ( កំពង់ឆ្នាំង ) ។

វស្សាទី ៣០ ពុទ្ធសករាជ ២៤៨៣ ព្រះករុណាម្ចាស់ជីវិត ទ្រង់

ព្រះរាជទានកិត្តិយសជាព្រះឧត្តមមុនី ទីពជាគណៈពិសេស ។

ក្នុងរវាង ៨ វស្សាគិតតាំងពីវស្សា ២៧ ដល់ ៣៤ លោកបានទទួលគ្រឿងឥស្សរិយយស ( មេដាយ ) ៤ ( ៥ ទាំងបដិញ្ញាណ១ ) គឺ ១ មុនីសារាភរណ៍ អំពីព្រះករុណាម្ចាស់ជីវិតព្រះចៅក្រុងកម្ពុជា, ២ – អស្សរិទ្ធិ អំពីព្រះករុណាម្ចាស់ជីវិតព្រះចៅក្រុងកម្ពុជា, ៣ - អស្សរិទ្ធិ អំពីព្រះចៅក្រុងហ្លួងព្រះបាង ( លាវ ) ៤- អូហ្វីស្សេដាកាដេមី អំពីរាជការបារាំងសែស, ៥- បដិញ្ញាណ អំពីមេវត្តក្រុងកម្ពុជា ដោយគុណដែលលោកបានជួយឧបត្ថម្ភព្រះពុទ្ធសាសនានិងការសិក្សាវិជ្ជាខ្មែរឲ្យចម្រើន ។

លោកបានចាត់ចែងធ្វើបុញ្ញកិរិយាវត្ថុជាច្រើន ដូចរៀបរាប់ដោយសង្ខេបតទៅនេះ គឺ បានសាងព្រះពុទ្ធរូបធំ, សាងសាលា, សាងកុដិ, សាងចេតិយ, ជីកស្រះ ក្នុងវត្តសំពេង ស្រុកត្របែក ។

ឯបុញ្ញកិរិយាវត្ថុ ដែលលោកបានសាងក្នុងវត្តសិរីសាគរ កំពង់ត្របែកនោះដូច្នេះ គឺបានជួយបង្ហើយវិហារនិងសាងកុដិ, បានសាងបល្ល័ង្កតំកល់ព្រះពុទ្ធរូប, បានធ្វើបុណ្យបញ្ចុះសីមា, បានសាងព្រះត្រៃបិដកអក្សរសៀម១ចប់, បានសាងចេតិយមាសតំកល់ព្រះសារីរិកធាតុ, បានសាងទូ ២ តំកល់ព្រះត្រៃបិដក, បានសាងមន្ទីរធម្មសភា, បានធ្វើបុណ្យឆ្លងធម្មសភានិងសម្ពោធសាលាបាលី, បានសាងចេតិយប្រាក់កំពូលមាសដាំត្បូងតំកល់ព្រះសារីរិកធាតុ និងអរហន្តធាតុ, បានសាងព្រះពុទ្ធរូប ២

ព្រះអង្គ គូរផ្ទាល់នឹងផែនកញ្ចក់ដាំខ្សែ, បានសាងព្រះត្រៃបិដកបាលីសម្រាយអក្សរខ្មែរ ១ ចប់, បានសាងគម្ពីរបាលីស្លឹករឹតជាច្រើន មានមូលកច្ចាយនៈ និងធម្មបទដ្ឋកថាជាដើម បានសាងសៀវភៅធម៌ជាភាសាបាលីអក្សរសៀម អក្សរខ្មែរ មានសៀវភៅវិសុទ្ធិមគ្គ, អភិធានប្បទីបិកា, សារត្ថសង្គហៈ, អភិធម្ម, មិលិន្ទបញ្ហា និងមហាវេស្សជាដើម, បានណែនាំមាតាបិតាឱ្យក្សមាទោសថសីល, បានក្សាជម្ងឺមាតាបិតា, វេលាមាតាបិតាអនិច្ចកម្ម បានធ្វើបុណ្យឈាបនកិច្ច, ក្នុងកាសបុណ្យនោះ បានចែកសៀវភៅអភិធម្មត្ថសង្គហៈ ១០០ ក្បាលជាធម្មបណ្ណាការ ។ល។

លោកបានជួយទំនុកបម្រុងវត្ត ដោយបានចាត់លោកអាចារ្យឲ្យទៅបង្ហាញព្រះបរិយត្តិធម៌នោះក៏ច្រើន គឺ វត្តស្វាយព្រហូត ( ស្វាយរៀង ) វត្តសិរីសាគរ ( កំពង់ត្របែក ), វត្តសំពេង, វត្តពោធិរតន៍, វត្តស្វាយឧត្តម, វត្តកាសី ( ព្រៃវែង ) វត្តស្វាកែត, វត្តទ្រមល់, វត្តមុនីសាគរ, វត្តជ្រៃ ( បឹងត្រាំ ) ស្រុកកៀនស្វាយ, វត្តកំពង់ចន្ទុះ, វត្តកំពង់ឫស្សី, វត្តជយនាទី ( ចុងកោះសំពេង ), វត្តឧត្តមសាគរ ( រលាច ), វត្តចុងកោះសូទិន ( កំពង់ចាម ), បានជួយផ្តើមទំនុកបម្រុងវត្តគេនាកម ( ស៊ុងកៀក ) ជាវត្តរបស់ពួកជនជាតិយួន ដែលចូលមកកាន់ពុទ្ធសាសនាបែបខ្មែរ (១) ។

---

១ តាំងពីដើមដំបូងមកទល់ត្រឹមនេះ រៀបរៀងតាំងពីព្រះកេរ្តិ៍ព្រះគុណព្រះឧត្តមមុនី គង់ព្រះជន្មនៅឡើយ ដោយបានសួរបញ្ជាក់ចំពោះអង្គលោកសព្វគ្រប់ ។

ព្រះតេជព្រះគុណព្រះឧត្តមមុនី លោកបួសជាសាមណេរបាន ៣ វស្សា ជាភិក្ខុបាន ៣៩ វស្សា, ចាប់ដើមតាំងពីបួសមក លោកព្យាយាមធ្វើសេចក្ដីប្រតិបត្តិជាប្រយោជន៍យ៉ាងច្រើនដល់ខ្លួនលោកផង ដល់ជនដទៃផង ដល់ពុទ្ធសាសនាផង ៗ សេចក្ដីព្យាយាមរបស់លោកនេះហើយ ដែលនាំឲ្យស្រុកខ្មែរបែរមុខទៅរកសេចក្ដីចំរើន ដោយការចេះដឹងនិងការប្រតិបត្តិធម៌វិន័យត្រឹមត្រូវតាមពុទ្ធសាសនា ៗ តាមដែលគេសង្កេតដោយហ្មត់ចត់ ឃើញថា សេចក្ដីព្យាយាមដែលលោកពេញព្រះទ័យជាងគេបំផុតក្នុងជីវិតរបស់លោក គឺព្យាយាមរៀន ព្យាយាមប្រតិបត្តិធម៌វិន័យឲ្យត្រឹមត្រូវតាមរបៀបពុទ្ធសាសនា និងព្យាយាមសរសេររៀបរៀងតែងធម៌អាថ៌ដែលជាហេតុនាំឲ្យកើតសង្វេគ និងធម៌បរមត្ថមានអត្ថដ៏ជ្រាលជ្រៅដូចយ៉ាងអនត្តាធម៌ និងនិព្វានធម៌ជាដើម ជាធម៌ល្អិតដែលអ្នកផងច្រើនយល់គំនិតគិតមិនសូវឃើញ មិនសូវមានអ្នកណាអធិប្បាយឲ្យងាយស្ដាប់បាន លោកក៏ខំតន់មើលគម្ពីរនិងរិះគិតរាល់តែឃើញពិត ហើយបានធ្វើជាសៀវភៅ ១ ឲ្យឈ្មោះថា រតនប្បភា ( ពន្លឺកែវ ) បោះពុម្ពផ្សាយក្នុងព្រះរាជបណ្ណាល័យកម្ពុជា ៗ នៅមានសៀវភៅ ១ ទៀត គឺសៀវភៅអវសានកិច្ច ដែលបោះពុម្ពផ្សាយ នៅវិជ្ជាឋាននេះដែរ ដែលលោកអធិប្បាយអំពីអវិជ្ជា, សង្ខារ, វិញ្ញាណ, នាមរូប ៗ សៀវភៅនេះហើយ ដែលជាស្នាព្រះហស្តក្រោយបំផុត ក្នុងចំណោមសៀវភៅដែលលោកតែងតាំងតួង

តាំងជាសៀវភៅដែលលោកចំគ្រងរង្គើក្នុងពេលមានអាពាធខ្លះហើយ តែនៅស្រាល ៗ ល្មមធ្វើបាន លោកតែងមិនខានចប់សព្វគ្រប់ កំពុងតែសម្រួលបញ្ចប់ផិតចប់ក៏មានអាពាធក្ដៅស្រៀវស្រាញ់ ឈឺសីសៈ, ក្អក, ឈឺកយ៉ាងធ្ងន់ មកកាត់ការងាររបស់លោកឲ្យអាក់ខាន ឲ្យកាន់ដីទៅផង ប៉ុកកាមិនកើត; អាពាធនុះចេះតែធ្ងន់បន្តិចម្ដង ៗ ឥតស្រាកស្រាន្ត ទោះរកពេទ្យយ៉ាងពូកែវិសេស មកអភិបាលរក្សាយ៉ាងណា ក៏មិនធូរថយ ៗ ក្នុងវេលាលោកមានអាពាធ តាំងពីស្រាលដល់ធ្ងន់នោះ លោកមានអជ្ឈាស្រ័យស្រឡាញ់សេចក្ដីស្ងាត់ លោកឃាត់មិនឲ្យភិក្ខុសាមណេរ ឧបាសកឧបាសិកា ចូលទៅជិតលោកក្នុងទីដែលបិទបាំងដោយខ្សប់ខ្សែរនោះឡើយ, លុះតែភិក្ខុអ្នកចេះបម្រើជម្ងឺទើបចូលទៅជិតបាន, សូម្បីភិក្ខុអ្នកចេះបម្រើជម្ងឺនោះសោត ក៏ឲ្យចូលយ៉ាងច្រើនបំផុតត្រឹម ៤ រូប ហើយលោកឲ្យនិយាយខ្សឹប ៗ ដែលលោកប្រព្រឹត្តយ៉ាងនេះ ដោយហេតុអ្នកដែលមានសេចក្ដីរាប់អានលោកច្រើនពេក ដណ្ដើមគ្នាចូលទៅសួរ អ្នកខ្លះ ចូលទៅជិតលោកហើយយំសោកខ្សឹកខ្សួល នាំឲ្យលោករំជួលក្នុងសន្ដានចិត្ត ខានគិតធម៌អាថ៌ក៏មាន ៗ

ព្រះតេជព្រះគុណព្រះឧត្ដមមុនី លោកកំពុងតែមានសតិសម្បជញ្ញៈគិតធម៌អាថ៌ជារឿយ ៗ អាពាធក៏កាន់តែធ្ងន់ឡើង ៗ ជាលំដាប់, មច្ចុធម្មជាតិតែងកំចាត់បង់ជីវិតរបស់សត្វក្នុងត្រៃភព ក៏មកគ្របសង្កត់ជីវិតសង្ខារ

របស់លោក ឥតកោតញញើតគណៈសិស្សានុសិស្ស និងញាតិមិត្ត ដែលមកចោមរោមផ្ដុំជិតជួយអភិបាលយ៉ាងម៉ឺងម៉ាត់នោះ បន្តិចបន្តួចសោះឡើយ, នៅវេលាយប់រំលងអធ្រាត្រ ម៉ោង ២ កន្លះ ក្នុងថ្ងៃសុក្រ ៥ កើត ខែទុតិយាសាឍ ឆ្នាំថោះឯកស័ក ព.ស. ២៤៨២ ត្រូវនឹងថ្ងៃ ២២ ខែ ស៊ីយេកឆ្នាំ ១៩៣៩ ក្រង់ព្រះជន្មាយុចូលក្នុងវ័យ ៥៩ ព្រះតេជព្រះគុណព្រះឧត្តមមុនី ក៏ទទួលអនិច្ចធម្មចំពោះមុខភិក្ខុសង្ឃ ៤ រូប យ៉ាងស្ងៀមស្ងប់រៀបរយ ត្រូវតាមអធ្យាស្រ័យរបស់គេដែលសព្វព្រះទ័យនឹងសេចក្ដីស្ងប់ស្ងាត់ ដូចពោលមកខាងដើម ។

លំដាប់តពីវេលាដែលព្រះតេជព្រះគុណព្រះឧត្តមមុនី ទទួលអនិច្ចធម្មទៅភ្លាម ក៏មានព្រះថេរានុថេរៈនវកភិក្ខុសាមណេរ ឧបាសកឧបាសិកាជាច្រើនផែរដាសចូលមកចោមរោមផ្ដុំជិតសពរបស់លោក ដោយសេចក្ដីសោកស្ដាយរកអ្វីប្រៀបពុំបាន ។ បណ្ដាជនដែលចូលមកឃើញសពរបស់លោក ច្រើនតែលាន់មាត់ថា " ឱ ! ស្រុកខ្មែរយើង ខាតអ្នកប្រាជ្ញខាងផ្លូវបរមត្ថអភិធម្ម និងខាងមេគំនិតដ៏មានសន្ដិភាពល្អ ដែលនាំឲ្យពុទ្ធសាសនា និងស្រុកទេសចម្រើនមួយហើយតើ ! គួរឲ្យស្ដាយពន់ពេក ស្ដាយអើយស្ដាយក្រៃលែងស្ដាយ !"

ក្នុងថ្ងៃសៅរ៍ ៦ កើតដែលជាថ្ងៃបន្ទាប់ពីថ្ងៃអនិច្ចធម្មនោះមក វេលារសៀលម៉ោង ៥ មានការជួបជុំធំ ដោយមហាជនទាំងបព្វជិតនិងគ្រហស្ថ

ព្រមទាំងអ្នកមុខអ្នកការមន្ត្រីបារាំងខ្មែរ ទាំងក្សត្រិយ៍ ទាំងរាស្ត្រតូចធំ ជាច្រើន ចូលមកគំនាប់ព្រះសព ស្រោចទឹកអប់ដ៏មានក្លិនពិដោរ ហើយនិមន្តឡើងកាន់មឈូស ដែលប្រដាប់ដោយគ្រឿងជាទង់ដ៏មានក្បាច់ចេនា ប្រាលន្ធោង្អិនឆ្អៅល្អពន្លឺក មានតម្លៃច្រើនតំកល់នៅទីកុដិរបស់លោក យ៉ាងខ្ពស់ត្រដែត ។

សភាពអនិច្ចធម្មរបស់ព្រះតេជព្រះគុណព្រះឧត្តមមុនីនេះ រាប់ថាជាសភាពអស្ចារ្យមួយ ដោយបណ្ដាលឲ្យមហាជនជាបព្វជិតនិងគ្រហស្ថ ទាំងស្រុកក្រុងនិងស្រុកក្រៅ ដែលជ្រះថ្លានឹងគុណសម្បត្តិរបស់លោក កកើតអំពើកជាច្រើន នាំគ្នាមកធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសផលប្រគេនទៅលោក ៗ ឯពិធីបុណ្យនោះគឺពេលព្រឹកនិមន្តព្រះសង្ឃសូត្រព្រះសត្តប្បករណាភិធម្ម បង្សុកូលឆាន់ យ៉ាងតិចត្រឹម ៥០ យ៉ាងច្រើនដល់ ១០០ រូប ពេលយប់ស្ដាប់ធម៌ ៗ កាលដែលទេសនាម្ដង ៗ សឹងសម្ដែងដោយយោសនស័ព្ទ (គ្រឿងពង្រីកសម្លេង) ឲ្យឮឆ្ងាយ ។ ព្រះសពព្រះតេជព្រះគុណព្រះឧត្តមមុនីនោះ គេតំកល់ទុក ៣ ខែកន្លះ ដើម្បីទុកឪកាសឲ្យពុទ្ធបរិសទ្យ ដែលមានកតញ្ញូកតវេទី ចំពោះគុណូបការៈរបស់លោក មកធ្វើបុណ្យឧទ្ទិសផលប្រគេនលោក ។ ពុទ្ធបរិសទ្យដែលមកធ្វើបុណ្យនោះច្រើនវត្ត ច្រើនស្រុក ច្រើនគ្នា ចូនកាលទៅស្រុកឆ្ងាយ ៗ ពីគ្នា មកធ្វើស្របគ្នា ២-៣ ស្រុកក្នុង ១ ថ្ងៃក៏មាន ចូនកាល ១ ស្រុក

មកធ្វើ ១ ថ្ងៃដោយខ្សែកពីគ្នាកំពាន ស្មើរតែដណ្ដើមពេលគ្នាធ្វើ, ថ្ងៃដែលចន្លោះពីអ្នកស្រុកក្រោមមកធ្វើ កំអ្នកស្រុកក្រុងគេធ្វើរាល់ថ្ងៃ ឥតមានខាន ថ្ងៃដែលធំជាងគេគឺថ្ងៃសីល ១ ខែ ៤ ដង, ដរាបដល់ថ្ងៃ ៧កើត ខែអស្សុជ ឆ្នាំថោះឯកស័ក ព.ស. ២៤៨២ ត្រូវនឹងថ្ងៃ ៤ ខែ ណូវែម្ប្រ៍ គ.ស. ១៩៣៩ ទើបគេព្រមព្រៀងគ្នា ធ្វើបុណ្យឈាបនកិច្ចរំលាយព្រះសពលោក ដោយពិធីបុណ្យយ៉ាងឧឡារិក អស់ ៤ ថ្ងៃ ៤ យប់ ។

---

វិញ្ញាណកើតមានឡើងអំពីវត្ថុពីរយ៉ាងគឺ អំពីគ្រឿងផ្សំនិងពួកជាងគឺ អវិជ្ជានិងសង្ខារ ។ អវិជ្ជាមានពីរយ៉ាងគឺ អវិជ្ជាគ្រាស់ ១ អវិជ្ជាស្ដើង ១ ។ អវិជ្ជាគ្រាស់នោះ គឺផែនដីទាំងមូលដែលយើងដើរលើសព្វថ្ងៃនេះ និងទឹកដែលមាននៅគ្រប់ស្ទឹង បឹង ទន្លេ សមុទ្រ ក្នុងលោកនេះ និងដុំភ្លើងធំដែលឋិតនៅក្នុងអាកាសសព្វថ្ងៃនេះ និងចំណោមខ្យល់ដែលបក់ផ្សាយក្នុងលោកសន្និកសនេះ ហៅថា អវិជ្ជាគ្រាស់ ជាពាហិរធាតុ គឺធាតុខាងក្រៅ ។ ឯអវិជ្ជាស្ដើងនោះ គឺក្នុអាកាសទាំងមូលដែលមាននៅក្នុងចន្លោះធំចន្លោះតូច ក្នុងលោកនេះ ជាពាហិរធាតុដូចគ្នាដែរ, កម្លាំងផែនដីនាំឲ្យកើតឡើងជាស្មៅ វល្លិ ឫស្សី ឈើ ឬ តិណជាតិ រុក្ខជាតិកំបាន, ដី ជាហេតុ, ពួកតិណជាតិនិងរុក្ខជាតិ ជាផល, ផលរបស់ដីនេះមានដំណើរដឹងបន្តិចបន្តួច ឬ ចេះដឹងបន្តិច ។ ជាងហេតុដើម គឺដី ។

(ដកស្រង់ពីសៀវភៅអភិសោធកិច្ច របស់ព្រះឧត្តមមុនី អ៊ុម-ស៊ូរ)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ប៉ាង-ខាត់ រៀបរៀង*

អនុវត៌ គុ. អនុវត៌, ដែលលុះក្នុងអំណាច ។ បុំ. សេចក្ដីគោរព ។

អនុវិស៑ ធាតុ ដើរតាម, នៅ ។

អនុវហ៑ ធាតុ នាំទៅរឿយៗ ។

អនុភា ធាតុ បក់, ផ្លុំ, (ខ្យល់) ។

អនុភាក បុំ. អនុភាក, វត្ត, ចំពូក ។

អនុភាក្យា ស្ត្រី. អនុភាក្យា, ពាក្យដែលហៅគូរសូត្រ ។

អនុភាត បុំ. អនុភាត, ខ្យល់បក់តាមក្រោយខ្នង ។

អនុភាទ បុំ. អនុភាទ, សេចក្ដីផ្ដើមសុន្ទរកថា ។ កិរិយាមើលងាយ ។

អនុភាទិន៑ គុ. ដែលពោលតាម, ដែលស្របតាម ។

អនុភាសរម៑ ក្រិ. វិ. មួយថ្ងៃហើយមួយថ្ងៃទៀត ។

អនុវិកស៑ ធាតុ រីកផ្កា, ចេញផ្កា ។

អនុវិចរ ធាតុ ឆ្លង ។

អនុវិទ៑ ធាតុ រកឃើញ, បាន, កាន់យក (ជាប្រពន្ធ) ។

អនុវិទ្ធ គុ. ដែលមុតហើយ, ដែលពេញដោយ ។

អនុវិធ គុ. ដែលអាស្រ័យដោយ ។

អនុវិជា ធាតុ កោះ, កំណត់ ។

---

អនុវិធាយិន៑ គុ. ដែលគោរពតាម ។

អនុវិធា ធាតុ ស្ទុះតាម, លិចតាម ។

អនុវិធ្យ ធាតុ បរបាញ់ ។

អនុវិនទ៑ ធាតុ ជ្រាបសព្ទ (សំឡេង) ។

អនុវិនឝ៑ ធាតុ វិនាសតាម ។

អនុវិន្ទ បុំ. នាមមនុស្ស, នាមព្រះរាជបុត្រព្រះបាទធ្ឫតរាស្ដ្រ ។

អនុវិប្លុ ធាតុ ធ្វើឲ្យវង្វេងផ្លូវ ។

អនុវិម្ឫជ៑ ធាតុ រឹត ។

អនុវិម្ឫឝ៑ ធាតុ ពិចារណា ។

អនុវិលី ធាតុ រលាយ ។

អនុវិឝ៑ ធាតុ ចូលតាម ។

អនុវិទ្ធ គុ. ដែលដោតទុក ។

អនុវិស្ឫត គុ. ដែលលាត, ទូលាយ ។

អនុវិស្មិត គុ. ដែលធ្ងល់ ។

អនុវិហន៑ ធាតុ ផ្តាច់ចេញ ។

អនុវីក្ស៑ (ត្វីក្ស៑) ធាតុ មើលជុំវិញ ។ ពិនិត្យ ។

អនុវីជិត គុ. ដែលរំភើយ, ដែលរហើយ ។

អនុវ្ឫ ធាតុ គ្រប, រុំ ។

អនុវ្ឫត៑ ធាតុ ប្រព្រឹត្តតាម, តាម ។ –វ្ឫត្ត គុ. ដែលប្រព្រឹត្ត
តាម ។ នបុំ. សេចក្តីគោរព ។

អនុវ្ឫត្ត គុ. មូល ។

អនុវ្ឫត្តិ ស្រ្តី. អនុព្រឹត្តិ, ចិរវេលា ។

អនុវ្ឫធ៑ ធាតុ ចម្រើនរឿយៗ ។

អនុវេលម ក្រ.វិ. តាមវេលា ។

អនុវេល្លិត គុ. វៃងលវៀង ។

អនុវេធ បុ. អនុវេធ, កិរិយាចូលរឿយៗ ។ រៀបមង្គលការប្អូន

មុនបង ។

អនុវេប្ត គុ. បិទ, ពាស ។

អនុវ្យធិ ធាតុ ប្រូវម្លុស, ចាក់ទំលាយ ។

អនុវ្យវិសា ធាតុ ស្គាល់, ទទួលស្គាល់ ។

អនុវ្យាខ្យា ធាតុ ពន្យល់, អធិប្បាយ ។

អនុវ្យាខ្យាន នបុ. អនុវ្យាខ្យាន, អត្ថបទពន្យល់ផ្នែកព្រាហ្មណៈ ។

អនុវ្យាធ បុ. កិរិយាទោរឿយៗ, កិរិយាអានទល់ចប់ ។

អនុវ្យាហ្ឫ ធាតុ ថាតាមដោយសូត្របណ្តើរ ។ _ហ្ឫត នបុ. បណ្តាសា,

អពមង្គល ។

អនុវ្រជ ធាតុ ប្រតិបត្តិ, គោរព, ធ្វើធម៌យាត្រា ។

( នៅមានត )

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១០

(ត)

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

លុះគ្រូទៅក៏ប្រទះឃើញដួងបទុមមាស ឱភាសខ្ទរស្រទាប់ត្របក ស្រស់ល្អខ្ទរខ្លាយ សាយក្លិនពិដោរ ដូចអប់ត្រឡប់ល្អងកេសរបុប្ផជាតិ, ផ្កានោះកែឡើងឃើញទាំងប្រអប់សុវណ្ណច្បាស់នៅក្នុងស្រទាប់បទុម មានស្វេតពណ៌ពាយរុងរឿង ក្នុងផ្ទុកហប់សែងព្រះទិនករ ព្រះមុនីក៏ចាប់ប្រអប់សុវណ្ណតេ្ត បើកបានឡើងហើយ ក៏ឃើញរាជធីតាល្អក្រៃលែងលើសលោកា ទេវលក្ខណ៍កន្ត្រាក៏ងើបងាយ ហើយព្រះមុនីក៏ចាប់លើកពយកចេញពីប្រអប់មាសហោង ។ តាំងតែពីនាងប្រសូតចេញមកអំពីផ្ទៃនៃព្រះមាតានោះ គិតដល់មកថ្ងៃដែលព្រះតាបសបើកយកនោះ ព្រះជន្មស្រពនាងបាន ១៦ ឆ្នាំហើយ ៗ គ្រានោះ រីពួកសេនាយោធាផងទាំងឡាយ គិតដល់ទីនៃអង្គព្រះរាជធីតាជាមហាស្ត្រី មើលទៅ ក៏រឹតតែល្អណាស់ឡើង ហើយក៏នាំគ្នាលើកជ័យថ្វាយពរព្រម ៗ គ្នា, ស័ព្ទសម្លេងឮលាន់ទាំងពនាល័យ ។

កាលនោះ ព្រះជនកមហាឥសី ក៏នាំព្រះរាជបុត្រីទៅកាន់ទីអាស្រមបរមសាលា, លុះមកដល់ទីអាវាសនោះហើយ ព្រះមុនីក៏

សែនសោមនស្ស ទើបពោលនូវគាថា នៃព្រះជីតាកដកុមារនេះ
រីឯខ្លួនអញសោកក៏គ្មានទាំងបុត្រាបុត្រី នឹងតវង្សានុវង្សនឹងគេក៏គ្មាន ទើប
បានជាអញលះបង់រាជសម្បត្តិ មកសាងព្រត ចម្រើនព្រហ្មវិហារ នៅ
ក្នុងព្រៃអរញ្ញគិរី គេតបានកុសលផលបុណ្យនោះ ច្រើនក្រៃពេកណាស់,
ឥឡូវនេះ អញមកបានកូនសម្លាញ់ហើយ ក៏សមដូចគ្រាប្រាថ្នាអញក្នុង
គ្រានេះ នឹងបានតស្សប់វង្សពង្សត្រកូល ។ ដូច្នេះ អាពុកនឹងឲ្យនាម
ដូចរាជជីតា ឈ្មោះនាងសីតា សូមកុំឲ្យមានពេកតាព្យាធិ មកបៀត
បៀនឡើយ ។

កាលនោះ រីនាងសីតាយុវមាល ក៏បានស្ដាប់ព្រះបិតាមាន
ព្រះបន្ទូលដូច្នោះហើយ ទើបនាងក៏ក្រាបក្រោមព្រះបាទា ថ្លែងថា រី
គុណព្រះបិតា ដែលទ្រង់ព្រះមេត្តាចិញ្ចឹម ជួយរក្សាព្យាបាលមកនោះ
មានព្រះគុណធ្ងន់ណាស់ជាទីបំផុត នឹងយកក្រឡាមហាប្រថពី ឬផ្ទៃ
អាកាស ព្រះគង្គា មហាសមុទ្រទាំងត្រៃលោកា មកប្រៀបធៀបផ្ទឹម
ឲ្យត្រឹមស្មើក៏ពុំស្មើឡើយ, កូននឹងសូមតបស្នងនៃព្រះបាទាបម្រើអស់ ១
ជីវិត លុះទាល់តែក្ស័យប្រល័យផងហោង ។ កាលនោះ រីពួក
សេនាបតី ក៏ក្រាបថ្វាយបង្គំប្រណម្យដាក់លើសិរោមាល ទូល
ទៅព្រះមុនី ថា តាំងតែពីព្រះអង្គលះបង់រាជសម្បត្តិ ចេញមកកសាង
ព្រតព្រហ្មចរិយាប្រកបជាឥសី ព្រះរាជទានឲ្យទូលព្រះបង្គំជាខ្ញុំរក្សា

ព្រះនគរថ្វាយនោះ ជាច្រើនឆ្នាំយូរមកហើយ មិនដែលមានហេតុកេវ កន្ទអ្វីសោះឡើយ, ឥឡូវនេះ ព្រះអង្គក៏បានព្រះរាជធីតាហើយ សូមព្រះអង្គទ្រង់លាព្រឹទ្ធព្រាហ្មណ៍ហោរាជាគ្រឹហាក់ស គ្រឡប់វិលទៅសោយរាជ-សម្បត្តិវៀងជ័យ គ្រប់គ្រងអាណាប្រជានុរាស្រ្ត សព្វមុខមន្ត្រី សេ-នាបតីទាំងពួង នូវក្រសួងព្រះញាតិពង្សវង្សក្សត្រនោះ នឹងបានស្បើយល្ហែល្ហើយអំពីទុក្ខ ៗ តាំងតែអំពីព្រះអង្គ យាងមកទ្រង់សាងព្រឹទ្ធថៃណាហើយ ក៏ជាទុក្ខគ្រប់គ្នាទាំងអស់ ថាបើព្រះអង្គស្តេចទ្រង់វិលទៅព្រះនគរវិញនោះ អស់រាស្រ្តទាំងឡាយ នឹងបានត្រេកអរសប្បាយ ដោយបុញ្ញរាសីបារមីព្រះអង្គហោង ៗ

កាលនោះ ព្រះជនកមហាឥសី ស្តេចបានស្តាប់ពាក្យសេនាបតីយកសេចក្តីទូលដូច្នោះហើយ ព្រះអង្គក៏ហាក់ដូចបានទិព្វពារី មកស្រង់សោយ ហើយទើបព្រះអង្គផ្លាស់គ្រឿងបរិក្ខារសំបកឈើ នូវស្បៃស្បែកខ្លាចេញ ផ្លាស់ពីស្មា តាំងចិត្តលាព្រឹទ្ធពិធីកិច្ចស្រេចហើយ ក៏ទ្រង់គ្រឿងក្សត្រវិញហោង ៗ លុះសឹកចាកសិក្ខាបទស្រេចហើយ ក៏ស្តេចឡើងគង់លើព្រះរាជរថសុវណ្ណ ជាមួយនឹងរាជធីតាវិសេសសុវណ្ណា ហើយព្រះអង្គក៏ឲ្យលើកចតុរង្គយោធា ចេញចាកអាស្រមកុដិសាលាមក, លុះស្តេចយាងមកតាមវិថី ទីជ្រោះច្រកជ្រលងដងព្រៃព្រឹក្សា, ស័ព្ទសម្លេងពលសេះដំរីសេនីយ៍សេនា គោលាហលរចល់ទាំងពនាលី, លុះគន្លង

ទីផែន ចូលដល់ឋានព្រះនគរ ស្ដេចក៏កៀនពលបន្ទំ ឲ្យបានគាប់ហោង ។ រីឯពួកពលសកលយោធាក៏ប្រជុំនាំគ្នាចរលី ស្រួតត្រួតតាមព្រះឧត្ដមមហាក្សត្រហោង ។

គ្រានោះ រីពួកស្រីប្រុសក្នុងនគរទាំងពួង សេដ្ឋី កុដុម្ពិក ពិព្រាហ្មណ៍ព្រឹទ្ធាចារ្យ ប្រជាជន បានដឹងដំណឹងថា ព្រះបរមគត បានកជងគីតាក្នុងដួងបទុមា នាងនោះល្អលើសស្រីទេពកញ្ញា, ឥឡូវនេះ ព្រះអង្គស្ដេចត្រឡប់វិលមកព្រះនគរវិញហើយ ក៏និយាយប្រាប់គ្នាជាអឹងកង ទៅលុះបានឃើញអង្គព្រះបរមកុដលោកា ទ្រង់រតន៍សុរ្យកាន្ត ព្រមទាំងពាហានសេនាអាមាត្យមុខមន្ត្រីសេនីយ៍យោធា ហែហមអមជុំមក ។ រីឯព្រះកជងគីតាអង្គុយគង់ពីមុខរថជ័យ ល្អដូចដួងព្រះចន្ទ្រានៅកណ្ដាលអម្ពរ ខ្លះក៏មើលទៅសរសើរ ខ្លះក៏មើលទៅភ្លេចភ្លាំងភាំងស្មារតី មិនមានដាក់ភ្នែក, ទាំងអស់គ្នាក៏សែនត្រេកអរសោមនស្ស នាំគ្នាបាចសាចទូវកុផ្កា ហើយស្រែកថ្វាយពរស្ដុតី មង្គលាជយាតិរេក ឯកឧត្ដមបរមសុខា ទាំងធរណីហោង ។

កាលនោះ ព្រះបាទព្រះជនកធិបតី លុះស្ដេចយាងមកដល់កើយរង្សីហើយ ព្រះអង្គក៏បញ្ជូនពួកយោធាទាំងពួង ។ រីពួកមន្ត្រីសេនាក្នុងបុរី លុះបានឃើញព្រះចក្រីស្ដេចឈប់នៅកើយកែវរតនា, សេនាទាំងពួង ក៏ក្រាបថ្វាយបង្គំគាល់ គាំងផ្ទុំត្រែស័ង្ខ អញ្ជើញឲ្យស្ដេចចុះ

ពីកដរថៃហោង  តាំងស្តូស្រស់ស្រៃប្រនាគភាទ្យគង់ជូរប្រជន្ត្រី  ក្លាហានជា គោលាបាល ។ កាលនោះ នាងរតន៍មុទីជាអង្គអគ្គមហាមហេសី ទង់ហ្វូងស្រីស្នំក្រមការ ទូវអស់តាំងស្រីចាស់ទុំអក់ឃោយ ទូវពួកស្រី កំណាន់ក្អាក់ផ្ការតាំងឡាយ កំតែង់ខ្លួនស្លៀកសំពត់សិតសក់ផាត់ម្សៅ មុខ តាំងតូចធំចេញមកចាំទទួលស្តេចព្រមគ្នាហោង ។

កាលនោះ ព្រះបាទជនកធិបតីស្តេចនាំព្រះរាជធីតា យាត្រាឡើង លើប្រាសាទរតនា ដាក់អង្គគង់លើបល្ល័ង្ករតន៍ ព្រះអង្គល្អដូចទេវរាជ រង្សី ព្រមដោយអង្គអគ្គមហេសីកល្យាណ គង់គាល់ដេរដាសពាសពេញ ក្រាបថ្វាយបង្គំប្រណម្យគាល់ រង់នៅចាំស្តាប់ព្រះរាជឧង្ការហោង ។

គ្រានោះ រីឯនាងសិតាយៅវមាល យើញអង្គព្រះវររាជមាតា នាងក៏ក្រាបថ្វាយបង្គំប្រណម្យក្រោមព្រះបាទមាតា ។ កាលនោះ នាងរតន៍មុទីស្នេហា ទ្រង់មើលរូបនោមរាជធីតា ដ៏មានលក្ខណាក៏ល្អ ព្រមតាំងឥន្ទ្រិយឥរិវណ្ណ, សម្តេចព្រះទេវីក៏ឱបអង្គែល ហើយទើបមាន ព្រះវាចាថា កូនអើយ ម្តាយសែនក៏សពកស្រឡាញ់ពេញចិត្តប្រៀប ស្មើដួងជីវិត ព្រោះដ្បិតម្តាយគ្មានបុត្រីបុត្រាណាមួយឡើយ, ឥឡូវនេះ ម្តាយបានកូនសម្លាញ់ពេញដួងចិត្ត ទឹងបានភព្វផងស្រង់ត្រៃត្រខត្តិយ-រាជទៅឯមុខ ជាសិរីមឿងរឿងឫទ្ធិ ក្រុងក្រុងមិថិលាមហានគរបុរីរាជ-ធានីហោង ។ នាងថាហើយ ក៏ទ្រង់ប្រទានគ្រឿងប្រដាប់សម្រាប់

តែងព្រះអង្គនោះ សមជាគូនឹងអង្គព្រះមហាចក្រា ហើយក៏ឲ្យនាំគង់នៅប្រាសាទកែវមកុដព្រហ្មតាំង ៤, សម្តេចព្រះទេវី ក៏ថ្នមស្រឡាញ់ដូចដួងជីវាកូនបង្កើតហោង ។

កាលនោះ ព្រះជនកចក្រពត្តិវង្ស គ្រប់គ្រងបុរីមិថិលា ជាមហាមហៃស្វរ្យ ប្រកបដោយនូវស្រីសួស្តីបរិវារនឹងសេនាអាមាត្យមុខមន្ត្រីអាណាប្រជាជនទាំងនាទី ជាទីសុខសម្រាន្តសប្បាយ ឥតសត្រូវទាំងឡាយមកបៀតបៀន ទាំងព្យាធិរោគាទាំងពួងក៏គ្មានឡើយ ។ ព្រះអង្គក៏ទ្រង់រំពឹងគិតក្នុងព្រះប្រាជ្ញាញាណ ដ្បិតព្រះរាជធីតាទូលល្អង ក៏បានព្រះជន្មវស្សា ១៦ ឆ្នាំហើយ គួរនឹងឲ្យមានគូស្រករមេរសកិម្យ, ដូច្នេះគួរអញនឹងតាំងពិធីលើកធ្នូសិល្ប ហើយនឹងមានសំបុត្រចុតហ្មាយប្រាប់ទៅឲ្យគ្រប់ក្រុងក្សត្រ ឲ្យអស់ក្នុងត្រៃចក្រ បើអ្នកឯណាលើករួចបានហើយ អញនឹងផ្សំកូនអញឲ្យជាអគ្គជាយា ។ ព្រះអង្គទ្រង់គិតហើយក៏ល្មមពេលស្វាងអរុណរះ ដួងព្រះទិនករចេញមកពីបុងកំពូលភ្នំយុគន្ធរជាភ្នំធំ ព្រះអង្គក៏ទ្រង់តើនចាកព្រះក្រឡាបន្ទំ ហើយទ្រង់ស្រង់វារីរួចស្រេច ព្រះអង្គទ្រង់គ្រឿងអលង្ការ ព្រះកុវ៉ៃយក៏ចេញមកពង់ពេងង់ ហោង ។ លុះដល់ហើយ ក៏ព្រះអង្គគង់លើបល្ល័ង្ករ័ត្ន ក្រោមស្វេតច្ឆត្រដែកនាយ ។ សេនាអាមាត្យគាល់ដេរដាសពាសពេញដូចតារាករ រាយរេមរោមអង្គព្រះច័ន្ទ្រានៅកណ្តាលវេហាស៍អាកាស,

ទើបព្រះអង្គមានព្រះឱង្ការនឹងលោកអាចារ្យឆ្វេងស្តាំ ថា ដ្បិតអញនឹងអភិសេកពជធីតា ឲ្យអស់ពួកក្សត្រា ក៏គ្នាមកលើកធ្នូសិល្បជ័យ តើថ្ងៃណាបានប្ញក្សពារពេលាល្អនឹងធ្វើមង្គលការពិធី ? ចូរពិនិត្យគិតគូរមើលព្រះគ្រោះឲ្យល្អ កុំឲ្យមានហេតុកេវភ័យ អន្តរាយ រោគាព្យាធិ អ្វី ៗ ឡើយ ។

គ្រានោះ នាយលោកអាចារ្យទាំង ៤ ទទួលព្រះឱង្ការព្រះបរមកព ហើយ ក៏មើលតាមដោយគម្ពីរសែយត្រៃភេទវេទវិជ្ជាទិនព្រះសុរិយយាត្រ ហើយក៏តាំងសំផុតព្រះច័ន្ទលុបប្ញកគុណនឹងគ្នាតាមស្ថាន បានប្ញក្សឧត្តមជោគសុភមង្គល: យើញ:ហើយ ក៏ក្រាបបង្គំទូលទៅថា នៅថ្ងៃព្រហស្បតិ៍ ៤ កើត ខែផលគ្គុនឆ្នាំនេះ ឈ្មោះហៅថាសិទ្ធិជោគ នេះប្ញក្សជ័គួរនឹងតាំងពិធីលើកធ្នូសិល្បជ័យ ព្រះគូរន័យទំនាយនឹងបានកូនប្រសារនោះស្បូវង៍ព្រាន់ព្រូផងទេវេស នឹងល្បីព្ញុះតេជៈដេស្ពជ័យទាំងត្រៃចក្រ នឹងបានជាតំនាក់ភាក់ពឹងទាំងលោកធាតុហោង ។

កាលនោះ ព្រះចក្រត្រៃវង្ស ស្តេចស្តាប់ហើយហាក់ដូចបានទិព្វភិរមនសួគ៌ ទើបមានព្រះពជនឹងឱង្ការទៅនឹងសេនាបតី ឲ្យតាំងធ្វើបណ្ណាបមាស ឲ្យទុកាសរុង់រៀងកំពូលកំពស់ស្មើនឹងវេហាស៍ ហើយក៏អញ្ជើញធ្នូព្រះឥស្សរឥស្សព្រមកតម្កល់ទុកនៅមុខព្រះលានជ័យ ។ រីពួកគណៈព្រះឥសីសិទ្ធ ដែលបិតនៅឯព្រៃហិមពាន្ត ក៏ឲ្យទៅនិមន្តមក

សង្រួមចិត្ត ចម្រើនវេទមន្តវិជ្ជាក្នុងទីរោងរាជពិធីធំហោង ។

គ្រានោះ សេនាបតីមន្ត្រីធំទាំង ៤ ទទួលព្រះឱង្ការហើយ ក៏ក្រាបថ្វាយបង្គំចេញចាកទីព្រះរោងគាល់ មកចាត់ចែងតែងធ្វើមណ្ឌបសុវណ្ណកេត ៤ ជ្រុង មានមុខដាច់ទាំង ៤ ល្អបីដូចជាទេពយន្តវិមាន អវណ្ណក ខាងក្រោមក្រាលចៀមចំរៃព្រំក្នុងបុប្ផាមាលា ចងដាំរំយោលរៀងរាយ ខាងលើសុទ្ធតែបាំងពិដានដាសពាសពេញ ហើយក៏តាំងចងគោមចង្កៀងនិងគោមយោងព្យួរជាជួរជុំវិញ ។ រីឯព្រះវេទនធ្វើដាក់ធ្ជជ័យនោះ សុទ្ធសឹងប្រដាប់ដោយត្បូងពេជ្រ រំលេចក្បាច់ចេនាល្អពណ្ណរាយ ។ រីឯគ្រឿងទាំងឡាយ ក៏ដោយដាំទមណ្ឌបរាជកិច្ចផ្ទុំតាមមុមជ្រុង ធំទូលាយ ធ្វើនៅកណ្តាលក្រុងព្រះនគរបុរី ។ លុះចាត់ស្រេចហើយនៃ ដូចព្រះឱង្ការបង្គាប់ហោង ទើបចាត់ប្រើពួកជម្មការឲ្យទៅនិមន្តព្រះអាចារ្យ ដែលនៅក្នុងព្រៃព្រឹក្សា ឲ្យអស់គណៈសិទ្ធានិមន្តមកកាន់រាជធានី ។ គ្រានោះ ពួកជម្មការទាំង ៤ ទទួលប្រសាសន៍សេនាបតី លើកដៃជូលីករ ហើយក៏លាទៅ ។ លុះបានដល់សំណាក់ព្រះសិទ្ធាតាបសជាធំ ក៏ថ្វាយបង្គំទូលព្រះពុទ្ធដីកាថា អង្គព្រះចមគភាលោកា ក្ងទិយនឹងតាំងពិធីពលិការ លើកមហាមោលិដ្ឋសិល្បជ័យរបស់ពីព្រះបមកៃលាសគិរីស្ថាន ហើយឲ្យព្រះអង្គ និង ពួកគណៈបរិវារផងនិមន្តទៅជាប្រធានអធិបតី ក្នុងពិធីពលិការ ។

កាលនោះ ព្រះមហាមុនីឥសីជាធំ បានស្តាប់ហើយ ក៏ត្រេកអរ និយាយប្រាប់ទៅគណៈមហាឥសីហោង ៗ ទាំងអស់គ្នាក៏គ្រងគ្រឿង បរិក្ខារទ្វៀយាមយោគផ្ចិតប្រត់ ហើយក៏ចេញចាកអាស្រមសាលាកុដី ឆ្ពោះមុខត្រង់តម្រង់ទៅកាន់សីមារាជធានី ៗ លុះនិមន្តមកដល់រោង រាជពិធីការ ព្រះអាចារ្យក៏ចូលទៅសម្រឹមកាយាគន់លើអាសនគន្ធមណី ហោង ៗ ទើបនិយាយពីក្សត្រស្សៀងគ្រប់នគររាជធានី សុទ្ធតែ មានខ្ទួយសសក្តា ដឹងថា ព្រះមហាជនកបក្រព័ត្តិឲ្យជាចមពិនស្សៀវឲ្យ និបតិ ទៅសាងព្រីទ្ធអត់ចិត្តការនា ហើយក៏រើសបាទព្រះរាជធីតា នោមធាយ ក្នុងដូងបវរមាមាស, ខ្ទួនល្អនោះ ល្អលើសទេពធីតា សួគ៌, ឥឡូវនេះ លោវាកព្រឹទ្ធព្រាហ្មណ៍វ្យ វិលមកកាន់នគរវិញ ហើយ ក៏តែងតង្កពជធីតាដើតដោមប្រលោមលោក ឲ្យមានគូរមសេតមេរ្យសេព សមសរ៍ ថាបើអ្នកឯណាហើយមានកម្លាំងបុទ្ធបារមីអានុភាព លើក មហាមោលីសិល្បជ័យឡើងរួចបាន ក៏នឹងឲ្យយៅវ៉ាលមិត្រមកជាគូគាប់, ឥឡូវនេះ ស្តេចតាំងពិធីការធំ, រីពួកក្សត្រៀងខ្លួនទាំងអស់គ្នា ក្នុងព្រះ ទ័យចង់បានរាជធីតា ក៏នាំគ្នាទៅគ្រប់ក្រុងភាពក្សត្រ ៗ

---

ចប់ភាគ ១០ មានភាគ ១១ តទៅ

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

(ក)

បំណងរឿង « សាស្ត្រា អានិសង្សគារវិន[១] »

អ្នកនិពន្ធ  *រកពុំបានឃើញ ។*

កាលបរិច្ឆេទ  *គ្មានបញ្ជាក់ក្នុងអត្ថបទ ។*

របៀបនិពន្ធ  *ពាក្យរាយៈ លំនាំទេសនា ។*

ប្រភេទរឿង  *ប្រពៃណីនិយម និងចលនាពុទ្ធនិយម ។*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១៣ សន្លឹក ។*

*ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តកោកកាក (កណ្តាល) ចុះលេខ ៩៩៥ ។*

អត្ថបទផ្តើម  *នមោ តស្ស ។ ឯវំមេ សុតំ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។*

---

១ អានិសង្សគារវិនបែបនេះ ប្រហែលគេរៀបរៀងតាមរឿងជាតកក្រោយទេ ហើយជាពិសេសប្រហែលការនិពន្ធ គម្ពីរបញ្ញាសជាតកនេះទៀត ព្រោះអ្នកនិពន្ធបានបញ្ជាក់ ៦. ដែលខ្លួនដកស្រង់រឿងនេះពីគម្ពីរជាតក ក្នុងបញ្ញាសជាតក ដើម្បីបញ្ជាក់ផលានិសង្ស នៃការកសាងកឋិនទាននេះ ។

អនុសន្ធិ ព្រះសទ្ធម្មទេសនា ជាពាក្យព្រះបាលីរៀបរាប់តាម លំដាប់ នៃព្រះជិនស្រីទ្រង់សម្តែងថា កគព អង្គសម្តេចព្រះ សាស្តាតាវទ្រង់ញាណមានព្រះពុទ្ធដីកាត្រាស់ទេសនា គង់ ឮដំព្រះស្រីជ័យជេតពនសុគន្ធកុដិ មហាវិហារ . . . ។ល។

អត្ថបទបញ្ចប់ នរប្រុសស្រីឯណាបានទៀនក្រមួន ទៅជួយបុណ្យ កឋិននោះក្តី ពុំនោះគ្មានអ្វីឡើយ មានតែកម្លាំងជួយទំនុកបំរុង អង្គព្រះកឋិននោះក្តី ពុំនោះសោភបានដឹងហើយ ដើរចូល ទៅហៃជាមួយទីងគេក្តី ពុំនោះលើកដៃសាធុជាមួយទីងគេក្តី ។ កិច្ចព្រមាលកិច្ចទាំងឡាយ ឯផលានោះ តាមដោយសេចក្តី នៃបុគ្គលនោះហោង ។ សត្ថា អង្គសម្តេចព្រះបរមគ្រូ សព្វញ្ញូ ទ្រង់សម្តែងព្រះធម៌វិសេសទេសនា ប្រោសប្រទាន អានិសង្សកឋិនចប់កាលឯណាម៉ិញ អ្នកខ្លះបានសោតាបត្តិមគ្គ អ្នកខ្លះបានសោតាបត្តិផល តាមដោយទេសនា អាត្មាទៃ ។ ឯទៀតក៏ចប់ដោយនូវប្រការ អម្បាលណោះឯងហោង ។

x x x

បំណងជើង « សាស្ត្រាអានិសង្សខ្សោយ[1] »

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ កន្លែងគួរ ។

១ សូមមើលនយលក្ខណៈ ក្នុងអត្ថបទនៃអានិសង្សមុនៗ ដែលបានបញ្ជាក់រួចមកហើយ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង ប្រពៃណីនិយម និងចលនាពុទ្ធនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៤ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តគោកគាក (កណ្ដាល) ចុះលេខ ៩៩៥ ។

អត្ថបទផ្ដើម ឯវម្មេ សុតំ ឯកំ សមយំ ភគវា វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ ភោ សាធវោ ហៃសាធុ សប្បុរសផងទាំងឡាយអើយ ភគវា រីព្រះដ៏មានបុណ្យ វិហរតិ គង់ព្រះអង្គស្ដេចគង់ ជេតវនេ ក្នុងព្រះស្រីជ័យជេតពន សុគន្ធ-កុដី ស្រីមហាវិហារ គឺវៀអនាថបិណ្ឌិកសេដ្ឋី ប្រដាប់សាងថ្វាយ ព្រះអង្គស្ដេចគង់ជាផាសុកព្រះហឫទ័យ ស្រេចយកត្រៃចីវរមហាបង្សុកូល . . . ។ល។ .

អត្ថបទបញ្ចប់ ហៃសាធុសប្បុរសទាំងឡាយអើយ ចូរអ្នកទាំងឡាយយកចិត្តចងចាំ តាមបន្ទូលព្រះធម៌វិសេសទេសនា យកទុកគ្រប់អាត្មាទីទៃៗ សព្វថ្ងៃ សព្វខែទៅហោង ។ កាលបករណំ ទិដ្ឋិតំ ។ រីទីងស្រដីសរសើរផលានិសង្ស ខែអ្នកបានលើកឡោចគ្រូបាធ្យាយ ម្ដាយឪពុក ដ៏ជូនជីតា ញាតិកាទាំង ៧ សន្តាន សាច់ញៅ គ្រៀងលាននេះមិញ ជាសុវេទន៍ប្រកាសម្បាលណោះហោង ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ច្វ-ភាគ ៨

ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកកាំងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ុន

ឡេវហាំងថា ដែលអ្នកនិយាយមកទាំងប៉ុន្មាន ក៏គ្មានទិយានពិតទាំងអស់ តែវេលានេះ គួនអ៊ូប្រើបម្រើឲ្យមកហើយ យើងនឹងរិះគិតប្រ-ការម្ដេច ? បេងតាត់ថា អ្នកចូរប្រាប់លៀវហ៊ូឲ្យត្រឡប់វិលទៅប្រាប់គួនអ៊ូចុះថាវេលានេះ ស្រុកទើបនឹងតាំងថ្មី ទាហានទាំងឡាយ ក៏នៅមិនទាន់មានបរិបូណ៌ច្រើននៅឡើយ ដែលនឹងឲ្យលើកកងទ័ពទៅជួយនោះ ឃើញថាជាការប្រញាប់ណាស់ លំបាកនឹងគិតឲ្យបាន ។

ឡេវហាំងបានស្ដាប់ដូច្នោះ ក៏យល់ឃើញផង, លុះព្រឹកឡើង ក៏ឲ្យគេហៅលៀវហ៊ូចូលមក ហើយប្រាប់ថា អ្នកឯងត្រូវវិលទៅប្រាប់គួនអ៊ូចុះថាយើងទើបតែនឹងមកគ្រងស្រុកជាថ្មី ទាហានក៏មានស្ដើងស្ដួច មិនទាន់ព្រមមូលគ្នា ដែលនឹងលើកទៅជួយនោះឃើញលំបាកណាស់ អ្នកកុំតូចចិត្តនឹងយើងឡើយ ។ លៀវហ៊ូ បានឮដូច្នោះ ក៏ស្ងួតស្ងាត់គ័យ

ណាស់ យកក្បាលបោកទៅក្នុងវិទោះទាល់តែបែកចេញឈាម ហើយថា ដែលអ្នកមកកាត់សេចក្តីទុក្ខក្តៅ មិនព្រមលើកទ័ពទៅជួយគ្រានេះ គួនអ៊ីទឹងមិនជាអន្តរាយហើយឬ? ។

បេងតាត់តបថា សត្រូវដែលវាទឹងចូលទៅវាយទម្លាយយកស្រុកកេងដីវគ្រានេះ ទបមាដូចគំនរភ្លើងដ៏ធំ, ឯដែលទឹងឲ្យយើងលើកទៅជួយនោះ ទបមាបីដូចយកទឹកក្នុងពែងតូច ទៅស្រោចលត់គំនរភ្លើងធំនោះ ទឹងរលត់ឬ? អ្នកចូរប្រញាប់ត្រឡប់ទៅចាំការពារស្រុកសែឈួនចុះ ។ លៀវហ៊្វ បានឮដូច្នោះ ក៏សែនតូចចិត្តពន់ពេកណាស់ ស្រែកយំហើយអង្វរករដោយពាក្យផ្សេង ៗ ។ ឡៅហង និង បេងតាត់ បានស្តាប់ក៏មិនបានតបថាប្រការម្តេច ក្រោកឡើងលាស់អាវដើរចូលទៅក្នុង ។ លៀវហ៊្វ ក៏តោមនស្ស តូចចិត្ត ក្រោកឡើងដើរចេញទៅ ហើយស្រែកដេរត្រេតោះផ្សេងៗ រួចទើបឡើងសេះគម្រង់ទៅរកព្រះចៅឡៅពីងស្រុកសែឈួន ។

ឯគួនអ៊ី នៅក្នុងស្រុកបេកសៀ មានទាហានប្រហែល ៥០០–៦០០ តែងតាំងចិត្តគិតចាំទទួលមើលផ្លូវកេងទ័ព ដែលប្រើលៀវហ៊្វទៅសុំពីឡៅហង, បេងតាត់ នៅស្រុកសុងយ៉ុងនោះ ក៏មិនឃើញបានមក ចាំងស្បៀងអាហារក៏អស់ ពួកទាហាននោះ ក៏កាន់តែគ្រាំគ្រាដោះគ្រនពន់ប្រមាណ ។ ខណៈនោះ ស្រាប់តែឮស្គរមាត់ដូកាត់គិន ស្រែកហៅពីក្រៅ

កំពែងថា កុំបាញ់យើងៗមានការនឹងចូលទៅនិយាយការផង ៗ គួនអ៊ូឮ
ដូច្នោះ ក៏ហាមទាហានមិនឲ្យបាញ់ផ្ទួ ៗ ដូកាត់គិន ចូលទៅគំនាប់គួនអ៊ូ
ហើយថា ឥឡូវស៊ុនគួន ប្រើខ្ញុំឲ្យចូលមកនិយាយបញ្ចុះបញ្ចូលអ្នក ខ្ញុំនឹងសុំ
និយាយនឹងអ្នក ១ ខ បុកណាលោកថា "ធម្មតាកើតជាមនុស្សនេះ ត្រូវ
ឲ្យដឹងស្គាល់ចំបង់ចីបាន នឹងរិះគិតអានគេក្បែដីតែខ្លួន កុំឲ្យមានអន្តរាយ"
យ៉ាងដូចខ្លួនអ្នក កាលពីដើមក៏បានធ្វើធំក្នុងស្រុកកេងដីរ ឥឡូវស្រុក
កេងដីរនិងអាណាខេត្តដែលឡើងទាំង ៩ មណ្ឌលនោះ ក៏ខូចអស់ដោយ
សត្រូវទៅហើយ អ្នកមកនៅក្នុងស្រុកបេកសៀនេះ ដែលមានទាហានក៏
តិចស្រុកក៏តូច ស្បៀងអាហារក៏ពុំសូវមាន, ឯកងទ័ពដែលថានឹងលើកមក
ជួយនោះ ក៏មិនឃើញមានឡើយ, ម៉្លេះហើយអ្នកនឹងទំប្រឹងទៅដល់ណា!
គួរតែសុំគ្រស្នេហាទៅនៅនឹងស៊ុនគួនចុះ, បើអ្នកទៅនៅហើយ គង់នឹងបាន
សេចក្តីសុខធ្វើធំក្នុងស្រុកកេងដីរតទៅទៀត សូម្បីទាំងករិយាបុត្រញាតិ
សន្តានរបស់អ្នក ក៏នឹងបានជាប្រក្រតីដូចពីដើម, ដែលខ្ញុំថាទាំងនេះ សូម
ឲ្យអ្នកត្រិះរិះគិតមើលតាមគួរចុះ ៗ

គួនអ៊ូ បានឮដូច្នោះ ក៏មិនបានប្រឡោតចិត្តដូចពីដើម តាំងចិត្តថ្ម
សំដីតាមប្រក្រតីធម្មតា ហើយនិយាយថា យើងជាជាតិទាហាន កើតទៅ
ស្រុកកៃលៀង សូម្បីព្រះចៅឡូវពី ក៏បានតាំងសត្យាប្តេជ្ញាជាបងប្អូននឹង
គ្នាថា ស៊ូតែស្លាប់រស់ជាមួយគ្នា បើដូច្នេះ នឹងឲ្យយើងត្រឡប់ទៅចូលខាង

សត្រូវធ្វើម្តេចបាន ពោះបើយើងបាញ់ក៏ត្រូវទទួលស្លាប់តាមក័ត្យ កុំឲ្យតែបង់ស័ក្យសុចរិត, ធម្មតាជាជាតិកែវហើយ បើពោះបីជាបែកធ្លាយយ៉ាងណា ក៏នៅឈ្មោះថាជាកែវដដែល; មួយទៀត ជាតិឈើក៏នៅជាឈើមិនក្លាយទៅជារបស់ឯទៀតឡើយ ពោះខ្លួនយើងនឹងស្លាប់ក៏ឲ្យប្រាកដឈ្មោះតទៅមុខ កុំបាច់ឲ្យអ្នកមកនិយាយឡើយ, ចូរអ្នកត្រឡប់ទៅប្រាប់ស៊ិនគួនចុះ ថា យើងសុំធ្វើសង្គ្រាមតគ្នា លុះត្រាតែអស់ជីវិតរៀងខ្លួន ៗ

ដូកាត់គិនថា ឯចិត្តនៃស៊ិនគួននោះ គិតតែចង់ឲ្យអ្នកបានជាមេត្រីនឹងគ្នាដោយសុចរិត នឹងបានគិតជួយគ្នាធ្វើការកំចាត់ចុងចេញ ហេតុម្តេចបានជាអ្នកមកប្រកាន់ស័ក្យតែម្យ៉ាងដូច្នោះមិនត្រូវសោះ ៗ គួនបើងបានស្តូច្នោះ ក៏ហូតគ្រប៉ះចេញនឹងកាប់ដូកាត់គិន, គួនអ៊ូ ក៏ចាប់គ្រប៉ះទុកហើយហាមឃាត់ថា ដែលនឹងសម្លាប់ដូកាត់គិននោះមិនត្រូវទេ ព្រោះខ្ញុំបេងជាប្អូនបង្កើត នៅធ្វើការក្នុងព្រះចៅឡៅតី, បើនឹងសម្លាប់ទៅ គេនឹងពាស់ចិត្តគិតចង់ព្យាបាទ ព្រោះយើងសម្លាប់បងគេ ៗ លុះនិយាយដូច្នោះហើយ ក៏ឲ្យពាហានទាំងខ្លួនដូកាត់គិនចេញទៅក្រៅ ៗ

ដូកាត់គិន មានសេចក្តីអាប់យសខ្មាសទាហានទាំងពួងណាស់ ក៏ត្រឡប់ទៅជំរាបស៊ិនគួនថា គួនអ៊ូនោះ ពេញជាមនុស្សត្រឹមត្រូវល្អណាស់ គឺជាមនុស្សចិត្តនឹង រីឯកតញ្ញូ តាំងនៅក្នុងសេចក្តីសត្យពិតណាស់ ៗ ស៊ិនគួន ថា គេមានសេចក្តីសត្យពិតត្រង់ដូច្នេះ យើងនឹងគិតយ៉ាងម្តេចឲ្យ

បានស្រួល? លិហាមថា ខ្ញុំបាទនឹងសុំចាប់យាមមើល បើគួនអ៊ូធ្វើសឹកនឹងលោកបាញ់ប្អូឈ្មោះប្រការម្តេច ក៏គង់តែដឹង ៗ ស៊ិនគួន ក៏ឲ្យចាប់យាមមើល ៗ លិហាមក៏ទាយថាក្នុងវែលសយាមនេះ ថា សត្រូវនឹងរត់ទៅផ្លូវឆ្ងាយ ៗ ស៊ិនគួន បានឮដូច្នោះ ក៏ប្រឹក្សានឹងលិហាមថា ក្នុងយាមថា សត្រូវរត់ទៅឆ្ងាយនោះ យើងនឹងគិតឧបាយប្រការម្តេច ទើបនឹងចាប់សត្រូវនោះបាន ?

លិបង់សើចហើយថា ក្នុងយាមទាយថា សត្រូវរត់ទៅឆ្ងាយនោះ ក៏ត្រូវដោយឧបាយរបស់ខ្ញុំបាទ, ឯគួនអ៊ូនោះ ឧបមាដូចសត្វនៅក្នុងទ្រុងទៅហើយ ដែលនឹងឡូនចេញពីដៃយើងនោះគ្មានទេ សូម្បីទាហានក៏មានតិចណាស់ ហើយទុនទុកផង, ដែលនឹងរត់ទៅតាមផ្លូវធំនោះ មុខជាមិនទៅទេ, ឯខាងទិសឧត្តរ ស្រុកបេកសៀ មានផ្លូវតូចមួយអាចធ្វើជាផ្លូវកាត់ ពីដើមដាច់ស្រយាល ព្រោះមានច្រកជ្រោះជ្រលងដងភ្នំជាច្រើន ជាផ្លូវលំបាកដើរក៏មិន តែខ្ញុំបាទយល់ថា មុខជាគួនអ៊ូនឹងរត់ទៅតាមផ្លូវនោះ, សូមលោកចាត់ជូហៀនឲ្យលើកទាហាន ៥.០១០ ទៅនៅស្ទាក់ត្រង់ផ្លូវនោះ បើឃើញគួនអ៊ូ រត់ចេញទៅ កុំឲ្យស្ទាក់ពីមុខទុកឡើយ ព្រោះគួនអ៊ូនោះ មានកម្លាំងខ្លាំងណាស់, បើគួនអ៊ូរត់កន្លងហួសបន្តិចទៅហើយ សឹមឲ្យទាហានស្រែកហោរដេញចាប់សម្លាប់ទាហានពីក្រោយបណ្តាយទៅ, មួយទៀត ភ្ជូបៀង់លើកទាហាន ៥០០

ទៅចាំនៅដើមភ្នំចៅសាន់ជាចុងផ្លូវនោះ ឲ្យរិះគិតរកឧបាយដែលនឹងចាប់គួនអ៊ី ឲ្យបានតែបាន មុខជាគួនអ៊ីនឹងទន់កម្លាំងចុះ ហើយក្នុងពេលយប់នេះ អ្នកចូរបង្ខំទាហានឲ្យចូលលុកទម្លាយទ្វារស្រុកឲ្យខ្លាំងចុះ មុខជាគួនអ៊ីនឹងអស់ទាហានទាំងនោះ រត់ចេញទៅជាប្រាកដ ។

ស៊ុនគួន បានឮលិបង់និយាយដូច្នោះ ក៏ពេញអំណរណាស់ ទើបឲ្យលិហាមចាប់យាមមើលទៀត ។ លិហាមក៏ទំនាយថា ពេលយប់នេះសត្រូវនឹងរត់ចេញពីស្រុកទៅខាងទិសឧត្តរ ដល់ពេលកណ្ដាលអធ្រាត្រនឹងចាប់ចុះជាប្រាកដ ។ ស៊ុនគួនក៏សប្បាយចិត្តណាស់ ទើបបង្គាប់ឲ្យជូហៀននិងក្លួចៀងលើកទាហានទៅតាមពាក្យលិបង់ថា ។ ជូហៀនក៏លើកទាហាន ៥.០០០ ទៅពួនបង្កប់នៅក្បែរផ្លូវនោះ ។ ឯក្លួចៀងក៏លើកទាហាន ៥០០ ទៅដល់ភ្នំចៅសាន់ ឃើញច្រកភ្នំច្រហាកចង្អៀតមួយអន្លើ ហើយសងខាងផ្លូវនោះ សុទ្ធតែព្រៃស្បាតញឹកណាស់, ក្លួចៀងក៏ឲ្យជីករណ្ដៅ ១ ធំ នៅចំកណ្ដាលផ្លូវ ហើយយកស្លឹកឈើគ្របពីលើ ហើយធ្វើអន្ទាក់ពាក់ សម្រាប់ដាក់ឲ្យសេះជាន់នៅក្បែរមាត់រណ្ដៅនោះ ។ លុះពេលយប់ ស៊ុនគួនក៏ចាត់ចែងទាហានដែលមានថ្វីដៃជាច្រើន លើកចូលទៅវាយកំបែកទម្លាយកំពែងស្រុកនិងទ្វារជាយ៉ាងសន្ធឹកសន្ធាប់ណាស់ ។

គួនអ៊ី ឃើញសត្រូវវាយកទម្លាយកំពែង និងទ្វារជាខ្លាំងសន្ធឹកសន្ធាប់ណាស់ ក៏ដេញទាហានឲ្យប្រុងប្រយ័ត្នទ្វារ តែដោយឃើញថាពល

យោធារបស់ខ្លួនមានតិចប្រហែល ៣១០ នាយ ហើយពួកមាត់ទាហាន ស្រុកហៅឈ្មោះអាហាន ដែលជាបងប្អូននឹងគ្នា មិត្តសំឡាញ់នឹងគ្នា ឲ្យរះចេញមកពីក្នុងស្រុកនោះ អស់ទាហានទាំងក្នុង ក៏ឡើងតាមលើកំពែង លោតចុះចេញទៅជាច្រើនណាស់, ទាហានគួនអ៊ូក៏កាន់តែលេសទៅ នៅតិចស្តើងស្តួច, ឯកងទ័ពដែលមានសំបុត្រឲ្យទៅសុំនោះ ក៏មិនឃើញ មកដល់ ទឹងរែគិតរកឧបាយក្នុងកលសឹកប្រការម្តេច ក៏គិតមិនលេចមិន យល់សោះ ទើបគួនអ៊ូនិយាយនឹងហាងហ៊ូថា យើងនឹករឭកដល់ពាក្យអ្នក ដែលនិយាយរំឭកខ្ញុំពីគ្រានោះ ព្រោះខ្ញុំមិនជឿស្តាប់ពាក្យអ្នក បានជា ថ្សស់ខ្លាយឲ្យលំបាកចិត្តដល់ទីនេះ, បើដូច្នេះ យើងនឹងគិតប្រការម្តេច ទើបនឹងមានជ័យជំនះដល់សត្រូវនេះបាន ?

ហាងហ៊ូ ឮគួនអ៊ូនិយាយដូច្នោះ ក៏យំះហើយថា សត្រូវគ្រានេះមាន កម្លាំងច្រើនណាស់, សព្វថ្ងៃនេះ ទោះបីជាមានល្បីកេរ្តិ៍ឈ្មោះដូចយ៉ាង លោកពោញជាមនុស្សល្អមានថ្វីដៃខ្លាំងពូកែយ៉ាងណា ក្នុងការសង្គ្រាមនោះ ទោះបីជាដែលមិនស្លាប់ក្តី ក៏គិតតែនឹងយកជ័យជំនះសត្រូវ ទៅតយកស្រុកវិញ, ពុំបានទេ ៗ ទៀតឡើយ ឮហាងហ៊ូថាដូច្នេះ ក៏ឆ្លើយថា យើងមានសំបុត្រ ទៅសុំកងទ័ពឡៅហាងនិងបេងគាត់ ខាងទិសឯជើងឲ្យចុះមកជួយ ក៏ បាត់ឈឹងសូន្យ មិនឃើញមកសោះ, ខ្ញុំគិតឃើញថា គួរនឹងរំសាយទ័ព

ត្រឡប់រត់ចេញពីស្រុកបេកសៀវទៅ ដូចជាស្រួលជាងទៅ, បើកាលណាបានទៅដល់ស្រុកសៃឈូនហើយ សឹមចាត់ចែងតែងកងទ័ពរើសយកតែទាហានដែលមានថ្វីដៃច្រើន លើកត្រឡប់មក នឹងទៅវាយយកស្រុកកេងជីវិញឲ្យបាន ។

គួនអ៊ិ ក៏យល់ឃើញស្របដូច្នោះផង, ខណៈនោះ គួនអ៊ូ ហាងហ៊ុ ទៀវល៊ុយ ក៏នាំគ្នាឡើងទៅលើសើនបន្ទាយ ក្រឡេកមើលទៅជុំវិញ ឃើញសត្រូវនៅចាមព័ទ្ធខាងទិសឧត្តរនោះស្ងឹងស្ងួច ក៏ឲ្យហៅក្រូអ្នកស្រុកមកប្រឹក្សាថា យើងនឹងចង់ទៅស្រុកសៃឈូនតាមទិសឧត្តរនោះនឹងបានឬមិនបាន ? អ្នកស្រុកឆ្លើយថា បើនឹងទៅស្រុកសៃឈូនតាមទិសឧត្តរនោះក៏បាន ព្រោះមានផ្លូវកាត់មួយត្រង់ទៅប្រហែល ៣០ ថ្ងៃទើបដល់ តែផ្លូវនោះដាច់ស្រយាលឆ្ងាយភូមិស្រុក ព្រោះមានច្រកជ្រោះជ្រលងជងស្ទឹងក្នុងកៀនភ្នំជាច្រើនអន្លើណាស់ ។ គួនអ៊ូ ក៏បង្គាប់ទាហានថា ពេលយប់នេះ យើងនឹងលើកចេញទៅស្រុកសៃឈូនតាមទិសឧត្តរ, ហាងហ៊ុ ក៏ហាមឃាត់ថា ខ្ញុំបានឃើញថានឹងទៅតាមផ្លូវតូចនោះមិនស្រួលទេ ក្រែងសត្រូវទៅពួនបង្កប់កងទ័ពទុកក្បែរផ្លូវនោះ បើទៅតាមផ្លូវធំយូរមែន តែដើរស្រួលមិនព្រួយនឹងភ័យភិត ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

( ក )

លោក ឌឹក-គាម ប្រមូលរៀបរៀង

ពុទ្ធគុណ : លោក ប៊ូ ប៉ូ, ទ.ក. ១១, ទំព័រ ៨៧៥, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

ពុទ្ធឃោសប្បវត្តិ : លោក អាចារ្យ ឈឹម-ស៊ុំ, ទ.ក. ១២៣, ទំព័រ ១៤៣, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

ពុទ្ធជីវប្បវត្តិ : ព្រះមហា ប៉ាង ខាត់, ទ.ក. ៤, ទំព័រ ៣៦១, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

ពុទ្ធនិយមនិងជាតិនិយម : លោកផ្គលេខាធិការ សូ-ណែម, ទ.ក. ១១, ទំព័រ ១២០៥, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

ពុទ្ធបរិស័ទគឺអ្នកណា : ឃុនបណ្ឌាទក្ស ប៊ូ-ប៉ូ, ទ.ក. ១២៣, ទំព័រ ៦៥៦, ឆ្នាំ ១៩៥៤, (ម.៥២/២៦) ។

ពុទ្ធបិតុបរិនិញ្ញាន : ព្រះមហា ជូ-សុទ្ធ, ទ.ក. ១១, ទំព័រ ៩៦៣, ឆ្នាំ ១៩៥១, (ម.៥២/២៩) ។

ពុទ្ធប្បវត្តិ ( រៀបរៀងតាមលំដាប់ ង-មោ-ភា-១ ): ទ.ក. ៤-៥-៦, ទំព័រ ៩៣, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

ពុទ្ធប្បវត្តិ (កាព្យ) : លោកអាចារ្យ មៀវ-នន្ទ ទ.ក. ១២, ទំព័រ ៦០៧, ឆ្នាំ ១៩៤៦, (ម.៥២/១៨) ។

ពុទ្ធប្បវត្តិសង្ខេប : ឃុនសិរីមេធ ស្រី-អ៊ូ, ទ.ក. ១០, ទំព័រ ៧៨៩, ឆ្នាំ ១៩៤៨, (ម.៥២/២០) ។

ពុទ្ធពង្សាវតារ : លោក ល្វីហ៊ីណូត៍, ទ.ក. ១, ទំព័រ ៦៣, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

ពុទ្ធរូបសិរីទ្ធិ ៣ អង្គ : ការប៉ុឡេស, ទ.ក. ៤, ទំព័រ ១៩, ឆ្នាំ ១៩៣០, (ម.៥២/៣) ។

ពុទ្ធសរណគាថា : មហា ហ៊ុន-ប្រិញ, ទ.ក. ៣, ទំព័រ ២០៤, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

ពុទ្ធសាសនបណ្ឌិត្យនិងពិតណាអក្ខរជាតិ : លោកចាប-ពិន, ទ.ក. ៣, ទំព័រ ២៨៤, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

ពុទ្ធសាសនាធិប្បាយ : ព្រះបាឡាត់ ឌូ-ឌម, ទ.ក. ១, ទំព័រ ១៦, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

ពុទ្ធសាសនាធុរកថា : ព្រះមហា ព្រហ្ម-មារិទ្ធ, ទ.ក. ២, ទំព័រ ១២១, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

ពុទ្ធសាសនាធៀបសាសនាដទៃ : លោកជា-យូ, ទ.ក. ៧, ទំព័រ ៦១១, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

ពុទ្ធសាសនានិងគ្រិស្តសាសនា : លោកក៏យ-ប៊ុក, ទ.ក. ២, ទំព័រ ១១៨, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

ពុទ្ធសាសនាតាមយោបល់របស់ចាកិនសែស [អ៊ិតា] ទ.ក. ២៣, ទំព័រ ៥, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

ពុទ្ធសាសនានិងរកហារសាសនា : លោក ម៉ុញ-ណាគ្រី តំណាងរាស្ត្រ, ទ.ក. ១, ទំព័រ ៤៣, ឆ្នាំ ១៩៥០, (ម.៥២/២២) ។

ពុទ្ធសាសនានៅប្រទេសកម្ពុជា : លោក ទៀង-គៃឃុន, ទ.ក. ៥, ទំព័រ ៤១២, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

ពុទ្ធសាសនានៅប្រទេសជប៉ុន : លោក ប៊ូ-ប៉ូ, ទ.ក. ៦, ទំព័រ ៤១៦, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

ពុទ្ធសាសនានៅអាស៊ីកណ្ដាលនិងអាស៊ីខាងកើត : លោកដេម៉ាវៃគត, ទ.ក. ៥, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម.៥២/១២) ។

ពុទ្ធសាសនា ២៥០០ : ទ.ក ៥, ទំព័រ ១, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

---

ពេជ្រព្រះកថា : លោក សិន-ហ៊ាន, ទ.ក. ១, ទំព័រ ៣៤, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

ពេទ្យសំណាង (រឿង) : ឃុនសុវត្ថិវេទ យូរ-អ៊ុន, ទ.ក. ១២,
ទំព័រ ៦៥៦, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

ពោធិគយា : ទ.ក. ១៨, ទំព័រ ១៤, ឆ្នាំ ១៩៤១,
(ម.៥២/១៣) ។

ព្រះថេរតីរូបធិមន្តមកពីលង្កា នៅនគរវត្តខេត្តសៀមរាប : ព្រះមហាកែ-អឿន, ទ.ក. ៨, ទំព័រ ៦៣២, ឆ្នាំ
១៩៥២, (ម. ៥២/២៤) ។

ព្រហ្មចរិយកថា : ព្រះមហាសែស, ទ.ក ១-២-៣, ទំព័រ ៣,
ឆ្នាំ ១៩៣៨, (ម.៥២/១០) ។

ព្រះញាណ-ឈឹង : ទ.ក. ៨, ទំព័រ ៦៩៧, ឆ្នាំ ១៩៥៨,
(ម.៥២/៣០) ។

ព្រះបាទអសោក : ទ.ក. ១៥, ទំព័រ ៣, ឆ្នាំ ១៩៤១,
(ម.៥២/១៣) ។

ព្រះនិញ្ញាន (ភិក្ខុនារីនៅលង្កាទ្វីប) : ក្រមការ ជុំ ម៉ៅ,
ទ.ក. ៩, ទំព័រ ២៩, ឆ្នាំ ១៩៣០, (ម.៥២/៣០) ។

ព្រះបច្ចិមកិច្ចារបស់ព្រះដ៏មានព្រះភាគ : លោក ប៊ូ-ប៉ូ,
ទ.ក. ៤, ទំព័រ ៣៥១, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

ព្រះបាទជ័យវរ្ម័នទី ៧ និងប្រទេសកម្ពុជា : លោក
អាចារ្យ មៀវ-នន្ទ, ទ.ក. ២ ទំព័រ ៥៧ ឆ្នាំ ១៩៤៧,
(ម.៥២/១៩) ។

ព្រះបាទក្រុសរ៉ាឧសាជនិងព្រះនាងសេរីយោរិស្ពាធិ : អ្នកស្រី
សារិៈយ៉ាន, ទ.ក. ៣, ទំព័រ ២៣៨, ឆ្នាំ ១៩៥៦,
(ម.៥២/២៨) ។

ព្រះបាទអសោកមហារាជ : ទ.ក. ២២, ទំព័រ ៣, ឆ្នាំ
១៩៤១ (ម.៥២/១៣) ។

ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ព្រះចៅក្រុងលាវ
ស្ដេចចូលក្រសាលក្នុងព្រះរាជបណ្ណាល័យកម្ពុជា :
ទ.ក. ៥, ទំព័រ ៤៧, ឆ្នាំ ១៩២៧, (ម.៥២/២) ។

ព្រះពុទ្ធរូបដ្ឋកក់ ១ អង្គដែលគេយើបនឹងគេឃើញក្នុង
ទីប្រាសាទបាយ័ន (អំពី) : ទ.ក. ១២, ទំព័រ ១, ឆ្នាំ
១៩៣៥, (ម.៥២/៧) ។

ព្រះពុទ្ធនិងលទ្ធិព្រះពុទ្ធសាសនា លោក ញ៉ែម-ទឹម, :ទ.ក.
១០, ទំព័រ ១០៨១, ឆ្នាំ ១៩៦០, (ម ៥២/៣២) ។

ព្រះពុទ្ធសាសនាក្នុងសមុទ្រខាងត្បូង គឺកោះថ្វាចាលី

និងកោះសុមាត្រា : ទ.ក. ១៥, ទំព័រ ៣, ឆ្នាំ ១៩៤១,
(ម.៨២/១៣) ។

ព្រះពុទ្ធសាសនាជាសាសនានាំទៅកាន់សេចក្ដីសុខ :
លោក ក៊យ-ប៊ុក, ទ.ក. ១, ទំព័រ ១០, ឆ្នាំ ១៩៦០,
(ម.៨២/៣២) ។

ព្រះពុទ្ធសាសនាដែលត្រូវគេបន្លំបង្ខូច : លោក
ចេង - ជ្រីវ, ទ.ក. ៩, ទំព័រ ៨៧០, ឆ្នាំ ១៩៦៣,
(ម.៨២/៣៨) ។

ព្រះពុទ្ធសាសនានិងអពុទ្ធសាសនិក : លោក ចេង-ជ្រីវ,
ទ.ក. ១, ទំព័រ ១, ឆ្នាំ ១៩៦៤, (ម.៨២/៣៦) ។

ព្រះពុទ្ធសាសនានៅប្រទេសចិន : លោក ក៊យ-ប៊ុក, ទ.ក.
៨, ទំព័រ ៥៦៣, ឆ្នាំ ១៩៥២, (ម.៨២/២៤) ។

ព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌូណេស៊ី : លោក អង់-
ដេមីក្ងូក, ទ.ក. ៣, ទំព័រ ៣, ឆ្នាំ ១៩៤១, (ម.៨២/១៣) ។

ព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌា : លោកឌិក - គាម,
ទ.ក. ១១, ទំព័រ ១១២៩, ឆ្នាំ ១៩៦៣, (ម.៨២/៣៨) ។

ព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក : លោក ឌ-គាម,
ទ.ក. ១២, ទំព័រ ១២១២, ឆ្នាំ ១៩៦៣, (ម.៨២/៣៨) ។

ព្រះពុទ្ធសាសនារបស់ជប៉ុន : លោក ប៊ុ-ណ្ណ, ទ.ក. ៤-៥-៦, ទំព័រ ១៩, ឆ្នាំ ១៩៣៦, (ម.៥២/ឆ) ។

ព្រះពុទ្ធសាសនាលទ្ធិយោគ : ក្រមការ ជុំ-ទៀ, ទ.ក. ៧-១២, ទំព័រ ៧៧, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

ព្រះមហាវិហារពុទ្ធគយា : មហាក្រសេម ទ.ក. ៤-៥-៦, ទំព័រ ១៦.៣, (ម.៥២/១១) ។

ព្រះមហាសីលវ័ណជ : លោក ហេង-សំអាន, ទ.ក ៤, ទំព័រ ៣៤៤, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

ព្រះរដ្ឋបាល ខ្មែរ : លោក ចន្ទ-ន៍, ទ.ក. ១២, ទំព័រ ១៣៤០, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

ព្រះរាជតំណាក់ពិធីបុណ្យព្រះជាតិសេតា ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស : ទ.ក. ៥, ទំព័រ ១, ឆ្នាំ ១៩២៧, (ម.៥២/២) ។

ព្រះរាជក្រឹត្យក្រមចៅហ្វាយស្រុក : ហ្លួងទិពន្ធមន្ត្រី ញ៉ុក-ថែម, ទ.ក. ១០, ទំព័រ ៦៧, ឆ្នាំ ១៩៤៥, (ម.៥២/១៧) ។

ព្រះរាជក្រឹត្យក្រមឧសភរិយា : ហ្លួងទិពន្ធមន្ត្រី ញ៉ុក-ថែម, ទ.ក. ៨, ទំព័រ ១១, ឆ្នាំ១៩៥០, (ម.៥២/២២) ។

ព្រះរាជដំណើរនៃសម្តេចព្រះបរមរាជបុត្រាទី ១ ស្តេច

យានទៅកាន់ខេត្តបាត់ដំបង : លោក ឌុ - គាម ទ.ក. ៨, ទំព័រ ៨៧០, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

ព្រះរាជដំណើរសម្តេចព្រះសុម្រាធិបតីព្រះវង្សរាជថ្នាក់ទី ២ គណៈធម្មយុត្តិកនិកាយ : ទ.ក. ៦, ទំព័រ ៦៤-, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ព្រះរាជនិពន្ធរាមកេរ្តិ៍ : លោកឌុ - គាម, ទ.ក. ១១, ទំព័រ ៣០៧, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

ព្រះរាជដំណើរសម្តេចព្រះឧបយុវរាជទៅកាន់កោះសិរីលង្កាក្នុងពិធីបុណ្យព្រះពុទ្ធជយន្តិ : លោក ពៅ ប៊ុក, ទ.ក. ១០, ទំព័រ ៩៤៩, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

ព្រះរាជទានតាំងសមណស័ក្តិនៅវត្តបទុមវតី : ព - ប, ទ.ក. ១១, ទំព័រ ៦១៣, ឆ្នាំ ១៩៤៤, (ម.៥២/១៦) ។

ព្រះរាជពង្សាវតារ : អ្នកឧកញ៉ា ឈឹម-ក្រសេម, ទ.ក. ២, ទំព័រ ៨១, ឆ្នាំ ១៩៤៩, (ម.៥២/២១) ។

ព្រះរាជពិធីបួងសួងលាព្រះបំណន់ នៅខេត្តសៀមរាប និងព្រះវិហារសួគ៌ : ទ.ក. ៧, ទំព័រ ១៤២៣, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

(នៅមានត)

# អត្ថបទផ្នែកទំនៀមទម្លាប់

## រឿងភ្នំក្រោម

នៅខេត្តសៀមរាប មានភ្នំមួយឋិតនៅក្បែរមាត់ទន្លេសាប ចម្ងាយ ៨ គីឡូម៉ែត្រ ខាងត្បូងឆៀងខាងលិចក្រុងសៀមរាប ។ ភ្នំនេះមានឈ្មោះថា ភ្នំក្រោម មានទំហំតូចល្មម នៅលើខ្នងភ្នំ មានប្រាសាទបុរាណ និងវត្តព្រះសង្ឃ មិនសូវមានដើមឈើធំ ៗ ដូចភ្នំដទៃទៀតទេ ។ ដោយហេតុភ្នំនេះឋិតនៅជិតទន្លេសាប ជាទីចាប់អារម្មណ៍នៃអ្នកទេសចរ ក្នុងការទស្សនាទន្លេដ៏ធំធេងនេះ រាជការបានស្ថាបនាផ្លូវថ្នល់ ឡើងទៅដល់កំពូលភ្នំ ។

តាមរឿងព្រេងនិទានដែលមានដំណាលត ៗ មកថា ក្នុងសម័យដែលព្រះរាម កសាងថ្នល់ឆ្លងកាត់សមុទ្រទៅកាន់កោះលង្កា ដើម្បីច្បាំងដណ្ដើមយកនាងសីតាពីក្រុងរាពណ៍មកវិញនោះ សេនារបស់ព្រះអង្គដែលមានហនុមាន និងអង្គទជាដើម បាននាំគ្នាជញ្ជូនយកថ្មមកកសាងថ្នល់នេះ ដោយចាត់ឲ្យអង្គទ និង ពួកពលឯទៀត ទៅជញ្ជូនយកថ្មមក, ឯហនុមាន និង ពិភេកជាអ្នកទទួលយកទៅរៀប ។ ពួកអ្នកជញ្ជូនមានកម្លាំងខ្សោយ មិនអាចនឹងនាំយកថ្មឲ្យបានច្រើនដូចល្មមនឹងកម្លាំងហនុមានដែលទទួលយកទៅរៀបហ៊ាងហ៊័សនោះ ហនុមានមានពេលទំនេរច្រើន ក៏បបួលពិភេកលេងចត្រង្គកំដរពេលវេលាទៅ, នៅពេលដែលគេជញ្ជូនថ្ម

មកដល់ គាត់គ្រាន់តែយកដៃឆ្វេងទៅទទួលប៉ុណ្ណោះ ម្ល៉ោះហើយអង្គរក្សក៏ស្ដីឲ្យថា គេខំធ្វើការស្ទើរស្លាប់ បង់ដងនាំគ្នាលើកចត្រង្គ យកតែដៃឆ្វេង ១ មកទទួលថ្វាយ គ្មានគិតខំជួយធ្វើការសោះ ៗ ដូច្នោះ ហនុមានក៏ចាត់អង្គទនិងពួកពលឲ្យនៅចាំទទួលរៀបរៀបវិញម្ដង ខ្លួនគាត់ជាអ្នកទៅដញ្ញានយកមកឲ្យ ៗ ដោយហេតុហនុមាន ជាសេនាដែលមានកម្លាំងខ្លាំងមហិមា ផង មានឫទ្ធានុភាពពូកែអស្ចារ្យផង គាត់ក៏យកថ្មធំ ១ ជាច្រើនមកបង្កិនទីកេមរបស់គាត់ ហើយដៃទាំងពីរទ្រភ្នំមួយម្ខាង យកមកប្រគល់ឲ្យ ៗ អ្នកចាំទទួលរាល់តែខំស្រាយយកថ្មពីកេមគាត់ មិនទាន់បានទទួលយកភ្នំពីដៃ គាត់ធុញទ្រាន់ខឹងគេធ្វើការយឺតពេក ក៏បោកភ្នំទៅនឹងដៃខាងឆ្វេងផ្ទប់រាំងនឹងដៃខង ដើម្បីបញ្ជូនឲ្យអ្នកទទួល, ភ្នំនោះក៏ត្រឡប់កំពូលចុះក្រោម បាតផ្កាប់ឡើងលើទៅ ៗ

ដោយមានរឿងរ៉ាវដូចពណ៌នាមកនេះ ទើបគេសន្មតហៅភ្នំនេះថា "ភ្នំក្រោម" ព្រោះកំពូលផ្កាប់ទៅនៅក្រោម ហើយដោយហេតុបាតភ្នំឡើងលើ បានជាមិនសូវមានដើមឈើធំ ១ ដូចភ្នំឯទៀត ព្រោះឈើធំ ១ ដែលដុះនៅលើភ្នំនេះពីមុន ផ្កាប់ទៅនៅក្រោម ត្រូវភ្នំសង្កត់អស់ទៅ ៗ

នេះជារឿងព្រេងដែលរាសទុំពីសម័យបុរាណ បានដំណាលតៗមក មិនមានហេតុផលគួរឲ្យជឿបានឡើយ ព្រោះរឿងរាមកេរ្តិ៍ជារឿងរបស់សាសនាព្រាហ្មណ៍ដែលគេហៅវេទិក បាននិពន្ធឡើងជាពាក្យកាព្យ ភាសា

សំស្ក្រឹត ដោយបានអះអាងថា រឿងនេះ កើតមានមករាប់ម៉ឺនឆ្នាំហើយ ដូច្នេះ ក្នុងសម័យនោះ កម្ពុជាយើងនៅជាទឹកសមុទ្រនៅឡើយ មិនទាន់កើតបានជាផែនដីទេ ហើយរឿងរាមកេរ្តិ៍នេះទៀតសោត ក៏ព្រះពុទ្ធសាសនារបស់យើង បានបដិសេធថាជារឿងមិនពិតឯណ៏ តែបើទោះជាថាពិតទៅវិញ ក៏ថ្នល់ដែលព្រះរាមកសាងឆ្លងមហាសាគរនោះ ឋិតនៅត្រង់ចន្លោះកោះលង្កា និង ដែនឥណ្ឌាឯណោះទេ មិនមែនឋិតនៅក្នុងដែនដីកម្ពុជាឡើយ ព្រោះថ្នល់នេះ ព្រះរាមស្ថាបនាឆ្លងសមុទ្រ មានឆ្លងទន្លេសាបត្រង់ខេត្តសៀមរាបនោះកាលណា ។ ប៉ុន្តែដោយហេតុជនជាតិខ្មែរយើងពីបុរាណកាល ធ្លាប់គោរពប្រតិបត្តិសាសនាព្រាហ្មណ៍ ក៏នាំគ្នាជឿនិងគោរពរឿងរាមកេរ្តិ៍នេះយ៉ាងស៊ប់ស្ងួនទៅ ហើយដោយចូលចិត្តនិយម ជឿថាតួអង្គក្នុងរឿងនោះ ជាសញ្ជាតិខ្មែរផង ក៏ខិតខំស្វែងរកភស្តុតាងមកបញ្ជាក់ដូចរឿងភ្នំក្រោមនេះជាដើម ក៏មិនប្លែកគ្នាពីរឿងភ្នំនាងកង្រីក្នុងខេត្តកំពង់ឆ្នាំងដែរ ។

ឯសេចក្តីពិតវិញ ភ្នំនេះបានជាមានឈ្មោះថា "ភ្នំក្រោម" ព្រោះឋិតនៅត្រង់ភាគខាងក្រោមនៃស្ទឹងសៀមរាប ឯភ្នំដទៃ ៗ ទៀត សុទ្ធតែឋិតនៅភាគខាងលើទាំងអស់ ។ ឯហេតុដែលភ្នំនេះ មិនសូវមានដើមឈើធំ ៗ ព្រោះឋិតនៅតំបន់ព្រៃនោម ។

ព្រិន្ទបាលឯក ជា-ប៉ូវ ធ្វើការនៅការិយាល័យទី ៥

នៃអគ្គសេនាធិការយោធពលខេមរភូមិន្ទ

# ប្រវត្តិស្រុកត្បូងឃ្មុំ

ទី៥

## អ្នកតាបេង

ស្រុកត្បូងឃ្មុំនេះ កាលដើមឡើយជាខេត្តមួយ ហើយអភិបាលខេត្តនោះមានងារជាអរជូន ប៉ុន្តែពីមុនមកមិនដឹងជាមានឈ្មោះជាស្រុកអ្វីទេ, តែបើតាមការដំណាល ហើយមានគោលជាក់ណែលនៅដល់សព្វថ្ងៃ ដែលគួរយកជាការបាននោះ មានដូចតទៅ ៖

ដើមឡើយ មានវត្តមួយនៅក្នុងឃុំវិហារហ្លួង ស្រុកត្បូងឃ្មុំ ហៅជា វត្តទួលក្តី (មិនដឹងពីពុទ្ធសករាជប៉ុន្មាន)? លោកគ្រូចៅអធិការវត្តនេះ ឈ្មោះមិនប្រាកដ មានប្អូនស្រីក្រមុំម្នាក់ ។ វត្តនេះ មានអ្នកតាបុស់រិទ្ធិមួយ មានឥទ្ធិឫទ្ធិខ្លាំងពូកែណាស់ អាចក្លែងខ្លួនធ្វើជាមនុស្សធម្មតាបាន, នៅថ្ងៃបុណ្យទាន ឬថ្ងៃសីល ដែលមានធ្វើកិច្ចរាប់បាត្រក្នុងវត្តនោះ អ្នកតា តែងតែក្លែងខ្លួនជាបុរសកម្លោះម្នាក់ ស្លៀកពាក់ស្អាតស្អំ កាន់ផ្តិលសំរិទ្ធិ រែកសំរិទ្ធិ យកបាយទៅរាប់បាត្រជាមួយនឹងអ្នកស្រុករាល់ៗពេល, ដាក់បាត្ររួច ចុះពីលើសាលា ក៏បាត់ខ្លួនភ្លាមមួយរំពេច, អ្នកស្រុកតែងសួរគ្នាទៅវិញទៅមក ដោយនឹកសង្ស័យនឹងមនុស្សចម្លែកនេះពន់ពេកណាស់, គេចេះតែឆ្ងល់ ដោយមិនដឹងជាទីលំនៅបុរសនោះ នៅឯណា ស្រាប់តែឃើញដល់វត្តតែម្តង ។

ក្រោយមកអ្នកតានោះ ទៅលបស្រឡាញ់មេសោមត្រីជាមួយប្អូន ក្រមុំលោកគ្រូមេវត្ត, លោកគ្រូ លុះដឹងថា ប្អូនស្រីមានប្រុសសហាយ ក៏ហៅប្អូនមកសាកសួរតាមដំណើរ នាងនោះក៏ទូលថា បានស្រឡាញ់ ប្រុសម្នាក់មែន តែឥតមានអ្នកណាដឹកនាំទេ ពេលយប់ស្រាប់តែឃើញ ប្រុសនោះចូលទៅដេកជាមួយខ្ញុំតែម្ដង តែនាងចាប់ពាល់ខ្លួនបុរសនោះ មិនត្រូវសោះ ហាក់ដូចជាស្រមោល ។ លោកមេវត្តបានស្ដាប់ ប្អូនស្រីរាយរាប់គ្រប់សព្វហើយ លោកជ្រាបភ្លាមថា គ្មាននរណាទេ ពិតជាអ្នកតារូបសំរិទ្ធនោះឯង ព្រោះវាមានឫទ្ធិខ្លាំងពូកែណាស់, លោក គ្រូខ្ញាល់ខឹងអ្នកតាសំរិទ្ធនោះជាខ្លាំង ក៏ប្រើគេឲ្យទៅជីករណ្ដៅទៅទួល មួយខាងជ្រុងអាគ្នេយ៍វត្ត ចម្ងាយប្រមាណជា ២០០ ម ឬ ៣០០ម ពីវត្ត, ជីករួចហើយ លោកយករូបសំរិទ្ធនោះ ទៅកប់ផ្កាប់ក្បាលចុះ ក្រោម លុបដីហើយ យកដើមបេងមួយទៅដាំសង្កត់លើរូបនោះ ។ ទួលនោះសព្វថ្ងៃគេហៅថា ទួលអ្នកតាបេង ។

ក្រោយមក មេវត្តក៏អនិច្ចធម្មបាត់ទៅ នៅសល់តែភិក្ខុ-សាមណេរ តិចតួច, ក្នុងវត្តទួលគីនេះ មានយាយម្នាក់ឈ្មោះកែ គាត់ឥតមានប្ដីបងប្អូន ទេ ហើយបួសជាយាយជីនៅវត្តទួលគីនោះ ។ តមកខាងក្រោយទៀត លោកសង្ឃក្នុងវត្ត ក៏ចេះតែប៉ាត់ប៉ោយអស់រលីងគ្មានសល់ នៅសល់ តែយាយជីកែនោះម្នាក់ឯង នៅរក្សាវត្តទួលគី ។ ឯដើមបេងដែល

លោកមេវត្តដាំសន្ទត់លើរូបអ្នកតានោះ ក៏ចម្រើនធំឡើង មានសត្វឃ្មុំនៅលើមែកផង ។ តាមដំណាលថា ឃ្មុំនេះធំហើយ កាចណាស់ផ្ទិតជាភ្នាក់ប្រផាត់ដី ។ គ្រាន់តែខ្យល់បក់នាំក្លិនមនុស្សមកដល់ មេវានាំគ្នាហើរតាំងហ្វូងទៅទិចតាល់តែស្លាប់ ។ ដូចនោះ នៅខែកត្តិក–មិគ្គសិរ – បុស្ស ដែលជារដូវខ្យល់ខ្លាំងបក់មកពីទិសខាងជើង យាយតា តែងតែប្រាប់អ្នកដំណើរ ឲ្យដើរពីខាងត្បូងឃ្មុំ តែដើរពីខាងជើងក្លិនរមែងផាត់មកដល់ឃ្មុំ ៗ ទំងហើរមកទិចស្លាប់ជាមិនខាន ។ ពាក្យថា “ដើរខាងត្បូងឃ្មុំ” នេះហើយ ដែលជាដើមកំណើតឈ្មោះខេត្តត្បូងឃ្មុំនេះ, មិនមែនគជឃ្មុំម្យ៉ាងដែលគេប្រើធ្វើត្បូងចិញ្ចៀននោះទេ ។

តមកខាងក្រោយ ដើមបេងនោះ ត្រូវដើមជ្រៃដុះរួតរឹតខ្លាំង ក៏ងាប់ទៅ ដើមជ្រៃក៏លូតលាស់បែកមែកសាខាឡើង នៅកន្លែងដើមបេងនោះ ។ តមកមែកជ្រៃក៏បាក់ចេះលែងអស់នៅសល់តែគល់ទំហំ ២ ម ដុះស្ទឹកតាប ៗ ទឹងដី ។ អ្នកមានបណ្ដាស័ក្តិដើរកាត់មុខអ្នកតាបេងនេះមិនបានទេ, សព្វថ្ងៃមានផ្លូវ ១ ពីខាងត្បូង, ១ ពីខាងជើងអ្នកតានេះ ។

អ្នកតានេះ សម្រាប់ចៅហ្វាយខេត្តត្បូងឃ្មុំឡើង កាលបើមានអស់លោកណាទៅធ្វើជាចៅហ្វាយខេត្ត ឬ ចៅហ្វាយស្រុក ដែលមានងារជាអរជូន ត្រូវឡើងអ្នកតានេះ ខានមិនបានទេ ។

តាមសេចក្ដីឲ្យការណ៍ពីលោក ឧកញ៉ា កែវ-ហង្ស ចាងហ្វាងរ៉ៃត្រែត នៅឃុំស្នួង (ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម) ។

# ជីវប្រវត្តិ

## របស់ខ្ញុំឈ្មោះ អៀង-សាយ

(គ)

នៅសាលាពេនា គេដឹងថា ខ្ញុំចេះអក្សរ ចេះភាសាបារាំង ទើបកាលដែលគេរុះរើផ្ទះរៀនចេញពីក្នុងភូមិ មកតាំងនៅសាលាពេនា ដែលទើបនឹងសង់ហើយថ្មី នៅខាងជើងភូមិជាប់នៅខាងលិចវាលមេរុនោះ គេតាំងខ្ញុំឲ្យធ្វើជាមៀមប៉ូង គឺឲ្យកាន់បញ្ជីកត់ឈ្មោះសិស្សប្រុស-ស្រីណាដែលបាត់មុខមិនមករៀន ។ ឲ្យវាយជួងតាមម៉ោងចេញ-ចូល ចែកស្លាកលេខសំគាល់ខ្លួនដល់សិស្សទាំងអស់ វេលាចូលទទួលយកស្លាកវិញ វេលាចេញ និងកាន់កូនសោរ ។

មុខការបែបនេះ គេឲ្យប្រាក់ខែ ១១ រៀល ក្នុង ១ ខែ នាំឲ្យសិស្សធំៗ អាយុច្រើនជាងខ្ញុំ គេច្រណែន តែមិនដឹងធ្វើម្តេច បើគេរើសយកខ្ញុំឲ្យធ្វើ ដោយឃើញខ្ញុំមានចំណេះចេះដឹងពូកែជាងគេទាំងអស់ៗ

ដល់រៀនបាន ១ ឆ្នាំមកទៀត គេសួរចិត្តពួកសិស្សថ្នាក់លេខ ១ អ្នកណាចង់ទៅរៀនខាងជាងទង, ជាងឆ្លាក់, ជាងសិតរូបស្ពាន់, ជាងសូនដីធ្វើពុម្ព, ជាងស្នាប់មុខយក្ស និងជាងគូរផែនទីសំណាក់ ។

ខ្ញុំស្ម័គ្រចិត្តមកខាងគំនូរផែនទីសំណាក់ លុះរៀនបាន ១ ឆ្នាំក្រោយមកទៀត ត្រូវប្រឡងចេញយកសញ្ញាប័ត្រ សំគាល់ថា បាន

រៀនបេះចប់ហើយ ។ ខ្ញុំបានទទួលឌីប្លូមដឺហ្វាំងដេទុតឱ្យរ៉ើយេដា ពីសាលារចនា ។

ដូចជាពេលនោះ មានសំបុត្រពីលោករ៉េស៊ីដង់នៅខេត្តកំពង់ឆ្នាំង ផ្ញើមកលោកបានហ្វាន់សាលារចនា សូមគ្រូបង្រៀនគំនូរម្នាក់ យកទៅឲ្យបង្រៀនសិស្ស នៅសាលាកំពង់ឆ្នាំង ដ្បិតគេទើបនឹងបង្កើតថ្នាក់បង្រៀនគំនូរថ្មី មិនទាន់មានគ្រូ ។

គួរកត់សំគាល់ត្រង់នេះថា សិស្សនៅថ្នាក់លេខ ១ ខាងគំនូរមានគ្នា ១០ នាក់ លោកបានហ្វាន់តម្រូវមកឈ្មោះខ្ញុំថា ត្រូវឲ្យទៅធ្វើគ្រូបង្រៀនគំនូរឯសាលាកំពង់ឆ្នាំង ។

ខ្ញុំក៏រៀបចំដំណើរចេញពីភ្នំពេញទៅ ក្រោយដែលបានទទួលសំបុត្រពីលោកបានហ្វាន់ កាន់យកទៅជាមួយផង គឺក្នុង គ.ស. ១៩១៩ ដែលខ្ញុំទើបនឹងបានអាយុ ១៩ ឆ្នាំ ។

កាលដែលខ្ញុំចេញពីភ្នំពេញទៅកំពង់ឆ្នាំង មិនមែនទៅតែម្នាក់ឯងទេ គឺនាំប្រពន្ធទៅជាមួយផង ។

ដោយខ្ញុំមិនបានសរសេររឿង កាលដែលខ្ញុំបានប្រពន្ធនេះ គេឆ្ងល់គ្រប់គ្នា មិនដឹងថាខ្ញុំមានប្រពន្ធពីកាលណា សូមជម្រាបកុំឲ្យឆ្ងល់ថា ខ្ញុំកើតមកមានលក្ខណៈជាប្រជ្រុយជាក្រយៅពីកំណើតប្លែកពីគេខ្លះ ដោយមានយាយតាសម្នាក់ គាត់ចេះមើល គាត់ចេះទាយ មិនដឹងជាឈ្មោះអី

នៅស្រុកណា ខ្ញុំជួបនឹងគាត់នៅផ្ទះមីងឈុន នៅភូមិបឹងកំង គាត់សួរថ្ងៃ–ខែ–ឆ្នាំ ហើយចាប់ដៃខ្ញុំមើល ពិនិត្យខ្សែដៃ បាតដៃ ក្រោមដៃ មើលដៃមួយហើយមើលដៃមួយទៀត គាត់សើច ពាដៃលែងមើល និយាយថា អ្នកឯងនេះខិលខូចខាងស្រីញីណាស់ តាមទំនាយថា មានប្រពន្ធ ៣ ប្រពន្ធទី ១ មិនបានជាប់នឹងគ្នាទេ មានកូនមួយព្រាត់ប្រាស់គ្នា ឃើញតែប្រពន្ធទី ២ ស្រីនោះកើតឆ្នាំមមែ ជាគូព្រេងនឹងគ្នា បានរួមសុខទុក្ខជាមួយគ្នារហូត ។ ខ្ញុំសួរបញ្ជាក់ថា ម៉េចក៏មិននិយាយពីប្រពន្ធទី ៣ ផង ។

យាយនោះចាប់ដៃទៅមើលម្ដងទៀត រួចប្រលែងដៃខ្ញុំចេញនិយាយថា រសេមរសាមពេក ខ្ញុំមិនចង់និយាយក្រែងវាខុស ត្រង់ណាខ្ញុំដឹងច្បាស់ ទើបបានខ្ញុំហ៊ាននិយាយ តែខ្ញុំនិយាយហើយគ្មានខុសទេ ចាំមើលចុះ ។

ប្រពន្ធដែលខ្ញុំនៅកំពង់ឆ្នាំងគឺមុនដំបូង សូមកុំថាប្រពន្ធទី ១ ដូចជាយាយហោរថា ហើយសុំកុំថាប្រពន្ធដើម ដ្បិតវាជាប្រពន្ធពយរងបាន គ្នាជាប្ដីប្រពន្ធ ដោយម្ដាយខាងស្រីចាប់ខ្ញុំបាន នៅដំណេកកូនក្រមុំគេ ។ សែនខ្មោចមេបាឲ្យយកគ្នាជាប្ដីប្រពន្ធមកបានជិត ១ ឆ្នាំ ហើយទើបនាំគ្នាទៅនេះ បើគេបោះពុម្ពជីវប្រវត្តិខ្ញុំផ្សាយ ខ្ញុំជូនរូបថតនាងនោះមួយសន្លឹក ឲ្យគេពុម្ពបោះបង្ហាញមុខឲ្យគេស្គាល់ ។

ខ្ញុំបានទៅនៅធ្វើគ្រូបង្រៀនកំពូងឯងខេត្តកំពង់ឆ្នាំង ក្រោមបង្គាប់លោក

ចាងហ្វាងសាលាស្រីជាតិបារាំងឈ្មោះម៉ះសែល មានផ្ទះពេជការឲ្យខ្ញុំនៅ ធ្វើការបាន ១ ឆ្នាំ ខ្ញុំសូមលាឈប់ដោយប្រាក់ខែតិចពេក ចាយមិនគ្រប់គ្រាន់ ដ្បិតខ្ញុំមានប្រពន្ធ មានទាំងកូនប្រុស ១ ហើយខ្ញុំបានអញ្ជើញអ្នកម្ដាយខ្ញុំឲ្យទៅនៅជាមួយនឹងខ្ញុំទៀតផង, ពេលនោះ លោកស្រីដឺត គាត់មិនព្រមឲ្យឈប់ ដោយពន្យល់ខ្ញុំថា អ្នកឯងទើបនឹងធ្វើការថ្មី ហើយអាយុមិនទាន់គ្រប់ ទើបនឹងតាំងឲ្យមានឈ្មោះជាគ្រូពេញច្បាប់ ស៊ីប្រាក់ខែប្រចាំឆ្នាំមិនទាន់បាន ទើបឲ្យស៊ីប្រាក់ខែរាប់តាមថ្ងៃ ទម្រាំដល់ ១ ឆ្នាំទៀត នឹងបានប្រាក់ខែច្រើនមិនខាន ។

ខ្ញុំមិនព្រមតាមពាក្យនេះ ដោយខ្ញុំមានគំនិតគិតថា ខ្ញុំមានចំណេះចេះគូរគំនូរផាត់ពណ៌បានល្អលក់ឲ្យគេ ឬស៊ីឈ្នួលគូរឲ្យគេបានប្រាក់ច្រើនជាងធ្វើគ្រូបង្រៀន ទើបខ្ញុំចេះតែសូមឈប់ លុះដល់បានគ្រប់ ពីកំពង់ឆ្នាំងមកភ្នំពេញវិញ ។

ខ្ញុំធ្វើការរកទទួលទានបានគួរជាសប្បាយចិត្ត តែប្រពន្ធភរិយារបស់ខ្ញុំនោះ ក៏មិនចេះទុកដាក់ ខ្ញុំមានគ្រឿងមាសប្រាក់សំលៀកបំពាក់ល្អៗ ក៏យកទៅលក់បញ្ចាំយកប្រាក់លេងបៀ ខ្ញុំទំតែធ្វើការមិនសូវបានទៅណាមកណាច ម្ដងៗ ម៉ាតែនឹងបានដឹងថាអស់គ្រឿងមាសប្រាក់ ខ្ញុំមិនចេះឈ្លោះ ខ្ញុំបបួលលះលែងគ្នា តែក៏មិនព្រម ក៏សុខចិត្តចុះសន្យានឹងខ្ញុំថា ក៏លែងលេងបៀទៀតហើយ ខ្ញុំថាបើព្រមលែងលះគ្នា ខ្ញុំ

ចែកទ្រព្យរបស់ភាគកណ្តាលម្នាក់ បើពុកមិនព្រមចែកពីខ្ញុំត្រូវឈប់លេងល្បែងស៊ីសង បើមិនឈប់ហើយ ហ៊ានលួចលេង តែខ្ញុំពាន់ខ្ញុំបណ្តេញឲ្យចុះចេញតែខ្លួននិងសំលៀកបំពាក់ដែលនៅជាប់នឹងខ្លួន ពុកព្រមផ្តិតដៃលើសំបុត្រសន្យាថែបះនេះ ។ ថ្ងៃក្រោយ ពុកសូមខ្ញុំទៅលេងផ្ទះម្តាយពុកនៅមុខវាំង ជាន់នោះមានភូមិមួយហៅភូមិដងកើ ឬ ភូមិកំពង់ផែ តែឥឡូវបាក់បាត់ទៅក្នុងវទ្វេយូរហើយ ។

ពុកនៅតែលួចលេងបៀរដដែល ដោយខ្ញុំមានគំនិត ចេះគិតរកគ្នាឲ្យតាមមើល គេឃើញគេប្រាប់ខ្ញុំ ។ ទៅផ្ទុញផ្ទាល់ពុកចំពោះមុខម្តាយពុក ពុកក៏យល់ព្រមឲ្យបែកពីគ្នាក្នុងរវាងអាយុខ្ញុំបាន ២២ ឆ្នាំ ឯកូនប្រុសស្លាប់ដោយមានជម្ងឺតាំងពីអាយុទើបនឹងបានជាង ១ ខួប ។

ខ្ញុំត្រឡប់ទៅផ្ទះជាប្រុសកម្លោះទៅវិញ ខ្ញុំនឹកឃើញពាក្យយាយហោរ គាត់ទាយឲ្យខ្ញុំត្រូវណាស់ ខ្ញុំគិតរកប្រពន្ធឲ្យបានត្រឹមត្រូវ ឲ្យបានសុខសប្បាយរៀងឆ្ងាយជាមួយគ្នា គិតទៅនឹកឃើញពាក្យយាយហោរថាគូព្រេងរបស់ខ្ញុំកើតឆ្នាំមមែ ។ ខ្ញុំចេះតែឲ្យគេស៊ើបសួររកស្រីឆ្នាំមមែ ហើយល្មមនឹងស៊ីដណ្តឹងទៅគេព្រមឲ្យផង គឺថាបើឆ្នាំមមែតែកូនគេអ្នកមានបានៈយសសក្តិនោះកុំឲ្យគិត ។

ស៊ើបសួរទៅ គេថាមានកូនស្រីគេឆ្នាំមមែអាយុ ១៧ ឆ្នាំ នៅកោះឧក មានតែឪពុកគ្មានម្តាយសេនៅ មានមាមីង–ធំ ជីដូន ជីតា

នាងនោះឈ្មោះនាងសាគុំ គ្មានបងប្អូនបង្កើតទេ មានតែបងជីដូនមួយ ហើយគេថារូបពាងល្អ ឫកពាសុភាព គំនិតការយាទត្រឹមត្រូវល្អ មិនដែលទៅណាមកណាទេ នៅតែក្នុងផ្ទះ ចេះដេរប៉ាក់ល្អណាស់ គេទៅមករកជួលឲ្យដេរខោអាវញឹកញាប់ ។

ខ្ញុំឲ្យគេនាំខ្ញុំទៅរកលួចមើល តែនាងនោះដឹងខ្លួន គេពួននៅតែក្នុងផ្ទះ ខ្ញុំខាលគំនិតមិនដឹងយ៉ាងម៉េចឲ្យបានឃើញ ខ្ញុំសូមអ្នកម្ដាយខ្ញុំគាត់អញ្ជើញទៅមើលដំនួល បើគាត់ថាគួរសមហើយ ខ្ញុំនឹងឲ្យគេចូលទៅស្ដីដណ្ដឹងតែម្ដង ខ្ញុំមិនបានឃើញក៏ហើយទៅចុះ ។

ពេលដែលអ្នកម្ដាយខ្ញុំ អញ្ជើញទៅដល់ញាតិសន្ដាន បងប្អូន មាមីង ជីដូន ជីតា នាងនោះទទួលអបអរសាទរ នាំគ្នាអញ្ជើញអ្នកម្ដាយខ្ញុំឲ្យឡើងទៅលើផ្ទះ ហើយហៅនាងនោះឲ្យចេញមកសំពះសួរគួរសមនឹងអ្នកម្ដាយខ្ញុំ តែនាងនោះបិទទ្វារដាក់រនុកជាប់ខាងក្នុង មិនព្រមចេញមិនព្រមឲ្យអ្នកណាចូល ។ មាមីង ជីដូន ជីតា នឹងឪពុកនិយាយពន្យល់ឲ្យដឹងការគួរសមចំពោះភ្ញៀវ ដោយគ្រាន់តែបើកទ្វារឲ្យគេចូល បើមិនព្រមចេញ ។ និយាយល្ងួងលោមមិនព្រមចេញមិនព្រមបើក គេនិយាយស្ដីទោសគ្រប់គ្នា ក៏នៅតែមិនព្រមបើកទ្វាររហូត ទទួលពេលនោះ ដល់ពេលបាយថ្ងៃត្រង់ ញាតិសន្ដានខាងនោះ គេដាំស្លនិង គេត្រូវការយកចានបាយសម្ភុកល្អ មករៀបបាយទឹក ជូន

អ្នកម្តាយខ្ញុំនិងញាតិមិត្តស្រី ៗ ពីរបីនាក់ ដែលនៅជាមួយគាត់ តែបានអស់នោះនៅក្នុងផ្ទះធំ គ្មាននៅឯផ្ទះបាយ ទើបគេប្រឹងហៅឲ្យបើកទ្វារឲ្យគេចូលយកបាន តែនាងនោះមិនព្រមបើក ខ្លាចក្រែងគេបន្ទំចូលទៅមើលខ្លួន ៗ ចាស់ ៗ អត់ទឹងមិនបាន ក៏ស្តីបន្ទោសគ្រប់គ្នា នាំឲ្យនាងនៅខាងក្នុង យកកាំបិតកាត់វះជញ្ជាំងស្លឹក ល្មមតែបញ្ចោញបានតាមប្រហោងនោះបាន ឲ្យគេនៅខាងក្រៅយកមកដាក់បាយសម្ល ៗ

លុះដល់ប៉ុន្មានថ្ងៃក្រោយ គេនាំដំណឹងមកជម្រាបអ្នកម្តាយខ្ញុំថា គេមានធ្វើបុណ្យវិសាខបូជានៅវត្តកំសាន្ត សូមអញ្ជើញទៅចាំនៅវត្តនោះ ទើបបានឃើញកូនស្រីគេ ៗ អ្នកម្តាយខ្ញុំមិនចង់អញ្ជើញទៅទេ ដោយអាក់អន់ចិត្តពីថ្ងៃមុន ខ្ញុំខំអង្វរលុះតែព្រមនាំគ្នាបីបួននាក់ទៅ ពេលនេះទើបបានឃើញមុខ ឃើញរូបរាងនាងនោះទាំងអស់គ្នាដោយដើរវិសាខដ៏តាមកបូជា ៗ

កាលនោះ ខ្ញុំមិនបានឃើញមុខអនាគតភរិយារបស់ខ្ញុំទេ តែដោយអ្នកម្តាយខ្ញុំនិងបងប្អូនថា គួរសមល្មមហើយ ក៏រកអ្នកផ្ទះបោមហាឲ្យចូលទៅស្តីដណ្តឹង រៀបមង្គលការត្រឹមត្រូវ តាមទំនៀមទម្លាប់ខ្មែរ បានគ្នាជាប្តីប្រពន្ធពេញច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍ដាក់ជាប្រពន្ធទី ១ គឺអ្នកមេផ្ទះរបស់ខ្ញុំសព្វថ្ងៃនេះ ឈ្មោះអ្នកសាគុំ ខ្ញុំបានគាត់កាលពីអាយុបាន ២២ ឆ្នាំ គាត់អាយុបាន ១៧ ឆ្នាំ ៗ ខ្ញុំស្ទួរតែរៀនពួនលាក់ខ្លួនមិនចេញ

ជូនអ្នកម្ដាយខ្ញុំមើលនោះ គាត់ឆ្លើយថាគាត់ស្អប់ស្រីណាដែលឬថាគេចង់បាន ហើយខំតែងខ្លួនប្រាណដើរទៅឲ្យគេមើល ដោយចង់បានប្ដីពេក ក្មេងអៀនខ្មាសអស់ គាត់ថាខ្លួនគាត់មិនមែនពួកស្រីចង់បានប្ដីទេ គឺជាពួកស្រីតាមសំណាង បានប្ដីក៏យក មិនបានក៏ហើយទៅ ។

ខ្ញុំរៀបការរួចនៅឯភូមិកំពង់ចម្លង ឃុំកោះឧក ស្រុកកៀនស្វាយ ខេត្តកណ្ដាល នៅផ្ទះឪពុកក្មេកខ្ញុំ ជួបជុំគ្នានឹងដូនក្មេកផង ។

ខ្ញុំរកទទួលទានដោយគូរគំនូរផាត់ពណ៌ដោយថ្នាំទឹកក៏មាន ថ្នាំប្រេងក៏មាន គូរលើសំពត់ទេសឯក សំពត់ព្រៃសាគាំង លើក្ដារពងមូលពង ពងក្រពើនឹងពងបួនជ្រុង គូរហើយយកមកដាក់ផ្ញើលក់នៅសាលាចេនា នៅផ្សារស៊ីញែក នៅផ្ទះវឿងស៊ុង និងនៅផ្ទះហង់រ៉ ។ មានដាក់ឈ្មោះជាអក្សរបារាំង ដោយគម្រូលក់ឲ្យបារាំងយកទៅដាក់លំអក្នុងផ្ទះ ឬ ផ្ញើទៅឲ្យញាតិមិត្តនៅឯស្រុកបារាំង ។

ខ្ញុំនៅឯកោះឧក តែខ្ញុំទៅមកភ្នំពេញញយណាស់ ដោយឈ្មោះ អៀង - សែម បងខ្ញុំ និងឈ្មោះ អៀង - សឿង ប្អូនខ្ញុំធ្វើជាមេជាងការចនាអំពីស៊ីម៉ង់តនៅភ្នំពេញ មានការទាក់ទងនឹងគ្នាជានិច្ច ។

មានកាលមួយថ្ងៃនោះ ខ្ញុំមកលេងនឹងបងប្អូនខ្ញុំ ជួបនឹងមនុស្សស្គាល់គ្នាម្នាក់ គេនិយាយថា មានប្អូនគុងមកពីសាលាដែកមកសួររកឈ្មោះ សាយ ដែលចេះគូរ ជួបនឹងគេ ១ ថាគេស្គាល់ ហើយបាន

ទាំងជាទាថាចាំគេនាំដំណឹងមកប្រាប់ខ្ញុំ ។

គេថាលោកចាន់ហ្វាន់សាលាដែកជាតិប៉ាកំង មានការចង់ឲ្យឈ្មោះសាយខ្ញុំទៅជួបកុំឲ្យខាន ។

ដោយខ្ញុំទើកទ្ទួលក៏ទៅឯសាលាដែកភ្លាម ។ សូមជ្រាបថាសាលាដែកដែលប៉ាកំងហៅថាគេគូឡីសប្របៀះស៊ុយ៉ែណលនោះ នៅខាងជើងមន្ទីរពេទ្យព្រះកេតុមាលា ជាប់នឹងក្លូទ្បេសស៊ីស្ទីតពីដើម ឥឡូវនេះ សាលាដែកនោះទៅជាកេរ៍តម្កព្រះពជទ្រព្យ ឯក្លូទ្បេសស៊ីស្ទីត គឺបច្ចុប្បន្នមន្ទីររដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាលនេះ ។

ខ្ញុំបានចូលទៅជួបនឹងលោកចាន់ហ្វាន់សាលាដែក ឈ្មោះលោកបាតូលី លោកចង្អុលទៅក្រោមជើយបង្អែកកៅអី ចង្អុលទៅគំនូរដែលព្យួរនៅជញ្ជាំង សួរខ្ញុំថា អ្នកឯងឈ្មោះ សាយ ដែលគូរគំនូរអស់នេះឬអី ខ្ញុំឃើញ ខ្ញុំស្គាល់គំនូរដែលគូរលើព្រែសាតាំងរបស់ខ្ញុំ ទីងគំនូរដែលគូរលើក្តារកេងមូល កងពង់ក្រតើនោះទៀត ខ្ញុំឆ្លើយថា ទាំងអស់នេះគឺគំនូរដែលខ្ញុំបានគូរ ។ ខ្ញុំយល់ថា បានជាគេស្គាល់ហើយសួររកឈ្មោះខ្ញុំ ដោយខ្ញុំដាក់ឈ្មោះជាអក្សរប៉ាកំង ។

លោកចាន់ហ្វាន់សាលាដែកមើលមុខខ្ញុំបែបពេញចិត្តនឹងការដែលខ្ញុំបានគូរល្អ លោកសួរសោកចង់ដឹងពីរបរកេទទួលទាន ដោយគូរគំនូរលក់បានប្រាក់ប៉ុន្មានគង់ ១ ខែ ហើយលោកស្នើថា បើលោកហៅឲ្យចូល

ធ្វើការស៊ីប្រាក់ថ្ងៃ ជាពួកជាងនៅសាលាដែកនេះ តើព្រមមកធ្វើទេ? ។

ដោយខ្ញុំធ្វើការលក់ ជួនកាលបានច្រើន ជួនកាលតិច មានលក់មិនដាច់សោះក្នុង ១ ខែ ក៏មាន ដោយធ្វើការលក់មិនទៀង ទើបខ្ញុំតបទៅលោកវិញថា បើបានប្រាក់ខែច្រើនគួរសមខ្ញុំព្រមមកធ្វើ ។

លោកសួរខ្ញុំថា អ្នកឯងចង់បានប្រាក់ខែប៉ុន្មាន ?

ដោយកាលនោះ ប្រាក់មានតម្លៃណាស់ ទំនិញ អង្ករមួយតៅថ្លៃតែ ៥ កាក់ នៅព្រៃវែង ឬ ពោធិ៍សាត់ក្ដីរបើ ១ ថ្លៃតែ ៤ ឬ ៥ រៀល ទើបខ្ញុំឆ្លើយថា: បើបាន ៣០ រៀល ក្នុង ១ ខែខ្ញុំព្រមមកធ្វើ ។

លោកទុនគូសគិតលេខបន្តិចលោកថា អ្នកឯងចូលធ្វើការជាដំបូង មិនទាន់ឲ្យស៊ីប្រាក់ខែទេ គេឲ្យស៊ីប្រាក់ថ្ងៃ ១ ថ្ងៃ មួយរៀលម្ភៃសេន បើគិតតាមចំនួននេះ ឃើញបានដល់ទៅ ៣៦ រៀល តែគេត្រូវកាត់ថ្ងៃអាទិត្យនិងថ្ងៃបុណ្យ បើមានឈប់អស់ ៤-៥ រៀល ក្នុង ១ ខែ អ្នកឯងបើគប្រាក់បានដាច់ ៣០ រៀលដែរ មេចព្រមមកធ្វើការឬទេ? បើព្រមដាច់ខែនេះ ចូលមកធ្វើការថ្ងៃទី ១ អាព្រិលទៅ ។

ខ្ញុំទូលថា បាទ ខ្ញុំព្រម ហើយនិយាយអរគុណលោក រួចលាលោកមកផ្ទះវិញ ។

ខ្ញុំបានចូលធ្វើការជាជាងក្នុងកន្លែងជាងឡាប ស៊ីប្រាក់ថ្ងៃតាំងពីខែមេសា គ.ស. ១៩២៤ គ្មានការគួរគំនូរអ្វីទេ មានតែការលាបថ្នាំ គុ ខូ

កៅអីរបស់រោងការដែលចាស់ ៗ គេបញ្ជូនមកឲ្យលាបថ្នាំឲ្យបានស្រស់ថ្មី និងមានការលាបក្តារតុ ឬ ស្លាកសរសេរតួអក្សរធំ ៗ យកទៅដាក់នៅខ្លោងទ្វារ ឬលើមាត់ទ្វារលើបន្ទប់មន្ទីររោងការ ឬ សាលារៀន ឲ្យតែមានការលាបការតួអក្សរធំ ៗ ត្រូវតែខ្ញុំធ្វើ តែមិនមែនខ្ញុំជាអ្នកទទួលការទេ មានមេជាងយួនម្នាក់ជាអ្នកទទួលការហើយបង្គាប់ចាត់ការត្រូវធ្វើយ៉ាងណា ៗ ខ្ញុំតាមវា តែវាចិត្តអាក្រក់ ខ្ញុំចំផ្គាប់ផ្គុនថ្នមចិត្តវាយ៉ាងណា ក៏វានៅតែលាក់បាំងមិនចង់ឲ្យខ្ញុំចេះសោះ វាគ្រាន់តែឲ្យខ្ញុំលាង ជូតសំអាត ឬខាត់ឲ្យស្អាតនិងកោសថ្នាំចាស់ចោលប៉ុណ្ណោះ គ្រឿងការទិញប្រដាប់សម្រាប់យកមកធ្វើការ វាមិនឲ្យខ្ញុំដឹងជាទិញពីណាទេ វាបានថ្នាំមកលាយយ៉ាងម៉េច វាមិនឲ្យខ្ញុំឃើញទៀត វាពួនលាយ បើខ្ញុំកៀកទៅជិតវាប្រើខ្ញុំទៅធ្វើនេះធ្វើនោះឆ្ងាយពីវា តែខ្ញុំមានគំនិត គិតលួចមើល តាមស្រមោលក្នុងកញ្ចក់ឆ្លុះដែលមាននៅគ្រប់រថយន្ត ខ្ញុំខាត់ផងលួចមើលវាផង វាចាក់ពកកទឹកកំប៉ុងណាច្រើនកំប៉ុងណាតិច ថ្នាំពណ៌ពីនាយឬលាយបញ្ចូលគ្នា យកកំប៉ុងណាចាក់ចូលក្នុងកំប៉ុងណា ដាក់សាំងតេរេបង់ទីនច្រើនឬតិច កូរយ៉ាងម៉េច ខ្ញុំលួចមើលឃើញ កត់ចំណាំទុក ដោយក្រោយពេលវាលាយរួច ខ្ញុំអាចទៅជិតទូដាក់ថ្នាំបាន ខ្ញុំទៅមើលសំគាល់បញ្ជាក់កំប៉ុងថ្នាំនិងប៊ុងវ៉ាកនីថែមទៀត ៗ

តាមសំដីមេជាងយួននោះ វាមិនចង់ឲ្យខ្មែរចេះធ្វើការដូចវា ១ ចង់

បានយួនគ្នាៈមកធ្វើការនៅកន្លែងខ្ញុំ ។ ដឹងគំនិតក៏ដោយក៏ចេះតែនិយាយ បារាំងថា ខ្ញុំចេះតែគួរមិនចេះលាបទេ ។ បារាំងថាឲ្យក៏បង្រៀនខ្ញុំឲ្យចេះលាបផងទៅ ក៏ថាខ្ញុំធ្វើជាងស៊ីប្រាក់ខែទៅហើយ មិនមែនកូនសិស្សឯណា បើកូនសិស្សមករៀនគ្មានប្រាក់ខែទើបក៏បង្រៀន ។

បារាំងបែបដូចជាស្អប់យួននោះ ហៅខ្ញុំទៅនិយាយស្ងាត់ ។ ថា ឲ្យខ្ញុំខំរៀនហាត់ធ្វើការឲ្យបានល្អ ដូចជាជាងយួននោះ បើខ្ញុំចេះធ្វើការស្ទាត់គ្រប់ដូចជាងយួនវេលាណាលោកនឹងឲ្យខ្ញុំធ្វើជាមេជាងលាប ។

ការលាបដែលពិបាកនោះ គឺការលាបគួរថយន្ត ឲ្យរលោងដូចកញ្ចក់ គ្មានស្នាមដក់ គ្មានស្នាមហូរ គ្មានសម្រាមធូលីជាប់នឹងថ្នាំ ឯ តុ ទូ កៅអី គ្រឿងឈើក៏យ៉ាងហ្នឹងដែរ ឯអក្សរធំ ។ អក្សរបារាំង ខ្មែរ ចិន យួន ក៏ឲ្យល្អដូចជាអក្សរបោះពុម្ព ហើយឲ្យចេះធ្វើមុតប្រាយមានស្រមោលមានក្បាច់ខ្លះផង ។

ចំណែកខាងអក្សរខ្ញុំធ្វើបានល្អជាងយួន តែមានការរេះចូលមកត្រូវមុខខ្ញុំធ្វើម្នាក់ឯង មេជាងយួនដឹងថាខ្ញុំចេះ ក៏មិនរវល់ទេ ។ ដោយខ្ញុំសំគាល់ថា ខ្លួនខ្ញុំល្មមធ្វើការបានដូចជាយួនដែរ ខ្ញុំសូមលាបគួរថយន្តម្តង មេជាងយួនមិនព្រមដោយថាខ្លាចខូចខាតថ្នាំ ហើយខ្លាចយឺតយូរការផង ។ ខ្ញុំទៅនិយាយសុំដល់បារាំងថា បើមិនឲ្យខ្ញុំលាបលមើល ម្តេចនឹងថាចេះ ឬ មិនចេះ បើខ្ញុំលាបទៅហើយក៏ខូច ខ្ញុំខាត់លាបម្តងទៀត បើខ្វះថ្នាំ ខ្ញុំចេញប្រាក់ថ្លៃថ្នាំ ។ (នៅមានត)

# ផ្នែកកំណត់និងប្រវត្តិការណ៍

ភ្នំពេញថ្ងៃទី ៥ កញ្ញា ១៩៦៦

លេខ ១៤៩៩ ព.ប.

## នាយកនៃពុទ្ធសាសនបណ្ឌិត្យ

សូមនមស្ការព្រះតេជព្រះគុណព្រះមុនីកោសល

អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ។

សូមភានជ្រាប ។

តបតាមលិខិតពុទ្ធសាសនបណ្ឌិត្យលេខ ៩៩៨ ព.ប ចុះថ្ងៃទី ១១-៦-៦៦ ។

ខ្ញុំព្រះករុណា សូមប្រគេនភ្ជាប់មកជាមួយនេះ នូវសៀវភៅ « ពុទ្ធាពទកថា » ចំនួន ៥០ ក្បាល ជាស្នាព្រះហស្តរបស់ព្រះតេជ-ព្រះគុណម្ចាស់ ដែលទើបនឹងបោះពុម្ពហើយ ដើម្បីព្រះគុណម្ចាស់ប្រើប្រាស់ ឬ ធ្វើអំណោយដល់ពុទ្ធបរិស័ទខ្លះ តាមសព្វព្រះទ័យ ។

ខ្ញុំព្រះករុណា សូមថ្លែងជាថ្មីម្តងទៀត នូវអំណរព្រះគុណដ៏លើស-លប់ ចំពោះព្រះតេជព្រះគុណ ដែលបានប្រទានឥតបទធម៌នេះ ដល់វិជ្ជាឋាន ព្រមទាំងប្រគេនសព្ទសាធុការ ចំពោះព្រះគុណម្ចាស់ សូមបានប្រកបដោយ អាយុ វណ្ណៈ សុខៈ ពលៈ អស់កាលជាអង្វែងតទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ហត្ថលេខា៖ លាង ហ័ប អាន

ភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ១៩៦៦

លេខ ១៦១៣ គ.ប. នាយកនៃពុទ្ធសាសនបណ្ឌិត្យ

សូមនមស្ការសម្តេចព្រះពោធិវ័ង្ស អគ្គាធិការនៃពុទ្ធិកសិក្សា

និងជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក

សូមទានជ្រាប ។

ខ្ញុំព្រះករុណាម្ចាស់ សូមទានប្រគេនជាប់ជាមួយនេះ នូវសៀវភៅ « ពុទ្ធសាសនសង្ខេប » ចំនួន ១០០ ក្បាល ជាស្នាព្រះហស្ថរបស់សម្តេចជាម្ចាស់ ដែលពុទ្ធសាសនបណ្ឌិត្យទើបនឹងបោះពុម្ពហើយ ដើម្បីសម្តេចជាម្ចាស់ប្រើប្រាស់ ឬ ធ្វើអំណោយដល់ពុទ្ធបរិស័ទតាមសព្វព្រះទ័យ ។

ខ្ញុំព្រះករុណាម្ចាស់ សូមថ្លែងក្នុងនាមនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ និងក្នុងនាមផ្ទាល់ នូវអំណរព្រះគុណដ៏លើសលប់ ចំពោះសម្តេចជាម្ចាស់ ដែលបានប្រទានអគ្គបទសៀវភៅនេះ ដល់វិជ្ជាស្ថាន ព្រមទាំងប្រគេនពរសព្វសាធុការចំពោះសម្តេចជាម្ចាស់ សូមទានប្រកបដោយព្រះ អាយុ-វណ្ណៈ សុខៈ ពលៈ អស់កាលអង្វែងតទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសម្តេចជាម្ចាស់មេត្តាទទួលនូវគារវភាព ដ៏ល់អុតល់ទុនទឹង ស្វាមីភក្តិយ៉ាងស្មោះបំផុតរបស់ខ្ញុំព្រះករុណាម្ចាស់ ។

ហត្ថលេខា : លាង - ហ៊ប អាន

# ការចាត់តាំងបុគ្គលិក

តាមប្រកាសលេខ ២.៧៤៩ ចុះថ្ងៃ ១៨ ខែ តុលា ១៩៦៦ បានចាត់តាំងបុគ្គលិកនៃរដ្ឋបាលពុទ្ធសាសនបណ្ឌិត្យ (ក្រសួងធម្មការ) ជានាយការិយាល័យនិងជានាយផ្នែកដូចតទៅ ៖

១- អ្នកស្រី ពេជ្រ-សល់ នាមដើម ស្រ៊ិន-សារីយ៉ាន់ អត្តលេខ ៦៥០, លេខាធិការ ការិយាល័យនិងខេត្ត ថ្នាក់លេខ ១ ជានាយការិយាល័យទំនៀមទម្លាប់ ។

២- លោក ឈឹម-ណាគា អត្តលេខ ៦៦, លេខាធិការ ការិយាល័យ និង ខេត្ត ថ្នាក់លេខ ២ ជានាយការិយាល័យ គណនេយ្យ ។

៣- លោក ប៉ិ-សុវណ្ណា អត្តលេខ ២០, អ្នកនិពន្ធតែងសេចក្ដី ថ្នាក់លេខ ៥ ជានាយផ្នែកនៃការិយាល័យ ការបោះពុម្ពផ្សាយ ។

៤- លោក ដល-ធិត អត្តលេខ ២៥, អ្នកនិពន្ធតែងសេចក្ដីថ្នាក់លេខ ៦ ជានាយផ្នែកនៃការិយាល័យ ក្រុមជំនុំព្រះត្រៃបិដក ។

៥- លោក សូ-បូរ៉ អត្តលេខ ១០៩២, លេខាធិការ ការិយាល័យ និង ខេត្ត ថ្នាក់លេខ ៦ ជានាយផ្នែកនៃការិយាល័យ របៀបនិងបុគ្គលិក ។